បណ្ណាល័យ
គ.ជ.អ.ប

# ក្រសួងផែនការ

អគ្គនាយកដ្ឋានផែនការក្នុងកិច្ចសហការជាមួយអង្គការUNDP/UNOPS/CARERE

# ចំណេះដឹងស្ដីពីការកសាង ផែនការអភិវឌ្ឍន៍ខេត្ត

**កម្មវិធីសិលា**

354.968
UND
sh: training

ខែ កុម្ភៈ ១៩៩៩

library.ncdd.gov.kh
002381

*រៀបរៀងដោយៈ

-ចន វិចទ័រ បូទីនី

-ទុយ ភាព

-គង់ មុនីច័ន្ទ

***Prepared by**:

-J. Victor Bottini

-Tuy Pheap

-Kung Munichan

*ចូលរួមយោបល់ដោយៈ

-មន្ទីរផែនការនៃខេត្តទាំងប្រាំ

* **Commented by**:

- Planning Depts. in all 5 SEILA Provinces

*ពិនិត្យនិងកែសំរួលដោយៈ

-ហ៊ូ តាំងអេង

***Reviewed and Edited by** :

-Hou Taing Eng

*អនុញ្ញាតិអោយប្រើប្រាស់ដោយៈ

ក្រសួងផែនការ

***Approved by** :

Ministry of Planning

*បោះពុម្ពលើកទី១ចំនួន ៤០ ច្បាប់នៅបាត់ដំបង កម្ពុជា, តុលា ១៩៩៧

* First printing 40 copies in Battambang, Cambodia, October 1997

*បោះពុម្ពលើកទី២ចំនួន ១០០០ ច្បាប់នៅភ្នំពេញ កម្ពុជា, កុម្ភៈ ១៩៩៩

* Second printing 1000 copies in Phnom Penh, Cambodia, February, 1999

# មាតិកា


អារម្ភកថា ..... iii

សេចក្ដីផ្ដើម ..... iv

I. ភាពចាំបាច់និងសារសំខាន់នៃការធ្វើផែនការ ..... 1

១.១ និយមន័យផែនការ ..... 1

១.២ ប្រភេទនៃផែនការ ..... 1

១.៣ បុព្វហេតុនៃការធ្វើផែនការ ..... 2

១.៤ តួនាទីរបស់រដ្ឋក្នុងសេដ្ឋកិច្ចផ្សារសេរី ..... 3

១.៥ តួនាទីផែនការអភិវឌ្ឍន៍នៅបណ្ដាប្រទេសអាស៊ី ..... 3

១.៦ ការវិវត្តនៃនយោបាយផែនការអភិវឌ្ឍន៍នៅប្រទេសអាស៊ីមួយចំនួន ..... 8

II. វដ្តនៃការកសាងផែនការ ..... 20

២.១ វដ្តនៃការកសាងផែនការទូទៅ ..... 20

២.២ បទពិសោធន៍នៃការកសាងផែនការអភិវឌ្ឍន៍ខេត្ត ..... 21

III. បែបផែននៃផែនការអភិវឌ្ឍន៍ខេត្ត ..... 24

៣.១ ប្រតិទិននៃការកសាងផែនការអភិវឌ្ឍន៍ខេត្ត ..... 24

៣.២ ឯកសារជាមូលដ្ឋាន ..... 25

៣.៣ ការចូលរួមក្នុងការកសាងផែនការអភិវឌ្ឍន៍ខេត្ត ..... 26

៣.៤ ទំនាក់ទំនងអន្តរវិស័យក្នុងការកសាងផែនការ ..... 27

៣.៥ ទំរង់នៃផែនការអភិវឌ្ឍន៍ខេត្ត ..... 29

៣.៥.១ ជំពូក១ ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច ..... 30

៣.៥.២ ជំពូក២ ក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត ..... 31

៣.៥.៣ ជំពូក៣ ផែនការអភិវឌ្ឍន៍មូលដ្ឋាន ..... 33

៣.៥.៤ ជំពូក៤ កម្មវិធីអភិវឌ្ឍន៍តាមវិស័យ ..... 33

៣.៥.៥ ជំពូក៥ កម្មវិធីវិនិយោគសំរាប់ការអភិវឌ្ឍន៍ខេត្ត ..... 37

៣.៦ ផែនទីមូលដ្ឋានសំរាប់ប្រើនៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត ..... 37

៣.៧ ការធ្វើសមាហរណកម្មផែនការឃុំ ........................................................................ 37

IV. ឧបសម្ព័ន្ធ

៤.១. តារាងគំរូកម្មវិធីវិនិយោគសំរាប់ការអភិវឌ្ឍន៍ខេត្ត ........................................ 47

៤.២. តារាងគំរូឡូក់ហ្វ្រេម ........................................................................ 48

៤.៣. តារាងគំរូបញ្ជីគំរោងដែលបាននឹងកំពុងដំណើរការឆ្នាំ១៩៩៧របស់ឃុំ ............ 49

៤.៤. តារាងគំរូបញ្ជីសំណើគំរោងអាទិភាពរបស់ឃុំ ........................................ 50

៤.៥. តារាងគំរូផែនការការងារស្រុកប្រចាំត្រីមាស ........................................ 51

៤.៦. ផែនទីគំរូបង្ហាញអំពីតំបន់គោលដៅនៃកម្មវិធីសិលា ................................ 52

៤.៧. ដំណើរការកសាងផែនការមូលដ្ឋាន ........................................................ 53

៤.៨. និតិវិធីក្នុងការអនុវត្តន៍ផែនការមូលដ្ឋាន .................................................. 58

៤.៩. និតិវិធីក្នុងការគ្រប់គ្រងកិច្ចការអភិវឌ្ឍន៍មូលដ្ឋាន .................................... 65

# អារម្ភកថា

ផែនការគឺជាឧបករណ៍ចាំបាច់និងមានសារៈសំខាន់ណាស់ សំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិ ។ ប្រទេសណាក៏ដោយ ទោះជាប្រទេសនោះអនុវត្តប្រព័ន្ធគ្រប់គ្រងណាក្តី ក៏ប្រព័ន្ធផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច (មានផែនការថ្នាក់ជាតិនិងផែនការថ្នាក់តំបន់) នៅតែជាឧបករណ៍ចាំបាច់មិនអាចខ្វះបាន។ ជាតុពិត ផែនការគឺផ្តើមចេញមកពីបញ្ហាចោទនិងតំរូវការ។ កាលណាមានបញ្ហា នោះតែងតែមានដំណោះស្រាយ។ ការគិតទុកជាមុនសំរាប់ដោះស្រាយនូវបញ្ហាផ្សេងៗទាំងនោះហើយ ដែលនាំឱ្យកើតចេញមកនូវផែនការ និងការរៀបចំកម្មវិធីឬគំរោងផ្សេងៗ ដើម្បីអនុវត្តន៍ឱ្យមានការផ្លាស់ប្តូរបញ្ហាចោទទាំងនោះ ។ ដូចនេះផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចគឺជាការគ្រោងទុក នូវដំណោះស្រាយក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ ។

ដើម្បីអោយដំណើរការអភិវឌ្ឍន៍ប្រទេសជាតិប្រព្រឹត្តទៅបានល្អ នោះក្នុងផែនការអភិវឌ្ឍន៍ត្រូវតែមានការគ្រោងទុកនូវដំណោះស្រាយត្រឹមត្រូវ សមស្រប ច្បាស់លាស់ល្អ ឈរលើលក្ខណៈវិភាគសភាពការណ៍គ្រប់ជ្រុងជ្រោយ លើកឡើងបានច្បាស់ពិតប្រាកដ អំពីបញ្ហាចោទ និងតំរូការផ្សេងៗ ។ មន្ត្រីផែនការត្រូវតែយល់ដឹងឱ្យបានច្បាស់ អំពីភាពចាំបាច់និងសារៈសំខាន់របស់ផែនការ វដ្តនៃការកសាងផែនការ និងបែបផែននៃផែនការអភិវឌ្ឍន៍ ។

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាកំពុងអនុវត្ត យន្តការគ្រប់គ្រងតាមបែបផែនប្រពន្ឋ័សេដ្ឋកិច្ចទីផ្សារ។ និន្នាការឯកជនភាវូនីយកម្មលើមធ្យោបាយផលិតកម្ម និងសេរីភាវូនីយកម្មនៃមុខរបរអាជីវកម្ម បានមកជំនួសសេដ្ឋកិច្ចប្រមូលផ្តុំ ដែលមានមូលដ្ឋានផ្អែកលើកម្មសិទ្ធរដ្ឋនិងសមូហភាព ដែលបានគ្របដណ្តប់ប្រមាណមួយទសវត្សកន្លងមកហើយ ។ ក្នុងប្រព័ន្ធគ្រប់គ្រងបច្ចុប្បន្ន ផែនការក៏តំរូវអោយមានបំលាស់ប្តូរដែរ គឺផ្លាស់ប្តូរពីផែនការមានលក្ខណៈបញ្ជារដ្ឋបាល មកជាផែនការមានលក្ខណៈណែនាំ ដែលទាមទារឱ្យមានប្រពន្ឋ័ផែនការមួយតាមបែបវិមជ្ឈការ មានលក្ខណៈស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នាគ្របវិស័យទាំងអស់។

ដោយធ្លាប់មានបទពិសោធន៍ ក្នុងការធ្វើផែនការក្នុងប្រព័ន្ធសេដ្ឋកិច្ចប្រមូលផ្តុំ នៅក្នុងទសវត្សទី៨០ នោះក្រោយពីមានការផ្លាស់ប្តូរមក ជាពិសេសក្រោយពេលបោះឆ្នោត ឆ្នាំ១៩៩៣ ការកសាងផែនការច្រើនតែប្រមូលផ្តុំបាននៅតែថ្នាក់កណ្តាលប៉ុណ្ណោះ ដូចជាការកសាងផែនការស្តារសេដ្ឋកិច្ច-សង្គមកិច្ចរយៈពេល ២ឆ្នាំ(១៩៩៤-៩៥) ផែនការវិនិយោគសាធារណៈ ផែនការសកម្មភាពអាហារូបត្ថម្ភជាតិ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រាំឆ្នាំលើកទី១ (១៩៩៦-២០០០) ជាដើម ។ នៅក្នុងពេលជាមួយនេះ ការរៀបចំផែនការថ្នាក់ខេត្តត្រូវបានអសកម្មអស់មួយរយៈ ។ មកដល់ឆ្នាំ១៩៩៦ ដោយមានជំនួយឧបត្ថម្ភពីអង្គការ

ផែនការថ្នាក់ខេត្តត្រូវបានអសកម្មអស់មួយរយៈ ។ មកដល់ឆ្នាំ១៩៩៦ ដោយមានជំនួយឧបត្ថម្ភពីអង្គការ UNDP/CARERE នោះបានជួយពង្រឹងសមត្ថភាពក្នុងការសាកល្បងកសាងផែនការអភិវឌ្ឍន៍ថ្នាក់ខេត្ត ក្នុងខេត្តចំនួន៥ជាដំបូងគឺៈ ខេត្តបាត់ដំបង ពោធិសាត់ សៀមរាប បន្ទាយមានជ័យ និង រតនគិរី ។ ក្រោយពីបានទទួលការឧបត្ថម្ភនេះឃើញថា បណ្តាខេត្តទាំង៥ បានកសាងផែនការអភិវឌ្ឍន៍ខេត្តឆ្នាំ១៩៩៧ ទទួលបានលទ្ធផលល្អ ។ ដូច្នេះ ដើម្បីពង្រីកបទពិសោធន៍នេះទៅបណ្តាខេត្តឯទៀត សៀវភៅ "**ចំណេះដឹងស្តីពីការកសាងផែនការអភិវឌ្ឍន៍ខេត្ត**" ក៏ត្រូវបានរៀបរៀងឡើងក្នុងក្របខណ្ឌក្រសួងផែនការ (អគ្គនាយកដ្ឋានផែនការ) ក្រោមការជួយឧបត្ថម្ភពីអង្គការ UNDP/CARERE សំរាប់ជាមូលដ្ឋានពិចារណា ដើម្បីកសាងផែនការអភិវឌ្ឍន៍ខេត្តដទៃទៀត ។

សង្ឃឹមថា ចំណេះដឹងស្តីពីការកសាងផែនការអភិវឌ្ឍន៍ខេត្តនេះ នឹងផ្តល់ជាមូលដ្ឋានជំនួយស្មារតីយ៉ាងសំខាន់ ក្នុងការកសាងផែនការ អភិវឌ្ឍន៍ខេត្តឱ្យបានល្អប្រសើរ រួមចំណែកក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការកាត់បន្ថយភាពក្រីក្រ ។

ឆ្លៀតឱកាសនេះ សូមថ្លែងអំណរគុណចំពោះលោក Scott Lieper នាយកកម្មវិធីយែរេរបស់អង្គការUNDPប្រចាំនៅប្រទេសកម្ពុជា និងសូមថ្លែងអំណរគុណចំពោះអង្គការUNDP/CARERE ទាំងមូលក្នុងកិច្ចសហប្រតិបត្តិការ និងការជួយឧបត្ថម្ភ គាំទ្រទាំងបច្ចេកទេស សំភារៈ និងស្មារតី ក្នុងការងារនេះ។ សូមថ្លែងអំណរគុណផងដែរចំពោះលោក Victor Bottini ជាទីប្រឹក្សាផែនការប្រចាំអង្គការ UNDP/CARERE ព្រមទាំងសហការីទាំងអស់ ដែលបានជួយសហការក្នុងការរៀបចំសៀវភៅនេះឡើង ។ សូមសសើរដល់អគ្គនាយកដ្ឋានផែនការរបស់ក្រសួងផែនការ ដែលបានសហការល្អ រៀបចំចងក្រងជាសៀវភៅ "ចំណេះដឹងស្តីពីការកសាងផែនការអភិវឌ្ឍន៍ខេត្ត" នេះ ។

សង្ឃឹមថាអង្គភាពផែនការតាមបណ្តាខេត្ត-ក្រុងទាំងអស់ ផ្អែកលើចំណេះដឹងស្តីពីការកសាងផែនការអភិវឌ្ឍន៍ខេត្តនេះ នឹងខិតខំកសាងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុងរបស់ខ្លួនឱ្យបានល្អ ហើយរួមជាមួយនឹងអាជ្ញាធរដែនដីគ្រប់ថ្នាក់ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា អនុវត្តផែនការបានសំរេចជោគជ័យជាស្ថាពរ ។

ភ្នំពេញ ថ្ងៃទី 12 កុម្ភៈ ១៩៩៩

រដ្ឋមន្ត្រីក្រសួងផែនការ

ឆាយ ថន

# សេចក្តីផ្តើម

នេះគឺជាចំណេះដឹងដំបូងអំពី ជំហាន និងបញ្ហា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចខេត្ត-ក្រុងនៅក្នុងប្រទេសកម្ពុជា ។ ចំណេះដឹងនេះ គឺជាការរួមផ្សំនូវចំណុចគន្លឹះមួយចំនួនដែលមានចែងក្នុងលិខិតណែនាំរបស់ក្រសួងផែនការ នៅពេលចាប់ផ្តើមកសាងផែនការប្រចាំឆ្នាំនិមួយៗ ។ ចំណេះដឹងនេះអាចនឹងមានសារៈប្រយោជន៍ចំពោះគ្រប់ខេត្ត-ក្រុង ព្រោះថាចំណេះដឹងនេះត្រូវបានរៀបចំឡើងជាពិសេសសំរាប់ជាជំនួយដល់មន្ទីរផែនការខេត្ត-ក្រុងនានា ដែលមិនស្ថិតក្នុងកម្មវិធីសិលា ។

អត្ថន័យទាំងឡាយក្នុងចំណេះដឹងនេះ បានផ្អែកលើបទពិសោធន៍ដែលទទួលបានក្នុងការកសាងផែនការអភិវឌ្ឍន៍ខេត្តប្រាំ នៅឆ្នាំ១៩៩៧និង១៩៩៨ ដែលបានទទួលការជួយឧបត្ថម្ភផ្ទាល់ពី UNDP/OPS/CARERE សំរាប់កម្មវិធីសិលា ។ បច្ចុប្បន្ន ក្នុងការណែនាំធ្វើផែនការ មានយោបល់ផ្សេងៗដែលហាក់ដូចជាធ្វើអោយមានការលំបាកស្មុគស្មាញឬត្រូវចំណាយខ្ពស់ ។ ប៉ុន្តែ យើងជឿជាក់ថា ការកែសំរួលអោយសមស្របខ្លះៗអាចនឹងធ្វើឡើងបាន ដោយយោងទៅតាមស្ថានភាពជាក់ស្តែង របស់ខេត្ត-ក្រុងនិមួយៗដែលមានបទពិសោធន៍និងធនធានខ្លះៗ ហើយនិងរក្សាទុកនូវខ្លឹមសារដើមនៃចំណេះដឹងនេះ ។

ដើម្បីជាប្រយោជន៍ក្នុងការប្រើប្រាស់ចំណេះដឹងនេះ យើងសូមលើកបង្ហាញនូវចំណុចគន្លឹះមួយចំនួនដែលមាននៅក្នុងដំណើរការនៃការកសាងផែនការ ៖

- ផែនការដែលបានកសាង ត្រូវឆ្លើយតបនិងគោលការណ៍វិមជ្ឈការ សមាហរណកម្មផែនការគ្រប់វិស័យ ជាមួយផែនការតំបន់ និង លក្ខខណ្ឌរបស់ផែនការ ។ម្យ៉ាងទៀតផែនការក្នុងខេត្ត-ក្រុងនិមួយៗ ជាធម្មតាត្រូវឆ្លើយតបជាមួយនឹងផែនការជាតិ៥ឆ្នាំ ។ ដំណើរការនៃការរៀបចំផែនការទាំងនេះអាចជួយគាំទ្រឱ្យនិន្នាការវិមជ្ឈការកាន់តែទូលំទូលាយទៅទៀត ។

- ត្រូវធ្វើការជ្រើសរើសយ៉ាងម៉ត់ចត់ទៅលើគំរោងនានា ដោយយោងទៅលើប្រភពថវិកាមានកំណត់ ដូច្នេះផែនការត្រូវតែរំលេចឱ្យឃើញច្បាស់ពីអាទិភាពពិតប្រាកដ ពោលគឺមិនមែនគ្រាន់តែជាបញ្ជី "មហិច្ឆិតាគំរោងផែនការ" ដែលមានគំរោងការរាប់រយនោះទេ ។

- អាទិភាពការងាររបស់មន្ទីរជំនាញទាំងឡាយ គួរតែផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងតំរូវការជាអាទិភាពនៃអ្នកភូមិ ដែលបានសំដែងចេញតាមរយៈមេភូមិនិងមេឃុំ ។

- ផែនការដែលបានកសាងឡើង មិនមែនជាផែនការរបស់មន្ទីរផែនការខេត្ត-ក្រុងទេ តែជាផែនការរបស់ខេត្ត-ក្រុងទាំងមូលដែលអភិបាលខេត្ត និងមន្ទីរទាំងអស់រួមគ្នាកសាងឡើង ហើយដែល

បង្ហាញនូវសេចក្តី ត្រូវការជាអាទិភាពរបស់ប្រជាជនទូទាំងខេត្ត-ក្រុង ជាពិសេសប្រជាជននៅជនបទ។ មន្ទីរផែនការខេត្ត-ក្រុងមានតួនាទីយ៉ាងសំខាន់ ក្នុងការជួយសំរបសំរួលដំណើរការកសាងផែនការខេត្ត-ក្រុង ។

-ផែនការដែលមានភាពច្បាស់លាស់ និងមានសារប្រយោជន៍ គឺមិនវែងអន្លាយ មិនមានភាពស្មុគ្រស្មាញ និងមិនច្របូកច្របល់ ។ ផែនការនោះត្រូវតែអាចអនុវត្តបាន ដោយផ្អែកផ្ទាល់ទៅលើថវិកាមានកំណត់ ដែលបានផ្តល់ចំពោះគំរោងអាទិភាពជាមុន និង មានលទ្ធភាពទាក់ទាញប្រភពជំនួយដ៏ទៃបន្ថែមទៀត ។

មកដល់ពេលនេះ ការកសាងផែនការតាមរបៀបដូចបានរៀបរាប់មកខាងលើនេះ កំពុងតែបានដំណើរការក្នុងលក្ខណ:ជាការដកពិសោធន៍នៅតាមខេត្ត៥ (បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ សៀមរាប និងរតនៈគិរី) ក្នុងកម្មវិធីសិលា ដែលបានឧបត្ថម្ភទាំងបច្ចេកទេសថវិកាពីអង្គការUNPD/CARERE។ ដូច្នេះ សំរាប់ខេត្តទាំង៥ខាងលើ នោះសង្ឃឹមថាអាចនឹងបន្តការកសាង និងបង្កើនគុណភាពផែនការនេះអោយកាន់តែល្អប្រសើរ និងសំរាប់ជាមូលដ្ឋានពត៌មាន ជាមេរៀនដល់ខេត្តក្រុងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះខេត្តក្រុង ដែលមិនទាន់បានដំណើរការ នោះអគ្គនាយកដ្ឋានផែនការ យល់ថាសៀវភៅនេះ អាចមានសារ:ប្រយោជន៍ សំរាប់មន្ត្រីដែលត្រូវពាក់ព័ន្ធផ្ទាល់ ដល់ការរៀបចំសំរបសំរួលនិងកសាងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង (ពិសេសមន្ត្រីដែលបំរើការងារនៅមន្ទីរផែនការខេត្ត-ក្រុង ការិយាល័យផែនការស្រុក) សិក្សាជាចំណេះដឹងដំបូងអោយទៅជាការបំពេញតួនាទីភារកិច្ច របស់ខ្លួនតទៅថ្ងៃមុខ ។ អគ្គនាយកដ្ឋានផែនការ នឹងបន្តកិច្ចសហការជាមួយអង្គការUNDP/CARERE និងមន្ត្រីផែនការកម្ពុជាដែលកំពុងបំពេញការងារក្នុងកម្មវិធីសិលា នៅតាមខេត្តទាំង៥ ធ្វើការដកស្រង់បទពិសោធន៍ ចងក្រងជាមេរៀនទ្រឹស្តី ការណែនាំអនុវត្តន៍ ការត្រួតពិនិត្យនិងវាយតំលៃ អោយកាន់តែប្រសើរជាងនេះទៀត ។ គោលដៅនេះ ទាមទារអោយមានកិច្ចសហការដោយស្ម័គ្រចិត្ត ដោយទូលំទូលាយ ដោយនិរន្តរភាព និងតម្លាភាពពីគ្រប់មជ្ឈដ្ឋាន ។

សូមអោយការកសាងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង មានការរីកចំរើនជានិច្ច ។

សូមអរគុណ

# I. ភាពចាំបាច់និងសារៈសំខាន់នៃការធ្វើផែនការ

## ១.១ និយមន័យផែនការ

ផែនការគឺជាការគិតទុកជាមុន មានន័យថា យើងគិតទុកជាមុននូវអ្វីដែលយើងត្រូវធ្វើ ។ ផែនការអភិវឌ្ឍន៍ គឺជាការពិចារណារៀបចំជាមុនដោយប្រុងប្រយ័ត្ន នូវការអនុវត្តន៍សកម្មភាពមួយចំនួន ដែលអាចអោយយើងទទួលបាននូវគោលដៅមួយចំនួន (B.W.E. Wickramanayake, 1993) ។

## ១.២ ប្រភេទនៃផែនការ

គេអាចបែងចែកប្រភេទនៃផែនការទៅតាម ៖

- ពេលវេលា : ផែនការរយៈពេលវែង មធ្យម និង ខ្លី
- តួនាទី : ផែនការម៉ាក្រូ(Macro Plan) ផែនការវិស័យ(ផ្នែកជំនាញ)
- ទំហំ : ផែនការជាតិ ផែនការតំបន់ ផែនការមូលដ្ឋាន(តូចៗ)
- ស្ថាប័នរៀបចំ : ផែនការវិមជ្ឈការ(ពីមូលដ្ឋានភូមិឃុំ_ពីក្រោម) ផែនការមជ្ឈការ(ពីលើ)

លំដាប់ថ្នាក់នៃផែនការអភិវឌ្ឍន៍ត្រូវបានបង្ហាញអោយឃើញតាមរូបខាងក្រោម ៖




រូបទី១ ទិដ្ឋភាពឋានានុក្រមនៃផែនការអភិវឌ្ឍន៍
(Modify from Wickramanayake, Ebel, 1993)

## ១.៣ បុព្វហេតុនៃការធ្វើផែនការ

ការធ្វើផែនការ ជាទូទៅ តែងតែចាប់ផ្ដើមចេញមកពី បញ្ហាចោទ និងតំរូវការ ។ មានបញ្ហាតែងតែមានដំណោះស្រាយ ។ ការគិតទុកមុនគឺសំរាប់ដោះស្រាយបញ្ហាផ្សេងៗ ដែលនោះហើយនាំអោយលេចចេញមកនូវផែនការ និងការរៀបចំនូវកម្មវិធីឬគំរោងផ្សេងៗ សំរាប់អនុវត្តអោយមានការផ្លាស់ប្ដូរបញ្ហាចោទទាំងនោះ ។ ការបកស្រាយនេះ អាចសង្ខេបអោយឃើញតាមរយៈរូបទី២ខាងក្រោម ៖




រូបទី២ បុព្វហេតុដែលនាំអោយមានការធ្វើផែនការ

គេតែងតែមានការភ័ន្តច្រលំថាផែនការ ជាគំរោងដែលត្រូវយកទៅអនុវត្ត ។ តែគំនូសបំព្រួញក្នុងរូបទី២នេះ បានបង្ហាញអោយយើងយល់ច្បាស់ថា ចេញពីផែនការគេត្រូវមានរៀបចំជាគំរោងលំអិតបន្ថែមទៀត ដែលក្នុងនោះមានតាំងពីថវិកាចំណាយលំអិតសំរាប់សកម្មភាពនិមួយៗ ពេលវេលាអនុវត្តន៍ជាក់លាក់ គិតអំពីប្រសិទ្ធភាពសេដ្ឋកិច្ច បច្ចេកទេស ធនធានមនុស្សដែលត្រូវការ ស្ថាប័ននិងការគ្រប់គ្រង បែបបទរដ្ឋបាល ការជះឥទ្ធិពលទៅលើបរិស្ថាន ការទាក់ទងនិងនយោបាយប្រទេស សង្គមនិងវប្បធម៌ ។ល។

ដោយសារតែមានការណែនាំបច្ចេកទេសផ្សេងៗគ្នា ទៅតាមការចង់បានរបស់អ្នកផ្ដល់ជំនួយនិមួយៗ នោះការណែនាំលំអិតស្ដីអំពីបច្ចេកទេសនៃការរៀបចំគំរោង(**Project design**) មិនបានលើកឡើងយកមកអធិប្បាយនៅក្នុងសៀវភៅនេះឡើយ ។

## ១.៤ តួនាទីរបស់រដ្ឋក្នុងសេដ្ឋកិច្ចផ្សារសេរី

ស្ថានភាពផ្លាស់ប្តូរនៃរបបនយោបាយនៅប្រទេសកម្ពុជា បានតំរូវអោយមានការផ្លាស់ប្តូរបច្ចេកទេសនៃការរៀបចំផែនការ ជាក់ស្តែងគឺ ៖

| | | |
|---|---|---|
| ពីមុន | : | សេដ្ឋកិច្ចផែនការមជ្ឈការ (ឬផែនការបញ្ជាពីលើ) បានផ្លាស់ប្តូរមក |
| ពេលនេះ | : | សេដ្ឋកិច្ចផែនការវិមជ្ឈការនិងតំរង់រកទីផ្សារ (ជាបែបផែនការណែនាំ) |

តាមការសង្កេត នៅក្នុងសេដ្ឋកិច្ចឆ្ពោះទៅរកទីផ្សារ រដ្ឋាភិបាលមានតួនាទី ៖

១_ បែងចែកប្រភពធនធានយ៉ាងណាឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

២_ ផ្តល់នូវទំនិញនិងសេវាសាធារណៈ ដែលមានលក្ខណៈយុទ្ធសាស្ត្រ (តំរូវការជាមូលដ្ឋាន ដូចជា អប់រំ និង ហេដ្ឋារចនាសម្ព័ន្ធ ។ល។)

៣_ កំនត់ចេញនូវ " បរិយាកាសគោលនយោបាយបើកចំហរ " សំរាប់ការអភិវឌ្ឍន៍វិស័យឯកជនមួយ ដែលប្រកបដោយការប្រកួតប្រជែង និងមានភាពប្រែប្រួល ។

ហេតុនេះ ដើម្បីអោយការអភិវឌ្ឍន៍នេះអាចប្រព្រឹត្តទៅបាន និងប្រកបដោយនិរន្តរភាព រដ្ឋាភិបាលត្រូវតែមានផែនការជាតិ ផែនការតំបន់ច្បាស់លាស់ ដើម្បីណែនាំ តំរង់ទិសឬអន្តរាគមន៍ ប្រយោជន៍អោយមានសមធម៌នៅក្នុងសង្គមជាតិទាំងមូល ។

## ១.៥ តួនាទីផែនការអភិវឌ្ឍន៍នៅបណ្តាប្រទេសអាស៊ី

មានប្រទេសជាច្រើននៅតំបន់អាស៊ី_ប៉ាស៊ីភិច បច្ចុប្បន្ន បាននិងកំពុងលូតលាស់ដោយមានជប៉ុនជាក្បាលម៉ាស៊ីនដឹកនាំសេដ្ឋកិច្ច ។ កំណើនសេដ្ឋកិច្ច តាមរយៈការកើនឡើងនៃវិនិយោគទុននិងពាណិជ្ជកម្ម បានជំរុញឧស្សាហកម្មសេដ្ឋកិច្ចថ្មី របស់ ហុងកុង កូរ៉េ សិង្ហបុរី និងតៃវ៉ាន អោយរីកចំរើនឡើង ។ នៅតំបន់អាស៊ីអាគ្នេយ៍ ដូចជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ ក៏បានឆ្លងកាត់ការរីកចំរើនយ៉ាងខ្លាំង និងបានធ្វើឧស្សាហ_ភាវូបនីយកម្មជាច្រើនផងដែរ ក្នុងកំឡុងពេលពីរទសវត្សចុងក្រោយនេះ(៧០_៩០)។ ប្រទេសនានានៅអាស៊ីខាងត្បូងបានចាប់យកចលករ របស់តំបន់អាស៊ីអាគ្នេយ៍និងអាស៊ីបូព៌ា ដោយបានរៀបចំនូវយុទ្ធសាស្ត្រនិងគោលនយោបាយអភិវឌ្ឍន៍របស់ពួកគេ ។ ចិនបានចាប់ផ្តើមបើកទូលាយសេដ្ឋកិច្ចខ្លួននាដើមឆ្នាំ១៩៨០ លើវិស័យពាណិជ្ជកម្មនិងវិនិយោគអន្តរជាតិ ដោយបានចាប់ផ្តើមកែទំរង់យ៉ាងឆាប់រហ័ស ពីផែនការសេដ្ឋកិច្ចប្រមូលផ្តុំ ទៅជាផែនការសេដ្ឋកិច្ចទីផ្សារ ។

ការកសាងផែនការអភិវឌ្ឍន៍ជាតិ បានក្លាយទៅជាការអនុវត្តន៍ជាក់ស្តែង នៅក្នុងប៉ុន្មានទសវត្សមក ហើយ នៅក្នុងប្រទេសជាច្រើននៅអាស៊ី ។ ជាការពិត ការកសាងផែនការបានក្លាយជាមធ្យោបាយយ៉ាង សំខាន់ សំរាប់ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម ហើយផែនការអភិវឌ្ឍន៍ក៏បានជួយអ្នករៀបចំគោល នយោបាយ ដោយផ្តល់ជាការនែនាំសំរាប់រៀបចំនិងអនុវត្តគោលនយោបាយសេដ្ឋកិច្ច_សង្គមកិច្ចរបស់គេ ។ ព្រឹត្តិការណ៍ជាអំណៈអំណាងជាច្រើនបានបង្ហាញថា ការរីកចំរើនលូតលាស់ឆាប់រហ័ស និងឧស្សាហូបនីយ កម្មនៅក្នុងប្រទេសសេដ្ឋកិច្ចអាស៊ីមួយចំនួន បានមកពីការរៀបចំដោយប្រុងប្រយ័ត្ននូវផែនការអភិវឌ្ឍន៍ដែល បានជួយក្នុងការកំណត់យុទ្ធសាស្ត្រនិងគោលនយោបាយ សំរាប់ជំរុញកំណើនសេដ្ឋកិច្ចនិងកិច្ចអភិវឌ្ឍន៍ ។ ប៉ុន្តែ បទពិសោធន៍នៃការរៀបចំផែនការ មានភាពខុសគ្នាតាមប្រទេសនិមួយៗ ហើយនិងទទួលបាន ជោគជ័យនិងការបរាជ័យ ក្នុងការសំរេចអោយបាននូវគោលដៅនៃកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច_សង្គមកិច្ច ក៏ ផ្សេងៗគ្នាដែរ ក្នុងចំនោមប្រទេសអាស៊ីទាំងនោះ ។

ផែនការអភិវឌ្ឍន៍ត្រូវតែបានប្រែក្លាយអោយទៅជា វិធានការ គោលនយោបាយរឹងមាំជាក់លាក់ ហើយគេត្រូវតែអនុវត្តតាមផែនការនោះដាច់ខាត ។ ប៉ុន្តែ ត្រឹមតែវត្តមានផែនការអភិវឌ្ឍន៍តែមួយ ក៏មិន អាចធានាបាននូវជោគជ័យនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះទេ ។ នៅអាស៊ី យើងបានឃើញមានករណីប្រទេស ដែលមានសេដ្ឋកិច្ចលូតលាស់និងការអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស តែមានការខំប្រឹងប្រែងបន្តិចបន្តួចប៉ុណ្ណោះ លើការងារកសាងផែនការ ហើយក៏មានប្រទេសខ្លះមានផែនការអភិវឌ្ឍន៍ដ៏ល្អឥតខ្ចោះ តែបែរជាមានការ លូតលាស់តិចតួចទៅវិញ ។ ជាក់ស្តែង នៅសាធារណរដ្ឋកូរ៉េ ដែលមានដំណើរការរៀបចំផែនការអភិវឌ្ឍន៍ ល្អឥតខ្ចោះ ដោយរដ្ឋាភិបាលបានធ្វើអន្តរាគមន៍យ៉ាងខ្លាំងទៅលើសេដ្ឋកិច្ច ចំនែកនៅឯសិង្ហបូរីវិញ គេពុំឃើញ មានផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជាផ្លូវការណាមួយទេ ប៉ុន្តែរដ្ឋាភិបាលបែរជាមានលទ្ធភាពដាក់ចេញ នូវគោល នយោបាយសេដ្ឋកិច្ចយ៉ាងមានប្រសិទ្ធភាព នៅក្នុងវិស័យជាច្រើន ។ ជោគជ័យផ្នែកសេដ្ឋកិច្ចនៅកូរ៉េនិង សិង្ហបូរី អាចនិយាយបានថាជាជោគជ័យមួយដូចគ្នា ប៉ុន្តែ បើប្រៀបទៅជាមួយនិងសេដ្ឋកិច្ចហុងកុង គឺ ហុងកុងរិតតែមានសេដ្ឋកិច្ចសេរីជាងទៅទៀត(Laissez-faire Economy = សេដ្ឋកិច្ចដែលគ្មានការគ្រប់គ្រង ឬត្រួតពិនិត្យពីរដ្ឋាភិបាល) ។ ប្រទេសដែលមានជោគជ័យតិចបំផុត ប៉ុន្តែមានការកសាងផែនការយ៉ាង ខ្លាំងក្លា ម៉ត់ចត់នោះ គឺប្រទេសឥណ្ឌា ។

`ការកសាងផែនការអភិវឌ្ឍន៍ គឺជាដំណើរការមួយស្មុគ្រស្មាញ ដែលជាប់ទាក់ទងជាមួយនិងការ ប្រមូលពត៌មានគ្រប់គ្រាន់ ការវាយតំលៃលើឯកសារកិច្ចអភិវឌ្ឍន៍កន្លងមក និងការទស្សន៍ទាយទុកជាមុននូវ ទំនោរនៅពេលអនាគត់ ព្រមទាំងអនុម័តអោយបាននូវគោលដៅកំណត់ ក៏ដូចជាវិធានការគោលនយោបាយ

សំខាន់ៗ សំរាប់រយៈពេលខ្លី មធ្យម និងវែង ។ គេមាន ផែនការអភិវឌ្ឍន៍ជាច្រើនសណ្ឋានទៅតាមពេលវេលា ដូចជា ផែនការអភិវឌ្ឍន៍រយៈពេលវែង ដែលគ្របដណ្តប់សំរាប់រយៈពេលពី១០ទៅ២០ឆ្នាំ និងផែនការរយៈពេលមធ្យមសំរាប់រយៈពេលពី៣ទៅ៦ឆ្នាំ ។ ប៉ុន្តែនៅប្រទេសអាស៊ីភាគច្រើន គេច្រើនផ្តោតជាសំខាន់ទៅលើផែនការរយៈពេលមធ្យម ដែលគ្របដណ្តប់សំរាប់រយៈពេល៥ឆ្នាំ ។ ក្រៅពីផែនការជាតិក៏មានផែនការអភិវឌ្ឍន៍ប្រចាំតំបន់ ខេត្ត និងសំរាប់ថ្នាក់មូលដ្ឋានផ្សេងៗ ។ លើសពីនេះទៅទៀតក៏មានផែនការវិស័យដែលបានរៀបចំឡើង ដោយកំណត់គោលដៅ និងវិធានការជាគោលនយោបាយ សំរាប់សំរេចបាននូវគោលដៅទាំងនេះ តាមលក្ខណៈសេដ្ឋកិច្ចនៃវិស័យដោយឡែកៗពីគ្នា ។ ប្រសិទ្ធភាពនៃការអនុវត្តនិងការសំរបសំរួលផែនការអភិវឌ្ឍន៍ នៅលំដាប់ថ្នាក់ផ្សេងៗ បានក្លាយទៅជាបញ្ហាស្នូលនិងសំខាន់នៅក្នុងប្រទេសជាច្រើន ។ ពេលវេលាបានកន្លងជាច្រើនឆ្នាំ ជាមួយនិងការរីកចំរើននូវសមត្ថភាពរបស់រដ្ឋាភិបាលនៅប្រទេសអាស៊ីជាច្រើន បច្ចេកទេសកសាងផែនការអភិវឌ្ឍន៍ បានក្លាយជាបច្ចេកទេសថ្មីទំនើបជាសកល ។ នៅប្រទេសអាស៊ីមួយចំនួន ការប្រើប្រាស់ "របៀបគំរូ" នៃតារាងអ៊ីនភុត_អៅភុត និងសេដ្ឋកិច្ចមានទ្រង់ទ្រាយធំ ជាឧបករណ៍សំរាប់កសាងផែនការអភិវឌ្ឍន៍ បាននិងកំពុងផ្សព្វផ្សាយនិងប្រើប្រាស់យ៉ាងទូលំទូលាយ ។

ប៉ុន្តែ ដោយសារសេដ្ឋកិច្ចកាន់តែអភិវឌ្ឍន៍ និងកាន់តែបើកចំហរឆ្ពោះទៅកាន់ពិភពលោកខាងក្រៅនោះ កត្តាទាំងឡាយ ដែលត្រូវពិចារណានៅក្នុងដំណើរការកសាងផែនការ ក៏កាន់តែមានភាពស្មុគស្មាញ ។ ការរៀបចំកសាងផែនការអភិវឌ្ឍន៍ និងការអនុវត្តន៍ក៏កាន់តែមានភាពលំបាកខ្លាំងណាស់ដែរ។ សំរាប់ប្រទេសអាស៊ីជាច្រើន ការកសាងផែនការអភិវឌ្ឍន៍ មានចរិតលក្ខណៈជាទូទៅជាផែនការបែបនែនាំចង្អុលបង្ហាញ។ គំរោងផែនការអភិវឌ្ឍន៍បានកំណត់នូវគោលដៅ ដែលនិងត្រូវទទួលបានក្នុងរយៈពេលណាមួយកំណត់ ជាមួយនិងការកំណត់គោលនយោបាយទូទៅ ដើម្បីនាំឆ្ពោះទៅរកការទទួលបាននូវគោលដៅទាំងនោះ ។ ប៉ុន្តែការអនុវត្តន៍ជាក់ស្តែង ភាគច្រើនអាចខុសពីផែនការដែលបានរៀបចំទុក ។ គោលដៅដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ អាចមានលក្ខណៈខុសគ្នាជាច្រើន ពីលទ្ធផលដែលទទួលបានជាក់ស្តែង ដោយសារមូលហេតុផ្សេងៗ ។

សេដ្ឋកិច្ចភាគច្រើននៅអាស៊ី ជាសេដ្ឋកិច្ចទីផ្សារដែលផ្នែកឯកជនបានបំពេញតួនាទីចំបង ក្នុងការកំណត់ថា តើមុខទំនិញនិងសេវាកម្មអ្វីនិងដូចម្តេចខ្លះដែលត្រូវផលិត ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងពិភពលោកជាក់ស្តែង ការផ្លាស់ប្តូរយ៉ាងរហ័សនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក បានជះឥទ្ធិពលយ៉ាងសំបើមទៅលើសេដ្ឋកិច្ចក្នុងស្រុក នាំអោយគោលដៅនានាដែលបានកំណត់ឡើងនៅក្នុងផែនការអភិវឌ្ឍន៍

អាចក្លាយជាមិនពិតជាក់ស្តែងយ៉ាងងាយបំផុត ហើយការកែសំរួលឡើងវិញក៏ត្រូវបានធ្វើឡើងជាចាំបាច់។ លើសពីនេះទៅទៀត នៅក្នុងប្រទេសអាស៊ីជាច្រើន សកម្មភាពសេដ្ឋកិច្ចជាច្រើនត្រូវបានធ្វើឡើងដោយផ្នែកឯកជន នាំអោយតួនាទីរបស់ផ្នែកឯកជនពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែមានសារសំខាន់ឡើងៗ និងបានធ្វើអោយរដ្ឋាភិបាលមានការលំបាកកាន់តែ ខ្លាំងក្នុងការធ្វើ"យថាទស្សន៍"អំពីទំនោរសេដ្ឋកិច្ច ក៏ដូចជាការធានាអោយបាននូវការអនុវត្តន៍ផែនការអភិវឌ្ឍន៍អោយមានប្រសិទ្ធភាពផងដែរ ។ ប៉ុន្តែ នេះមិនមែនមានន័យថាតួនាទីរបស់រដ្ឋាភិបាលនិងការងារកសាងផែនការអភិវឌ្ឍន៍ត្រូវបានបន្ថយនោះទេ ។ ផ្ទុយទៅវិញ វាបានបង្កើននូវសារៈសំខាន់នៃយន្តការទីផ្សារ និងចាំបាច់ត្រូវការអោយមានការឆ្លើយតបយ៉ាងរួសរាន់ទៅនិងការផ្លាស់ប្តូរនៃស្ថានភាពទាំងនៅក្នុងស្រុកនិងក្រៅស្រុក ហើយការរៀបចំបង្កើតស្ថាប័ន ក៏ដូចជាបែបបទនិតិវិធីនៃការកសាងផែនការអភិវឌ្ឍន៍ ក៏ត្រូវមានការកែលំអរផងដែរ ។

ផែនការអភិវឌ្ឍន៍ គឺជាឯកសារដ៏សំខាន់ ដែលបានបញ្ជាក់ច្បាស់អំពីគោលនយោបាយប្រទេស ដោយបានផ្តោតជាសំខាន់ទៅលើអ្វីផ្សេងៗ ទៅតាមសម័យកាលខុសៗគ្នា ។ នៅប្រទេសអាស៊ី រដ្ឋាភិបាលភាគច្រើន មិនបានចូលរួមផលិតទំនិញ ឬផ្តល់សេវាកម្មជាទ្រង់ទ្រាយធំដុំនោះទេ ប៉ុន្តែរដ្ឋាភិបាលនៅតែមានតួនាទីសំខាន់ នៅក្នុងការរៀបចំនិងអនុវត្តគោលនយោបាយសេដ្ឋកិច្ចនិងសង្គមកិច្ច ដែលមានឥទ្ធិពលទៅលើការសំរេចចិត្តវិនិយោគទុនរបស់ផ្នែកឯកជន ។ ក្នុងនោះ តួនាទីសំខាន់បំផុតរបស់រដ្ឋាភិបាល គឺការរៀបចំយុទ្ធសាស្ត្រនិងគោលនយោបាយអភិវឌ្ឍន៍ ការកំណត់អាទិភាពសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច_សង្គម និងការផ្តល់សេវាកម្មហេដ្ឋារចនាសម្ព័ន្ធនិងស្ថាប័នសំខាន់ៗ ។ ជាមួយគ្នានេះដែរការអនុវត្តន៍មុខងារសំខាន់នានាដែលជាប់ទាក់ទងទៅនិង គោលដៅអភិវឌ្ឍន៍រយៈពេលវែងរបស់ប្រទេស ដូចជា ការត្រួតពិនិត្យលើកំណើនប្រជារាស្ត្រ កិច្ចអភិវឌ្ឍន៍ជនបទ និងការការពារបរិស្ថានជាដើម នៅតែជាតួនាទីរបស់រដ្ឋាភិបាល។

ទំនោរមួយដែលសង្កេតឃើញ គឺការផ្លាស់ប្តូរឆ្ពោះទៅកាន់សេដ្ឋកិច្ចទីផ្សារ ហើយយន្តការទីផ្សារបានបង្កើនតួនាទីរបស់វាក្នុងការបែងចែកធនធាន (ការវិភាជន៍ធនធាន) ជាឧទាហរណ៍ ប្រទេសចិន ។ ប៉ុន្តែ ប្រទេសដ៏ទៃទៀតដូចជា ឥណ្ឌា នេប៉ាល បាននិងកំពុងដំណើរការកែទំរង់សេដ្ឋកិច្ចអោយទៅជាសេដ្ឋកិច្ចសេរី ដោយគ្មានការត្រួតពិនិត្យតំលៃនិងឯកជនភាវូបនីយកម្ម ។ នៅក្នុងសេដ្ឋកិច្ចទីផ្សារជាប្រពៃណីនៅអាស៊ីបូព៌ានិងអាស៊ីអគ្នេយ៍ តួនាទីផ្នែកឯកជនបានគ្របដណ្តប់ពីមួយថ្ងៃទៅមួយថ្ងៃ ដូចជានៅម៉ាឡេស៊ីនិងថៃ ឯកជនភាវូបនីយកម្មនៃសហគ្រាសសាធារណៈ បានក្លាយទៅជាធាតុមួយដ៏សំខាន់ នៅក្នុងផែនការអភិវឌ្ឍន៍ថ្មីៗនេះរបស់គេ ។ គេមានបំណងផងដែរក្នុងការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការ រវាងវិស័យសាធារណៈនិងផ្នែកឯកជន ដូចជាៈ ក្រុមប្រឹក្សាមុខជំនួញនៅម៉ាឡេស៊ី គណៈកម្មការប្រឹក្សាយោបល់រួម

សាធារណៈនិងឯកជននៅថៃជាដើម នៅកូរ៉េ គេក៏ឃើញមាននិន្នាការកាត់បន្ថយអន្តរាគមន៍របស់រដ្ឋាភិបាល នៅក្នុងសកម្មភាពសេដ្ឋកិច្ចដែរ ។

និន្នាការទូទៅមួយទៀតបានកត់សំគាល់ថា លទ្ធផលដែលបានមកពីការបើកចំហសេដ្ឋកិច្ចទៅរកពាណិជ្ជកម្មអន្តរជាតិនិងវិនិយោគទុនបរទេស នៅក្នុងសេដ្ឋកិច្ចរបស់ពួកគេនោះ បានធ្វើអោយប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីជាច្រើន ផ្តោតកាន់តែខ្លាំងទៅលើទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ ។ តើត្រូវកំរិតព្រំដែនជាមួយនឹងការផ្លាស់ប្តូរបរិយាកាសអន្តរជាតិដូចម្តេច ? ហើយតើត្រូវរក្សានូវការប្រកួតប្រជែងក្នុងការនាំចេញដើម្បីទប់ទល់ជាមួយនិងការកើតមានជាបន្ទាន់នូវប្លុកពាណិជ្ជកម្មយ៉ាងដូចម្តេច ? ការភ័យខ្លាចចំពោះកំណើនឡើងនៃពាណិជ្ជកម្មការពារនិយម គឺជា បញ្ហាធំសំខាន់ក្នុងចំនោមបញ្ហាដ៏ទៃទៀត ដែលបានផ្តោតការយកចិត្តទុកដាក់ដោះស្រាយ នៅក្នុងផែនការអភិវឌ្ឍន៍របស់ប្រទេសអាស៊ីជាច្រើន ។

លទ្ធផលនៃការអភិវឌ្ឍន៍បច្ចេកវិទ្យាយ៉ាងឆាប់រហ័ស បានធ្វើអោយប្រទេសមួយចំនួននៅអាស៊ី ផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើកិច្ចអភិវឌ្ឍន៍បច្ចេកវិទ្យារបស់គេ ។ ការអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានយកចិត្តទុកដាក់ខ្លាំងឡើងៗ ដោយបានសង្កត់ធ្ងន់នៅក្នុងនយោបាយសេដ្ឋកិច្ចរបស់គេ ។ ការសង្កត់ធ្ងន់ទៅលើបច្ចេកវិទ្យានិងធនធានមនុស្ស ត្រូវបានលេចឡើងច្បាស់នៅក្នុងករណី កូរ៉េ និងសិង្ហបូរី ។

ដោយសារប្រទេសជាច្រើននៅអាស៊ី បានអភិវឌ្ឍន៍កាន់តែប្រសើរឡើងនោះ និន្នាការទៅរកការផ្តោតទៅលើការបញ្ចូលបង្គុំនៃបញ្ហាសង្គម ទៅក្នុងផែនការអភិវឌ្ឍន៍របស់ពួកគេក៏កើតមានឡើង ។ ក្នុងចំនោមបញ្ហាទាំងអស់ បញ្ហាដែលទាក់ទងទៅនឹងបរិស្ថាន បានក្លាយទៅជាបញ្ហាមួយសំខាន់ ។ ជាមួយគ្នានេះដែរក៏មានកើតឡើងនូវកង្វល់ទៅលើ ភាពខុសគ្នានៃប្រាក់ចំនូលនិងភាពក្រីក្រនៅជនបទ ការថែរក្សាសុខភាពនិងអាហារូបត្ថម្ភ អន្តោប្រវេសន៍ពីជនបទទៅកាន់ទីក្រុង ដែលជាមូលហេតុនាំមកនូវបញ្ហាក្នុងការផ្គត់ផ្គង់អោយបានគ្រប់គ្រាន់នូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដ៏ទៃទៀតក្នុងទីក្រុងដ៏ធំនានា ។

ដោយសារតែការកើនឡើងនៃការចាប់អារម្មណ៍ទៅលើ ហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មសង្គមនោះការកសាងផែនការអភិវឌ្ឍន៍នៅក្នុងប្រទេសអាស៊ីជាច្រើន មិនចេះតែបន្តរៀបចំដោយសេដ្ឋវិទូតែឯកឯងនោះឡើយ ។ អ្នកឯកទេសនិងអ្នកសិក្សាស្រាវជ្រាវកាន់តែច្រើនឡើងៗ រួមមាន៖ អ្នកច្បាប់ សង្គមវិទូ វិស្វករ អ្នកឯកទេសបរិស្ថាន ... ។ល។ ត្រូវបានចាត់អោយមកចូលរួមក្នុងដំណើរការកសាងផែនការ អភិវឌ្ឍន៍ ។ នៅប្រទេសមួយចំនួន គេឃើញមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់សមាសភាពនានា ក្នុងសង្គមក្នុងដំណើរការកសាងផែនការ ។ ឧទាហរណ៍ នៅឥណ្ឌូនេស៊ីនិងថៃ ផ្នែកសិក្សាធិការ និងតំនាងសហគមន៍ពាណិជ្ជកម្ម ត្រូវបានអញ្ជើញអោយ មកចូលរួមក្នុងការរៀបចំពង្រាងផែនការអភិវឌ្ឍន៍ជាតិ ។

## ១.៦ ការវិវត្តន៍នៃនយោបាយផែនការអភិវឌ្ឍន៍នៅប្រទេសអាស៊ីមួយចំនួន

### ក) ប្រទេសជប៉ុន

ការកសាងផែនការនៅជប៉ុន បានបង្ហាញនូវវិធីសាស្ត្រកសាងផែនការបែបសេដ្ឋកិច្ចទីផ្សារ។ មិនដូចការកសាងផែនការបែបសេដ្ឋកិច្ចប្រមូលផ្តុំនោះទេ ផែនការរបស់ជប៉ុន គឺជាផែនការមានចរិតជាផែនការបែបណែនាំចង្អុលបង្ហាញ ហើយមិនបានសន្មត់ជាមុននូវអន្តរាគមន៍ខ្លាំងក្លារបស់រដ្ឋាភិបាលទៅក្នុងសកម្មភាពសេដ្ឋកិច្ចឯកជននោះទេ ។ ដូចដែលបានបញ្ជាក់រួចមកហើយ ផែនការសេដ្ឋកិច្ចជប៉ុនមាន អត្ថន័យជាដំណើរការព្រមព្រៀងនៃសង្គម តាមរយៈប្រព័ន្ធការិយាល័យនិយម ។ វាមានជាប់ទាក់ទងជាមួយនិងបន្លាស់ប្តូរពត៌មានជាផ្លូវការ និងមិនផ្លូវការ រវាងវិស័យសាធារណៈនិងផ្នែកឯកជន ។

ទ្រង់ទ្រាយសំខាន់នៃផែនការសេដ្ឋកិច្ចជប៉ុន គឺអនុញ្ញាតិអោយមានភាពទន់ភ្លន់ នៅក្នុងដំណើរការកសាងផែនការ ពីព្រោះរយៈពេលនៃការអនុវត្តន៍កម្មវិធីវិនិយោគសាធារណៈផ្សេងពីគ្នា មិនចាំបាច់ដូចគ្នាទាំងស្រុងជាមួយ និងផែនការសេដ្ឋកិច្ចជាតិនោះទេ ។ កំរិតនៃភាពទន់ភ្លន់នេះ ត្រូវបានផ្តល់អោយទៅកម្មវិធីផ្សេងៗ ក្នុងលក្ខណៈជាការផ្តល់សិទ្ធិនិងការបែងចែកថវិកានៃកម្មវិធីហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ លើសពីនេះទៅទៀត ការប៉ាន់ស្មានទៅលើទស្សនៈវិស័យនៃសេដ្ឋកិច្ចរបស់ប្រទេស និងការឆ្លើយតបនៃផែនការអភិវឌ្ឍន៍ ត្រូវតែធ្វើការកែសំរួលជាប្រចាំ អាស្រ័យទៅតាមការផ្លាស់ប្តូរនៃលក្ខខ័ណ្ឌសេដ្ឋកិច្ច។ លក្ខណៈពិសេសមួយទៀតរបស់ផែនការជប៉ុន គឺតួនាទីរបស់រដ្ឋបាលមូលដ្ឋាន ក្នុងការរៀបចំផែនការអភិវឌ្ឍន៍របស់ខ្លួនគេផ្ទាល់។ ប៉ុន្តែចំនុចគួរអោយចាប់អារម្មណ៍នោះគឺ គ្មានប្រព័ន្ធផ្សារភ្ជាប់ទំនាក់ទំនងរវាងផែនការមូលដ្ឋាន និងផែនការជាតិ ក៏ដូចជារវាងផែនការមូលដ្ឋានមួយ ជាមួយនិងផែនការមូលដ្ឋានផ្សេងទៀត ហើយខួបនៃការកសាងផែនការរវាងផែនការមូលដ្ឋាន ពីរផ្សេងគ្នាក៏អាចខុសគ្នាដែរ ។ គ្មានកិច្ចអន្តរាគមន៍ណាមួយពីរដ្ឋបាលកណ្តាល ក្នុងដំណើរការកសាងផែនការមូលដ្ឋាននៅថ្នាក់មូលដ្ឋាននោះទេ ។

យោងទៅតាមវិធីសាស្ត្រនៃការរៀបចំផែនការ វិធីសាស្ត្រចំរើនជឿនលឿនដែលរួមមាន របៀបគំរូខ្នាតធំនៃអេកូណូម៉េតទ្រិច(**Large-Scale Econometric**) និងប្រព័ន្ធឌីណាមិចអ៊ីនភុត_អៅភុត ត្រូវបានគេយកមកប្រើប្រាស់ ។ ចុងក្រោយនេះ ជប៉ុនកំពុងលេចធ្លោថាជាមេដឹកនាំសេដ្ឋកិច្ចចំបងនៅលើឆាកអន្តរជាតិ បានរៀបចំកសាងរបៀបគំរូចំរុះប្រទេស (Multi-Country Model) ដើម្បីផ្សារភ្ជាប់សេដ្ឋកិច្ចនៃតំបន់អាស៊ីបូព៌ា ។ គេបានទទួលស្គាល់ថា ជប៉ុនមិនអាចបន្តការកសាងរៀបចំផែនការរបស់គេ បានតែក្នុងរង្វង់ការពិភាក្សានិងការព្រមព្រៀងក្នុងស្រុកនោះទេ ហេតុនេះហើយទើបមានការបង្កើនឡើងនូវ តួនាទីរបស់រដ្ឋាភិបាល ក៏ដូចជាទំនាក់ទំនងអន្តរជាតិនានា ដែលកំពុងលេចឡើងផងដែរ ។

## ២) កូរ៉េ

កូរ៉េបានល្បីល្បាញគួរអោយកត់សំគាល់ថាជាឧទាហរណ៍មួយនៃប្រទេសកំពុងអភិវឌ្ឍន៍ ដែលបានទទួលជោគជ័យក្នុងកំណើននិងកិច្ចអភិវឌ្ឍន៍យ៉ាងលឿន តាមរយៈការរៀបចំផែនការអភិវឌ្ឍន៍ដ៏ល្អ ។ បំណងរបស់រដ្ឋាភិបាលក្នុងការធានាអោយមានកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច តាមរយៈការកសាងផែនការ បាននាំមកនូវកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាលយ៉ាងសកម្ម ចាប់តាំងពីផែនការអភិវឌ្ឍន៍ប្រាំឆ្នាំត្រូវបានអនុវត្តនៅក្នុងឆ្នាំ១៩៦២មកម្លេះ ។ នៅចំពោះមុខ រដ្ឋាភិបាលបច្ចុប្បន្ន បន្តដើរតាមអ្វី ដែលគេបានបំពេញរួចទៅហើយនូវទំរង់ផ្សេងៗជាច្រើន សំរាប់ជាមធ្យោបាយទាក់ទាញការវិនិយោគនិងការសន្សំ ក៏ដូចជាការបែងចែកទុនមូលធនបរទេសជាច្រើននិងភាគរយដ៏ខ្ពស់នៃការវិនិយោគដោយរដ្ឋាភិបាល ព្រមទាំងស្ថាប័នធានារបស់រដ្ឋាភិបាលផងដែរ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការវិនិយោគរបស់រដ្ឋាភិបាល បានផ្តោតជាសំខាន់ទៅលើមូលធនចំណាយសង្គម(**Social Overhead Capital**) ហើយរដ្ឋាភិបាល ជាបណ្តើរៗបានបន្ធូរបន្ថយការត្រួតពិនិត្យផ្ទាល់ទៅលើការធ្វើអាជីវកម្មរបស់ផ្នែកឯកជន និងបានរក្សាទុកការបែងចែកធនធានសេដ្ឋកិច្ចជាច្រើន សំរាប់យន្តការទីផ្សារ ។ បើប្រៀបធៀបជាមួយ នឹងសេដ្ឋកិច្ចទីផ្សារនៃប្រទេសអាស៊ីឯទៀត អន្តរាគមន៍របស់រដ្ឋាភិបាលនៅកូរ៉េ នៅមានភាពធំធេងនៅឡើយ នាពេលថ្មីៗនេះ ។ នៅពេលមួយនោះ ទំនោរនៃការគ្រប់គ្រងសេដ្ឋកិច្ចបែបសេរីភាវូនីយកម្មត្រូវបានគ្រប់ដណ្តប់ ដោយសារតែការបង្កើនឡើងនូវអន្តរាគមន៍របស់រដ្ឋាភិបាល ទៅលើឧស្សាហកម្មគីមីនិងឧស្សាហកម្មធុនធ្ងន់ ។ ដូចដែលគេបានដឹងជាទូទៅថា លក្ខណៈពិសេសនៃនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កូរ៉េ គឺជាការខំប្រឹងប្រែងប្រកបដោយមនសិការរបស់ខ្លួន ក្នុងការលើកស្ទួយផលិតកម្មនាំចេញ ហើយទាំងនេះបានទាក់ទងយ៉ាងខ្លាំងដល់ ការពិចារណាអំពីអន្តរាគមន៍របស់រដ្ឋាភិបាល ។

ទ្រង់ទ្រាយពិសេសដែលគួរអោយចាប់អារម្មណ៍របស់ផែនការអភិវឌ្ឍន៍កូរ៉េ រួមមានៈ ការអនុញ្ញាតិជាសំខាន់ពីក្រុមប្រឹក្សាផែនការសេដ្ឋកិច្ច ការប្រើប្រាស់ផែនការប្រចាំឆ្នាំ (ដែលបច្ចុប្បន្នជាផែនការគ្រប់គ្រងសេដ្ឋកិច្ច) ដែលបានផ្សារភ្ជាប់រវាងផែនការប្រាំឆ្នាំ ជាមួយនិងការបែងចែកថវិកាជាក់ស្តែង វត្តមាននៃការិយាល័យផែនការ និងគ្រប់គ្រងនៅតាមក្រសួងនិមួយៗ ដែលទទួលបន្ទុករៀបចំផែនការផ្ទៃក្នុងរបស់ខ្លួន និងសំរបសំរួលសកម្មភាព កសាងផែនការជាមួយក្រុមប្រឹក្សាផែនការសេដ្ឋកិច្ច ព្រមទាំងដំណើរការត្រួតពិនិត្យនៃនាំនិងវាយតំលៃយ៉ាងល្អគ្រប់ជ្រុងជ្រោយ ។

## គ) ចិន

ចិនបានបង្ហាញនូវការចាប់អារម្មណ៍ ក្នុងករណីកែទំរង់ ពីផែនការសេដ្ឋកិច្ចប្រមូលផ្តុំ (ដែលរដ្ឋាភិបាល បានត្រួតពិនិត្យសកម្មភាពសេដ្ឋកិច្ចទាំងមូលយ៉ាងខ្លាំង) ទៅជាសេដ្ឋកិច្ចទីផ្សារ (ដែលការបែងចែកធនធានត្រូវធ្វើឡើងដោយយន្តការទីផ្សារ)។ ចាប់តាំងពីឆ្នាំ១៩៧៨មក ចិនបានដំណើរការផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ចជាច្រើន ។ ប្រទេសនេះបានកែទំរង់យ៉ាងលឿន ពីប្រព័ន្ធផែនការប្រមូលផ្តុំ ឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារ ។ លក្ខណៈពិសេស រួមមាន :

- ការកើនឡើងនៃភាគហ៊ុនរបស់ផ្នែកឯកជននៅក្នុងសេដ្ឋកិច្ច ការកើនឡើងនៃការប្រគល់ផ្តាច់អោយគ្រប់គ្រងជាឯករាជនូវសហគ្រាសសាធារណៈនានា (ស្វយ័តភិបាលសេដ្ឋកិច្ច) ។

- ប្រើប្រាស់យន្តការទីផ្សារ ដើម្បីកំណត់តំលៃទំនិញនិងសេវាកម្ម ដោយរួមបញ្ចូលទាំងចំនួនអ្នកប្រើប្រាស់ជាសារវន្តនិងទំនិញមូលធន ព្រមទាំងការបើកចំហរសេដ្ឋកិច្ច ឆ្ពោះទៅរកពាណិជ្ជកម្មបរទេសកាន់តែច្រើន និងការវិនិយោគទុនបរទេសផ្ទាល់ ។

- វិធីសាស្ត្រនិងប្រព័ន្ធកសាងផែនការ បានដំណើរការកែទំរង់គួរអោយកត់សំគាល់ ដោយបានឆ្លុះបញ្ចាំងពីការកាត់បន្ថយព្រំដែនប្រតិបត្តិការនៃអាណត្តិរបស់ផែនការ ហើយបានបង្កើននៅក្នុងនោះនូវរបៀបជាផែនការចង្អុលបង្ហាញឬជាផែនការណែនាំ ។

- ប្រើប្រាស់សន្ទស្សន៍តំលៃជំនួសអោយសន្ទស្សន៍សំភារៈ សំរាប់បញ្ចូលទុនសំភារៈទៅក្នុងផលិតកម្មសំខាន់ៗ ព្រមទាំងប្រើប្រាស់ប្រព័ន្ធ "កិច្ចសន្យាទទួលខុសត្រូវ" ចំពោះការវិនិយោគទុននិងផលិតកម្ម ។

ទោះជាយ៉ាងណាក៏ដោយ ការត្រួតពិនិត្យរបស់រដ្ឋនៅតែគ្រប់ដណ្តប់ទៅលើសកម្មភាពផ្សេងៗ នៅពេលណាដែលគេយល់ថា យន្តការទីផ្សារមិនមានលក្ខណៈគ្រប់គ្រាន់ សំរាប់បំពេញអោយលក្ខខ័ណ្ឌ "តំរូវការ_ផ្គត់ផ្គង់"។ ទាំងនោះរួមមាន: ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការបង្កើតឡើងនូវស្ថាប័នសុខមាលភាពសង្គមនិងសាធារណៈ ឧស្សាហកម្មទាក់ទងនិងការពារជាតិ និងឧស្សាហកម្មដែលរដ្ឋាភិបាលយល់ថាមានសារៈសំខាន់សំរាប់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចយូរអង្វែង និងដើម្បីស្ថេរភាពសេដ្ឋកិច្ច ។

ផែនការអភិវឌ្ឍន៍ បានសង្កត់ធ្ងន់ទៅលើការបង្កើនជាបណ្តើរៗនូវការផ្លាស់ប្តូរ ពីការបង្កើតនិទស្សន៍ត្រួតពិនិត្យនិងអនុម័តគំរោង រួមទាំងការបែងចែកទុនវិនិយោគនិងសំភារៈ អោយទៅជាការវិភាគទីផ្សារនិងទំនោរសេដ្ឋកិច្ច ក៏ដូចជាការរៀបចំការស្រាវជ្រាវទៅលើជំរើសគោលនយោបាយផ្សេងៗ ។ រដ្ឋាភិបាលចិនបានបង្កើនការប្រើប្រាស់ជាបន្ទាន់ នូវឧបករណ៍នយោបាយសេដ្ឋកិច្ចជាប្រពៃណី ដើម្បីមានឥទ្ធិពលទៅលើបំរែបំរួលកត្តាសេដ្ឋកិច្ចជាច្រើន ដូចជា អត្រាការប្រាក់និងតំលៃ ជំនួសអោយការរៀបចំអាជ្ញាធរកសាង

ផែនការកណ្ដាលមួយ ដើម្បីត្រួតពិនិត្យរចនាសម្ព័ន្ធសេដ្ឋកិច្ចនិងទំរង់ការផលិតកម្ម ។ វិធីសាស្ត្របរិមាណ ដែលបានប្រើនៅក្នុងការកសាងផែនការអភិវឌ្ឍន៍ បានដំណើរការផ្លាស់ប្ដូរនិងកែលំអរកាន់តែប្រសើរឡើង គួរអោយកត់សំគាល់នៅប្រទេសចិន ។

## ឃ) ឥណ្ឌា

ចាប់តាំងពីដំបូងមកម្លេះ គោលដៅចំបងបំផុតនៃរាល់ផែនការឥណ្ឌា គឺ ទី(១)បង្កើនប្រាក់ចំណូលប្រចាំឆ្នាំរបស់ប្រជាជនម្នាក់ៗ និងបង្កើនកំរិតជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ និង ទី(២) កាត់បន្ថយការពឹងផ្អែកកំលាំងខាងក្រៅនៃសេដ្ឋកិច្ចរបស់ខ្លួន ក្រោមទស្សនៈនៃការជឿជាក់លើខ្លួនឯង ។ ដោយជាប្រទេស ដែលបានចាប់ផ្ដើមពីហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាមូលដ្ឋានឧស្សាហកម្មស្ទើរសូន្យ ជំរើសរបស់អ្នកកសាងផែនការ បានដំណើរការទៅតាមចំណូលចិត្តនៃការកសាងផែនការតាមបែបសូវៀត។ យុទ្ធសាស្ត្រនៃការកសាងផែនការបែបនេះ បានផ្ដល់អោយវិស័យសាធារណៈនូវ តួនាទីបញ្ជា ដោយយោងទៅលើមូលដ្ឋានគ្រឹះនៃអំណះអំណាងស្ដីពី“ឧស្សាហកម្មកើតថ្មី” ។ ជំរើសបែបនេះ បាននាំមកនូវការយកពន្ធលើទំនិញនាំចេញនាំចូលយ៉ាងធ្ងន់ធ្ងរ ព្រមទាំងបានការពារបរិមាណទំនិញឧស្សាហកម្មឥណ្ឌា និងសកម្មភាពសេដ្ឋកិច្ចដ៏ទៃទៀត ។ ទោះបីជារបៀបគំរូនៃការកសាងផែនការឥណ្ឌា បានផ្ដួចផ្ដើមឡើងស្រដៀងគ្នាទៅនិងបែបផែនសូវៀតក៏ដោយ ក៏បច្ចុប្បន្ន គេបានផ្ដោតអារម្មណ៍ទៅលើ សេដ្ឋកិច្ចចំរុះ ជាមួយនិងការសន្មតថានៅទីណាដែលផ្នែកឯកជនអាចប្រតិបត្តិការយ៉ាងមានប្រសិទ្ធភាព ទីនោះ វិស័យសាធារណៈមិនចាំបាច់ធ្វើអន្តរាគមន៍ឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការដាក់កំរិតលក្ខខ័ណ្ឌទៅលើគុណភាពនិងបរិមាណ នៅក្នុងផ្នែកឯកជន ដែលបានប្រើប្រាស់ដោយរដ្ឋាភិបាល បានធ្វើអោយមានភាពធ្ងន់ធ្ងរ ការប្រតិបត្តិត្រូវស្ថិតនៅក្រោមអាជ្ញាប័ណ្ណ(ប្រតិវេទ) និងមានកំរិតលើការនាំចូល ការត្រួតត្រាលើសារពើពន្ធ និងឥណទាន ។

នៅដើមឆ្នាំ១៩៧០អ្នកកសាងផែនការបានដឹងថា ផលប្រយោជន៍នៃការលូតលាស់និងកិច្ចអភិវឌ្ឍន៍នៅក្នុងផែនការ មិនបានជ្រាបទៅដល់ប្រជាជនក្រីក្រ ដោយស្វ័យប្រវត្តិនោះទេ។ ទាំងនេះនាំអោយលេចមានឡើងនូវវិធានការកែតំរូវនិងវិធានការជាក់លាក់ផ្សេងៗ ដែលត្រូវបានយល់ព្រមទទួលយក ចាប់តាំងពីផែនការលើកទីប្រាំតទៅ ។ វិធានការទាំងនោះមានលក្ខណៈជាកិច្ចអន្តរាគមន៍ផ្ទាល់របស់វិស័យសាធារណៈ ក្នុងទំរង់ជាគំរោងនិងកម្មវិធីនានា សំដៅឆ្ពោះទៅរកប្រជាជនគោលដៅ។ ទោះជាយ៉ាងណាក៏ដោយ ក៏គេបានដឹងក្រោយមកទៀតថា យុទ្ធសាស្ត្របែងចែកសារជាថ្មីតែឯង មិនអាចដោះស្រាយបញ្ហាក្រីក្របានឡើយ លើកលែងតែវិធានការទាំងនោះ បានប្រែក្លាយជាប្រការដែលមិនគ្រាន់តែជា“ការផ្ទេរការប្រើប្រាស់” ពីក្រុមមួយទៅ

ក្រុមមួយទៀត ប៉ុន្តែថែមទាំងបាននាំមកជាមួយនូវការបន្ថែមសន្និធិទ្រព្យធន(Stock of Assets) ដល់ជនក្រីក្រជាងគេ និងដល់ក្រុមជនងាយរងគ្រោះនានានៅក្នុងសង្គម ។ ហេតុនេះ រដ្ឋាភិបាលបានផ្តួចផ្តើមឡើងនូវគ្រោងការមួយចំនួនធំ សំរាប់បង្កើនផលិតភាពនៃមូលធននិងកំលាំងពលកម្ម ដោយកែលំអរបច្ចេកវិទ្យាកែលំអរកិច្ចគ្រប់គ្រងចាត់ចែងនិងនិតិវិធីគ្រប់គ្រងនៅក្នុងប្រព័ន្ធផលិតកម្ម ។ ប៉ុន្តែ ទោះជានៅក្នុងដំណាក់កាលនេះក៏ដោយ ក៏វិធានការកែតំរូវនៅត្រូវបានគេកំណត់ព្រំដែនភាគច្រើន នៅក្នុងសកម្មភាពផ្ទាល់នៃវិស័យសាធារណៈ ។

នៅទីបំផុត ទិដ្ឋភាពទាំងនេះបាននាំមកនូវទំរង់នៃគោលនយោបាយមួយឆ្ពោះទៅរកការរីកចំរើន ដោយផ្អែកទៅលើសេរីភាវូបនីយកម្ម ការមិនត្រួតត្រាតំលៃទំនិញ និងការចូលរួមរបស់ផ្នែកឯកជន។ នេះគឺជាការឆ្លុះបញ្ចាំង អោយឃើញនូវខ្សែបន្ទាត់នៃគំនិតផ្តួចផ្តើមនូវកំណែទំរង់សេដ្ឋកិច្ច ដែលបានកើតឡើងចាប់តាំងពីឆ្នាំ១៩៧៧_៧៨ ហើយដែលបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ចាប់តាំងពីឆ្នាំ១៩៨៤_៨៥ ដោយរដ្ឋាភិបាល រ៉ាហ្ស៊ី គន្ធី នាពេលនោះ ។ ប៉ុន្តែ នៅក្នុងការប៉ុនប៉ងដើម្បីសេរីភាវូនីយកម្ម នោះសារៈសំខាន់នៃការរក្សាលំនឹងម៉ាក្រូសេដ្ឋកិច្ចក្រៅស្រុកនិងក្នុងស្រុក និងបញ្ហាសងបំណុលជំពាក់ នៅមិនទាន់ត្រូវបានដោះស្រាយអោយសមស្រប ។ រដ្ឋាភិបាល បានប្រើប្រាស់កំចីពាណិជ្ជកម្ម និងការដកយកប្រាក់ដោយគ្មានសុភវិនិច្ឆ័យ ចេញពីប្រាក់បំរុងសំរាប់ការប្តូរប្រាក់បរទេសរបស់ជាតិ ទៅបំពេញអោយចន្លោះខ្វះខាតប្រើប្រាស់ដ៏ធំ ដែលមានជាពិសេសនៅក្នុងវិស័យសាធារណៈ។

នាដើមឆ្នាំ១៩៩០ គណបក្សសមាជជាតិបានកាន់កាប់រដ្ឋាភិបាល ដែលគេបានជួបប្រទះឃើញមានវិបត្តិថវិកាយ៉ាងធ្ងន់ធ្ងរនៅឥណ្ឌា និងជាលើដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសនេះ ។ ឥណ្ឌាបានជួបប្រទះនឹងការប្រថុយគ្រោះថ្នាក់នៃការគ្មានលទ្ធភាពសងបំណុលបរទេសដែលមានពីមុនមក ។ ដើម្បីទប់ទល់និងសភាពការណ៍នេះ រដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីសេរីភាវូនីយកម្មដ៏ធំមួយ និងបានស្វែងរកជំនួយគាំទ្រពីមូលនិធិរូបិយប័ណ្ណអន្តរជាតិ(IMF) និងធនាគារពិភពលោក ក្រោមលក្ខខ័ណ្ឌតំរូវអោយកែសំរួលរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ ។ ចាប់ពីពេលនោះមក នយោបាយកែទំរង់ដែលបានអនុវត្តដោយរដ្ឋាភិបាលឥណ្ឌាមានជាអាទិ ការបញ្ចុះតំលៃរូបិយប័ណ្ណ ការកាត់បន្ថយឱនភាពសារពើព័ន្ធ (ចំណាយច្រើនជាងចំណូល) ការកែទំរង់ពាណិជ្ជកម្មសំខាន់ៗ បង្កើនការលើកទឹកចិត្តដល់ការវិនិយោគទុនបរទេសផ្ទាល់ ការចាត់វិធានការនានាទាក់ទងទៅនិងការជំរុញប្រសិទ្ធភាពវិស័យសហគ្រាសសាធារណៈ និងការបង្កើនតួនាទីរបស់ផ្នែកឯកជន (ឯកជនភាវូនីយកម្ម) ការទទួលយកកម្មវិធីបណ្តាញនិរភ័យ ។ល។ ដើម្បីជួយដល់អ្នកទន់ខ្សោយនៅក្នុងសង្គម ។ កម្មវិធីទាំងអស់នេះ បានតំរង់ជាបឋមឆ្ពោះទៅរក គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដោយផ្តោត

ជាសំខាន់ទៅលើសកម្មភាពរដ្ឋបាលថ្នាក់កណ្តាល ។ ប៉ុន្តែដោយសារ តែបញ្ហាវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរបានកើតឡើងចាប់តាំងពីមុនពេលឡើងកាន់អំណាចមកម្លេះ នោះទោះជាយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលមិនបានយកចិត្តទុកដាក់អោយបានពេញទំហឹងទៅលើដំណើរការកែទំរង់សេដ្ឋកិច្ចទូទៅ ដែលចាំបាច់អោយមានលទ្ធភាពផ្លាស់ប្តូររចនាសម្ព័ន្ធនានា ដើម្បីរក្សានិរន្តភាពសេដ្ឋកិច្ច និងដើម្បីប្រែក្លាយគោលនយោបាយមួយសមស្របអាចអោយគេទទួលយកបាននៅឡើយទេ។ គេពិបាកនិងយល់បានណាស់អំពីតួនាទីនៃការងារកសាងផែនការនៅក្នុងបរិបទបែបនេះ ។ នៅក្នុងដំណើរការសេរីភាវូបនីយកម្ម ការឆ្លើយតបទៅនឹងសញ្ញានៃទីផ្សារនានានៅក្នុងដំណើរប្រព្រឹត្តិទៅជាសកល នោះសេដ្ឋកិច្ចកាន់តែមានសកម្មភាពរស់រវើកទៅទៀត ។ នៅក្នុងបរិបទនេះ ការកសាងផែនការ ត្រូវតែមានការផ្លាស់ប្តូរតួនាទីជាសំខាន់ពីការអនុវត្តន៍បែបគណនេយ្យ ទៅជាការអនុវត្តន៍ជាក់ស្តែងបែបទេពកោសល្យសេដ្ឋកិច្ចពិតប្រាកដ ។

## ខ) នេប៉ាល

ក៏ដូចជាឥណ្ឌាដែរ យុទ្ធសាស្ត្រអភិវឌ្ឍន៍និងនយោបាយសេដ្ឋកិច្ចនៅនេប៉ាលបច្ចុប្បន្ន កំពុងមានការផ្លាស់ប្តូរយ៉ាងលឿន ។ វិធីសាស្ត្រកសាងផែនការអភិវឌ្ឍន៍ ត្រូវបានគេយកទៅប្រើប្រាស់នៅនេប៉ាលនាឆ្នាំ១៩៥៩ ។ មុនឆ្នាំ១៩៧០ គេមានការផ្តោតអារម្មណ៍ជាសំខាន់ទៅលើ ការកសាងហេដ្ឋារចនាសម្ព័ន្ធដែលពេលនោះវិស័យ ដឹកជញ្ជូនបានទទួលអាទិភាពខ្ពស់បំផុតនៅក្នុងផែនការអភិវឌ្ឍន៍។ ក្រោយមកគេបានដឹងថា ការផ្តោតការយកចិត្តទុកដាក់ខ្លាំងពេកទៅលើហេដ្ឋារចនាសម្ព័ន្ធ បាននាំមកនូវការមិនអើពើរទៅលើសារៈសំខាន់នៃការវិនិយោគឯកជន ដែលជាហេតុនាំអោយផលិតផលសេដ្ឋកិច្ចលូតលាស់តិច និងបានជះឥទ្ធិពលមិនល្អទៅលើកិច្ចអភិវឌ្ឍនីវិស័យកសិកម្ម ។ ចាប់តាំងពីផែនការប្រាំឆ្នាំលើកទីប្រាំ(១៩៧០_៧៥) មកកំណើនផលិតផលនិងការបង្កើនការងារ បានទទួលអាទិភាពខ្ពស់ជាងគេនៅក្នុងផែនការអភិវឌ្ឍន៍ ។ កិច្ចអភិវឌ្ឍន៍កសិកម្ម និងការបំពេញសេចក្តីត្រូវការជាមូលដ្ឋានរបស់ប្រជាជន ក៏ត្រូវបានគេលើកឡើងផង ដែរ ។ ដូចករណីនៅឥណ្ឌាដែរ គេបានដឹងថា វិធីសាស្ត្រអភិវឌ្ឍន៍ពីលើចុះក្រោម បានដើរវៀងក្រុមជនក្រីក្រនៅក្នុងសង្គម ហើយក៏នៅមានវិធានការជាច្រើនដែលត្រូវទទួលយក ដើម្បីជួយកាត់បន្ថយភាពក្រីក្រ។

កិច្ចអភិវឌ្ឍន៍តំបន់ក៏ត្រូវបានគេលើកឡើងដែរ។ នៅក្នុងឆ្នាំ១៩៨០ នៅពេលដែលរដ្ឋាភិបាលនេប៉ាលកំពុងតែបន្តផ្តល់ការផ្តោតការយកចិត្តទុកដាក់ទៅលើកិច្ចអភិវឌ្ឍន៍កសិកម្ម និងតំបន់ គេក៏បានចាប់ផ្តើមយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើវិស័យឧស្សាហកម្មផងដែរ។ គេបានចាប់អារម្មណ៍ទៅលើការជំរុញការនាំចេញទេសចរណ៍ និងឧស្សាហកម្មខ្នាតតូច ។ តួនាទីរបស់ផ្នែកឯកជននៅក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច កំពុងត្រូវ

បានគេទទួលស្គាល់ជាបណ្តើរៗ។ វិធានការមួយចំនួនក៏ត្រូវបានធ្វើឡើងរួចទៅហើយ នាពេលថ្មីៗនេះ ដើម្បីសំដៅឆ្ពោះទៅរកសេរីភាវូបនីយកម្ម និងការមិនត្រួតពិនិត្យតំលៃទំនិញ ។

គេបានកត់សំគាល់ថា នៅនេប៉ាល គណៈកម្មការកសាងផែនការ ពីមុនមកត្រូវបានគេរៀបចំសារចុះសារឡើងជាញឹកញយ ប្រយោជន៍ដើម្បីស្វែងរករូបមន្តដែលសមស្របបំផុតសំរាប់ប្រទេសនេះ ។ លក្ខណៈពិសេសគួរអោយចាប់អារម្មណ៍នៅនេប៉ាល គឺការបង្កើតជាការិយាល័យប្រចាំតំបន់ចំនួនប្រាំ ក្រោមការគ្រប់គ្រងរបស់ស្នងការផែនការ (**Planning Commission**) សំរាប់ពិនិត្យឡើងវិញនិងត្រួតត្រាមើល គំរោងដែលបានអនុវត្តដោយក្រសួងផ្សេងៗនៅក្នុងតំបន់ទាំងនោះ និងជួយអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំផែនការថ្នាក់មូលដ្ឋានតាមខ្លួបកំណត់ ។ ហេតុនេះ ការិយាល័យតំបន់ទាំងនេះ ត្រូវបំពេញតួនាទីសំរបសំរួលរវាងស្នងការផែនការនិងក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តអោយមានប្រសិទ្ធភាពនូវកម្មវិធីថ្នាក់មូលដ្ឋាន ។

លើផ្នែកបច្ចេកទេសកសាងផែនការ គេបានកត់សំគាល់ឃើញថា គ្មានអ្វីដែលបានធ្វើអោយកាន់តែប្រសើរឡើងឡើយ ក្នុងកំឡុងពេលប៉ុន្មានឆ្នាំនេះ ។ តែទោះជាយ៉ាងណាក៏ដោយ ម៉ាក្រូសេដ្ឋកិច្ចចំរុះ និងរបៀបគំរូអ៊ីនភុត_អៅភុត ត្រូវបានគេយកទៅប្រើប្រាស់នាពេលថ្មីៗនេះ។ ការសិក្សាដោយយកចិត្តទុកដាក់នូវបច្ចេកទេសកសាងផែនការអភិវឌ្ឍន៍ ដែលបានប្រើប្រាស់នៅក្នុងប្រទេសដ៏ទៃទៀត អាចមានអត្ថប្រយោជន៍ចំពោះនេប៉ាល ក្នុងការឆ្ពោះទៅរកការបង្កើនគុណភាពនៃការកសាងផែនការអភិវឌ្ឍន៍របស់ខ្លួន ។

## ច) អាស៊ាន

ទោះបីជាមានភាពខុសគ្នាអំពីទំហំ និងអំណោយផលធនធានធម្មជាតិក៏ដោយ ក៏ប្រទេសអាស៊ានបានប្រើប្រាស់យុទ្ធសាស្ត្រស្រដៀងគ្នា ក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន ។ វាគឺជាយុទ្ធសាស្ត្រសេដ្ឋកិច្ចទីផ្សារទាំងស្រុង ដែលទីនោះពាណិជ្ជកម្មនិងវិនិយោគទុនបរទេស មានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់គេ។ គេទាំងអស់បានទទួលជោគជ័យ ក្នុងការដឹកនាំឆ្ពោះទៅរកមាគ៌ាឧស្សាហូនីយកម្ម និងបានផ្លាស់ប្តូរយុទ្ធសាស្ត្រពីការនាំចូលបន្ថែម ទៅជាការពង្រីកការនាំចេញ ។ លើកលែងតែសឹង្ហបូរីមួយចេញ ផែនការអភិវឌ្ឍន៍បានដើរតួនាទីដ៏សំខាន់ក្នុងចំនោមប្រទេសអាស៊ានទាំងអស់ ។ ទោះជាប្រទេសអាស៊ានជាច្រើន មិនបានអនុវត្តតាមយ៉ាងហ្មតចត់នូវអ្វី ដែលគេបានសរសេរក្នុងផែនការអភិវឌ្ឍន៍ក៏ពិតមែន តែបើពិនិត្យអោយបានជិតដល់ទៅលើផែនការអភិវឌ្ឍន៍របស់ប្រទេសអាស៊ាន ក្នុងកំឡុងពេលបីទសវត្សចុងក្រោយនេះ នោះគេឃើញមានការផ្លាស់ប្តូរយ៉ាងរស់រវើកជាបន្តបន្ទាប់ ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់គេ ។

ក្នុងចំនោមប្រទេសអាស៊ានទាំងប្រាំ ដែលបានលើកយកមកពិភាក្សានៅពេលនេះ ប្រទេសឥណ្ឌូនេស៊ី ជាប្រទេសមួយ ដែលមានប្រជាជនច្រើនជាងគេ ប៉ុន្តែប្រាក់ចំណូលប្រចាំឆ្នាំរបស់ប្រជាជនម្នាក់ៗទាបជាងគេបំផុត ។ ប៉ុន្តែ ប្រទេសនេះបានឆ្លងកាត់អត្រាកំណើនសេដ្ឋកិច្ចជាទីសង្ឃឹម ពីមួយឆ្នាំទៅមួយឆ្នាំ ដោយបានបង្កើនកំរិតជីវភាពរស់នៅរបស់ប្រជាជនជាច្រើន ។ ក៏ដូចប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនដែរ ផែនការដំបូងបំផុតរបស់ឥណ្ឌូនេស៊ី បានសង្កត់ធ្ងន់ទៅលើការកសាងឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ។ គេឃើញមានផងដែរនូវការត្រួតពិនិត្យយ៉ាងតឹងរឹងរបស់រដ្ឋាភិបាល ទៅលើផ្នែកសំខាន់ៗនៃសេដ្ឋកិច្ច ដូចជាវិស័យប្រេងឥន្ធនៈនិងធនាគារ ។ នៅក្នុងរយៈពេលមានផែនការទីបី(១៩៧០-១៩៨៤) បញ្ហារបាយប្រាក់ចំនូលអសមភាពនិងអតុល្យភាពតំបន់ ត្រូវបានគេលើកឡើង ។ គេបានទទួលស្គាល់នូវតួនាទីគ្របដណ្តប់មិនអាចមាននិរន្តភាពបានរបស់វិនិយោគទុនសាធារណៈ ហើយឥរិយាបទនិងវិធីសាស្រ្តថ្មីត្រូវបានប្រើប្រាស់ដើម្បីជំរុញការវិនិយោគឯកជន ។ ក្នុងកំឡុងឆ្នាំ ១៩៨០ វិធានការជាគោលនយោបាយសំខាន់ៗត្រូវបានអនុវត្តសំដៅទៅរកការមិនត្រួតពិនិត្យថ្លៃទំនិញ និងសេរីភាវូបនីយកម្មវិស័យហិរញ្ញវត្ថុរបស់ប្រទេសនេះ ។ សេដ្ឋកិច្ចឥណ្ឌូនេស៊ី ត្រូវបានរងឥទ្ធិពលយ៉ាងខ្លាំង ដោយលក្ខខ័ណ្ឌនានានៅក្នុងវិស័យប្រេងឥន្ធនៈ ។ ប៉ុន្តែប្រទេសនេះមានលទ្ធភាពកាត់បន្ថយការពឹងផ្អែកលើប្រេងឥន្ធនៈ ជាបណ្តើរៗ ហើយការនាំចេញផលិតផលឧស្សាហកម្មបានពង្រីកយ៉ាងឆាប់រហ័សនាពេលថ្មីៗនេះ ។

នៅឥណ្ឌូនេស៊ី គេមានគោលនយោបាយរដ្ឋាភិបាល ក្នុងការបញ្ចូលគំនិតនិងសំណើរគំរោងពីគ្រប់មជ្ឈដ្ឋាននៃសង្គមទៅក្នុងផែនការអភិវឌ្ឍន៍ ។ ពង្រាងផែនការអភិវឌ្ឍន៍ជាតិ មិនត្រឹមតែត្រូវបានគេផ្ញើទៅកាន់ការិយាល័យឬស្ថាប័នសាធារណៈប៉ុណ្ណោះទេ តែថែមទាំងផ្ញើទៅកាន់សមាគម ផ្នែកឯកជន វិទ្យាស្ថានសិក្សា និងអង្គការជំនាញផ្សេងៗ ដើម្បីស្វែងរកយោបល់កែលំអរនិងសំណើរតបមកវិញ។ ការផ្លាស់ប្តូរយុទ្ធសាស្រ្តអភិវឌ្ឍន៍ប្រទេសនិងគោលនយោបាយ ត្រូវបានទទួលរងឥទ្ធិពលមួយចំនួន ទោះតិចឬច្រើនក៏ដោយ ដោយសារកិច្ចពិភាក្សាដែលបានធ្វើឡើងនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ ។

ផែនការអភិវឌ្ឍន៍នៅប្រទេសម៉ាឡេស៊ី មានបួនប្រភេទផ្សេងៗគ្នា អាស្រ័យទៅតាមរយៈពេលនៃការកសាងផែនការ ដូចជា "ផែនការគ្រោងទស្សនៈយូរអង្វែង"(Outline Perspective Plan) "ផែនការប្រាំឆ្នាំ" "ការពិនិត្យពាក់កណ្តាលខួប"(ការកែសំរួល)នៃផែនការប្រាំឆ្នាំ និង"ថវិកាប្រចាំឆ្នាំ"។ បញ្ហាគោលនយោបាយសំខាន់ៗនៅម៉ាឡេស៊ី គឺការលុបបំបាត់អតុល្យភាពរវាងប្រជាជន ដែលមានជាតិសាសន៍ខុសៗគ្នា ក្នុងការទទួលយកឱកាសសេដ្ឋកិច្ចនិងសុខុមាលភាព ។ "កំណើននិងសមធម៌" ត្រូវបានគេសង្កត់ធ្ងន់នៅក្នុងផែនការអភិវឌ្ឍន៍ប្រទេស ។ នៅក្នុងឆ្នាំ១៩៧១ គោលនយោបាយសេដ្ឋកិច្ចថ្មី ត្រូវបានគេប្រកាស

ផ្សព្វផ្សាយអោយប្រើប្រាស់ ដោយទទួលស្គាល់បញ្ហានិងតំរូវការនៃសង្គមជាតិសាសន៍ចំរុះនៅម៉ាឡេស៊ី។ ចាប់តាំងពីពេលនោះមក វិធានការជាគោលនយោបាយជាច្រើន ត្រូវបានប្រើប្រាស់ដើម្បីកាត់បន្ថយភាពក្រីក្រនិងពង្រីកសេដ្ឋកិច្ចអោយកាន់តែខ្លាំងក្លា មានទាំងការបង្កើនថានៈសង្គមនៃបូមីពុត្រា(Bumiputera) ដែលទទួលបានលទ្ធផលយ៉ាងល្អប្រសើរ។ នាពេលថ្មីៗនេះ ការផ្តោតអារម្មណ៍បានផ្តល់ទៅលើកិច្ចអភិវឌ្ឍន៍ធនធានមនុស្ស ការប្រើប្រាស់កាន់ច្រើននូវវិទ្យាសាស្រ្តនិងបច្ចេកវិជ្ជា និងការអូសទាញអោយផ្នែកឯកជនចូលរួមក្នុងកិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។

ហ្វីលីពីន គឺជាប្រទេសទីមួយក្នុងអាស៊ាន ដែលបានចាប់ផ្តើមកសាងផែនការអភិវឌ្ឍន៍មុនគេ ។ ផែនការអភិវឌ្ឍន៍ផ្លូវការទី១ បានចាប់ផ្តើមដំបូងបំផុតនៅឆ្នាំ១៩៣៥ ជាមួយនិងការបង្កើតឡើងនូវក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(NEC)។ ស្ថាប័ននិងយន្តការកសាងផែនការនៅហ្វីលីពីន បានធ្វើការផ្លាស់ប្តូរជាសំខាន់ ពីមួយឆ្នាំទៅមួយឆ្នាំ។ ចាប់តាំងពីឆ្នាំ១៩៧២ ភ្នាក់ងារកសាងផែនការទាំងអស់ ត្រូវបានសំរបសំរួលរួមបញ្ចូលគ្នាអោយទៅជាគណៈកម្មការកសាងផែនការមួយ ហៅថា អាជ្ញាធរអភិវឌ្ឍន៍និងសេដ្ឋកិច្ចជាតិ (National Economic and Development Authority = NEDA) ដែលបានក្លាយជាស្ថាប័នថ្នាក់កណ្តាលសំរាប់ការកសាងនិងអនុវត្តផែនការអភិវឌ្ឍន៍ជាតិនៅហ្វីលីពីន ។ ក៏ដូចជាប្រទេសអាស៊ានដ៏ទៃទៀតដែរ ផែនការអភិវឌ្ឍន៍ជាតិ បានផ្តល់នូវក្របខ័ណ្ឌគោលនយោបាយ និងតួលេខគោលដៅសេដ្ឋកិច្ចនានា ប៉ុន្តែមិនបានផ្តល់នូវការណែនាំអនុវត្តន៍លំអិតនោះទេ ។ ទ្រង់ទ្រាយពិសេសនៃយន្តការកសាងផែនការនៅហ្វីលីពីន គឺជាការអនុវត្តន៍តាមការសំរេចចិត្តសំខាន់ៗ ដោយគណៈកម្មការអន្តរៈស្ថាប័ន ។ ក្រុមប្រឹក្សា**NEDA** ត្រូវបានដឹកនាំដោយប្រធានាធិបតី ហើយសមាសភាពនៃសមាជិកក្រុមប្រឹក្សានេះ ត្រូវបានជ្រើសរើសមកពីសមាជិកខុទ្ទកាល័យនិងមន្រ្តីប្រតិបត្តិនានា ដែលជាថ្នាក់ដឹកនាំនាយកដ្ឋានផ្សេងៗ សំរាប់ទទួលខុសត្រូវអនុវត្តផែនការអភិវឌ្ឍន៍ ។ ក្រុមប្រឹក្សានេះ ត្រូវបានចូលរួមជាជំនួយបន្ថែមទៀតដោយគណៈកម្មការអន្តរៈស្ថាប័នកំរិតខុទ្ទកាល័យ ។ ក្នុងចំនោមនោះ មានគណៈកម្មការសំរបសំរួលថវិកាអភិវឌ្ឍន៍ ដែលជាអ្នកកំណត់និងបែងចែកថវិកាអភិវឌ្ឍន៍របស់រដ្ឋាភិបាល និងបំពេញតួនាទីជាអ្នកផ្សារភ្ជាប់ស្ថាប័នកសាងផែនការ ជាមួយនិងស្ថាប័នចាត់ចែងថវិកា ។

ផែនការអភិវឌ្ឍន៍ហ្វីលីពីននាដើមឆ្នាំ១៩៧០ បានផ្តោតជាសំខាន់ទៅលើការប្រើប្រាស់យន្តការទីផ្សារនៅក្នុងសកម្មភាពសេដ្ឋកិច្ចនិងតួនាទីនៃផ្នែកឯកជន ដែលជាអ្នកជំរុញចលនាអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏ល្អបំផុត ។ ទិសដៅនានាដែលបានដាក់ចេញ គឺសំដៅទៅរកកំណើនសេដ្ឋកិច្ច ការបង្កើនមុខរបរ សមធម៌ យុត្តិធម៌សង្គម និងកិច្ចអភិវឌ្ឍន៍តំបន់។ ថ្មីៗនេះដោយសារលទ្ធផលនៃអស្ថេរភាពសេដ្ឋកិច្ចនិងកំណើនសេដ្ឋកិច្ចទាប

ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៨០មក គេបានផ្តោតការចាប់អារម្មណ៍ជាសំខាន់ទៅលើការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច កិច្ចអភិវឌ្ឍន៍ជនបទ តំបន់ និងឧស្សាហកម្ម ជាមួយនិងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដោយរដ្ឋាភិបាល ។ ការបង្កើតឡើងនូវមូលដ្ឋានឧស្សាហកម្ម អោយកាន់តែមានប្រសិទ្ធភាព ក៏ដូចជារចនាសម្ព័ន្ធសេដ្ឋកិច្ច បានដំណើរការតាមរយៈសេរីភាវូបនីយកម្ម និងការបង្កបរិយាកាសប្រកួតប្រជែងទីផ្សារអោយកាន់តែខ្លាំងផងដែរ ។ នៅក្នុងស្ថានភាពមានវិបត្តិយ៉ាងខ្លាំងនៃធនធានហិរញ្ញវត្ថុ ផែនការអភិវឌ្ឍន៍នាពេលនោះ ត្រូវបានសាកល្បងផ្តល់សំរាប់តំរូវការចំរុះ ដែលកំពុងស្ថិតក្រោមបញ្ហាវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរ។

ក្នុងចំនោមប្រទេសអាស៊ាន <u>សិង្ហបូរី</u> បានចាត់ទុកផែនការអភិវឌ្ឍន៍ជា<u>ការមិនសំខាន់</u> ។ លោកបណ្ឌិត **Goh Keng Swee** ដែលជាស្ថាបត្យករសេដ្ឋកិច្ចដ៏ល្បីល្បាញនៅសិង្ហបូរី គឺជាអ្នកដែលជួយរៀបចំសិង្ហបូរីពីសេដ្ឋកិច្ចបែបឃ្លាំងស្តុកទំនិញ(**Entrepôt**) អោយសំរេចបានទៅជាទីក្រុងរដ្ឋនៃឧស្សហ_សេវាកម្ម ដែលគេបានគិតថា គោលនយោបាយសេដ្ឋកិច្ចមានសារៈសំខាន់ជាង ហើយផែនការអភិវឌ្ឍន៍ក៏ពុំសូវមានតំលៃដែរ ។ ទស្សនៈយល់ឃើញនេះ បានកើតមានឡើងជាទូទៅ នៅក្នុងរង្វង់រដ្ឋាភិបាលសិង្ហបូរី ដែលបានដឹកនាំដោយគណបក្សសកម្មភាពប្រជាជន រហូតមកទល់សព្វថ្ងៃ ។ អត្ថន័យសំខាន់នៃផែនការអភិវឌ្ឍន៍ទី១នាឆ្នាំ១៩៦០ គឺការកសាងឡើងវិញនូវសេដ្ឋកិច្ចអោយចេញផុតពីសកម្មភាពស្តុកទំនិញ ទៅជាវិស័យឧស្សាហកម្មប្រកបដោយថាមពល ដែលជាមធ្យោបាយមួយក្នុងការដោះស្រាយបញ្ហាអត់ការងារធ្វើដ៏ធំសំបើមនោះ ។ សិង្ហបូរី បានប្រើប្រាស់យុទ្ធសាស្ត្រឧស្សាហូបនីយកម្មជំនួសការនាំចូល គឺក្នុងកំលុងពេលដែល ប្រហែលជាមាននយោបាយបង្រួបបង្រួមជាមួយម៉ាឡេស៊ី ។នៅចុងឆ្នាំ១៩៦០ យុទ្ធសាស្ត្រឧស្សាហូបនីយកម្ម សំដៅនាំចេញត្រូវបានគេប្រើប្រាស់ ។ រាល់កិច្ចអភិវឌ្ឍន៍និងការកែទំរង់ស្ថាប័ននានាត្រូវបានគេធ្វើឡើង ដើម្បីជួយដល់ឧស្សាហូបនីយកម្មបំរើការនាំចេញ និងយុទ្ធសាស្ត្រទីក្រុងសកល ។ សិង្ហបូរី បានប្រកាស់អោយប្រើប្រាស់ផែនការចង្អុលបង្ហាញ១០ឆ្នាំ ដើម្បីអភិវឌ្ឍន៍ប្រទេសអោយទៅជា ប្រទេសមានសេដ្ឋកិច្ចទំនើបផ្អែកលើវិទ្យាសាស្ត្របច្ចេកវិទ្យាជំនាញនិងចំណេះដឹង ។ នាឆ្នាំថ្មីៗនេះ ការផ្តោតអារម្មណ៍បានសង្កត់ធ្ងន់ទៅលើកិច្ចអភិវឌ្ឍន៍វិស័យសេវាកម្ម ដែលពេលនោះការអភិវឌ្ឍន៍ធនធានមនុស្ស នៅតែជាអាទិភាពមួយនៅឡើយ។ ក្រៅអំពីផែនការ ដែលមានចរិតលក្ខណៈជាការណែនាំនិងជាគុណភាព ក៏នៅមានផែនការបំពេញបង្រ្គប់ និងផែនការជំនួយបន្ថែមជាច្រើនទៀត ដូចជា ផែនការបច្ចេកវិជ្ជាជាតិ ផែនការកំលាំងពលកម្ម ផែនការសង្គមនៅក្នុងផ្នែកសុខាភិបាល អប់រំ លំនៅដ្ឋាន និងផ្នែកដ៏ទៃទៀតជាច្រើន ។ ហើយផែនការទស្សនៈរយៈពេលវែង បានផ្តល់នូវទស្សនៈសំរាប់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម រយៈពេលយូរអង្វែង ។ ទោះបីជាគេមិនបានឃើញសិង្ហបូរី បានប្រើប្រាស់ផែនការគ្រប់ជ្រុងជ្រោយរបស់ជាតិនៅគ្រប់ទិសទីក៏ដោយ ក៏នៅមានកិច្ចខំ

ប្រឹងប្រែងកសាងផែនការអភិវឌ្ឍន៍យ៉ាងប្រុងប្រយ័ត្នផងដែរ ហើយមិនមានន័យថារដ្ឋាភិបាលសិង្ហបុរី មានការអន្តរាគមន៍តិចជាងប្រទេសអាស៊ានដ៏ទៃទៀតដែរ ។

ប្រទេសថៃ គឺជាតំណាងប្រទេសមួយទៀត ដែលបានទទួលកំណើនសេដ្ឋកិច្ចគួរជាទីសង្ឃឹម តាមរយៈយុទ្ធសាស្ត្រអភិវឌ្ឍន៍សំដៅទៅរកទីផ្សារ ។ ជាច្រើនឆ្នាំកន្លងមក សេដ្ឋកិច្ចបានបើកចំហរកាន់តែច្រើនឆ្ពោះទៅរកពាណិជ្ជកម្មនិងវិនិយោគទុនបរទេស ។ ផែនការអភិវឌ្ឍន៍ទីមួយនិងទីពីរ បានសង្កត់ធ្ងន់ទៅលើកិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងគោលនយោបាយរដ្ឋាភិបាល ក្នុងការជំរុញឧស្សាហូបនីយកម្ម តាមរយៈសហគ្រាសឯកជន ។ បញ្ហាយកផលិតផលចំរុះជាមូលដ្ឋាន របាយប្រាក់ចំណូល និងសកម្មភាពសេដ្ឋកិច្ចវិមជ្ឈការ ត្រូវបានគេសង្កត់ធ្ងន់នៅក្នុងផែនការអភិវឌ្ឍន៍ទីបីនិងទីបួន ដែលបានអនុវត្តក្នុងកំឡុងឆ្នាំ១៩៧០។ នៅក្នុងកំឡុងពេលនេះដែរ យុទ្ធសាស្ត្រឧស្សាហូបនីយកម្មរបស់ប្រទេស បានចាប់ផ្តើមផ្តោតអារម្មណ៍ជាសំខាន់ទៅលើការជំរុញការនាំចេញ។ នៅក្នុងពាក់កណ្តាលឆ្នាំដំបូងនៃឆ្នាំ១៩៨០ ថៃឡង់ដ៍ បានជួបប្រទះបញ្ហាអស្ថេរភាពសេដ្ឋកិច្ច ដូចជា អត្រាអតិផរណាបានកើនឡើងខ្ពស់ ពាណិជ្ជកម្មរបស់ប្រទេសកាន់តែយ៉ាប់យឺនអត្រាកំណើនថយចុះ។ ហេតុនេះ គេចាំបាច់ត្រូវផ្តោតអារម្មណ៍ទៅលើការរក្សាអោយបាននូវកំរិតអត្រាកំណើនសមស្របដើម្បីរក្សាលំនឹង។ សេដ្ឋកិច្ចរបស់ថៃបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សនិងបានឆ្លងកាត់អត្រាលូតលាស់យ៉ាងខ្ពស់ចាប់តាំងពីឆ្នាំ១៩៨៧ ។ ការរីកចំរើនយ៉ាងឆាប់រហ័សនៃឧស្សាហកម្មនាំចេញ និងការកើនឡើងជាលំដាប់នៃលំហូរចូលវិនិយោគឯកជនផ្ទាល់ បាននាំមកនូវអត្រាកំណើនចំនួនលេខពីរខ្ទង់នាឆ្នាំ១៩៨៨_៩០ ។ ប៉ុន្តែការនេះ បាននាំមកនូវបញ្ហាហេដ្ឋារចនាសម្ព័ន្ធនិងកំលាំងពលកម្មជំនាញ ។ ផែនការអភិវឌ្ឍន៍លើកទី៧នាពេលបច្ចុប្បន្ន បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើកិច្ចអភិវឌ្ឍន៍ធនធានមនុស្សនិងហេដ្ឋារចនាសម្ព័ន្ធ បើប្រៀបធៀបទៅនិងផែនការមុនៗ ។ បញ្ហាសង្គមសំខាន់ៗនានានៃកិច្ចអភិវឌ្ឍន៍ ដូចជា បរិស្ថាន គុណភាពរស់នៅ របាយប្រាក់ចំណូល និងភាពក្រីក្រនៅតាមជនបទ ក៏ត្រូវបានគេយកចិត្តទុកដាក់ច្រើនណាស់ដែរ នៅក្នុងផែនការអភិវឌ្ឍន៍បច្ចុប្បន្ន ។

ដូចក្នុងករណីឥណ្ឌូនេស៊ីដែរ ដំណើរការកសាងផែនការនៅថៃ បានជាប់ទាក់ទងជាមួយការចូលរួមយ៉ាងសកម្មដោយប្រជាជនក្នុងស្ថាប័នផ្សេងៗគ្នា ។ គេបានបញ្ជាក់ថាវាមានច្រើនរហូតដល់ទៅ១០.០០០នាក់ ដែលមានសមត្ថភាពផ្សេងៗគ្នា និងដែលបានចូលរួមនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ នៅប្រទេសថៃ ។ ក្រៅពីក្រុមប្រឹក្សាអភិវឌ្ឍន៍សេដ្ឋកិច្ច_សង្គមជាផ្លូវការ ដែលជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការរៀបចំពង្រាងផែនការអភិវឌ្ឍន៍ នៅមានស្ថាប័នសិក្សាធិការជាច្រើន ព្រមទាំង អ្នកបច្ចេកទេស និងតំណាងផ្នែកឯកជនផ្សេងៗ ក៏ត្រូវបានជ្រើសរើសជាសមាជិកនៃគណៈកម្មការផ្សេងៗ ដែលបានបង្កើតឡើងសំរាប់រៀបចំ

ផែនការអភិវឌ្ឍន៍។ ហេតុនេះ ការរៀបចំផែនការអភិវឌ្ឍន៍ជាតិ បានក្លាយទៅជាវេទិកាដ៏មានសារៈសំខាន់សំរាប់ការស្វែរយោបល់និងទស្សនៈ ស្តីអំពីបញ្ហានិងគោលនយោបាយនៃកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច_សង្គមរបស់ប្រទេស ។

# II. វដ្តនៃការកសាងផែនការអភិវឌ្ឍន៍

## ២.១ វដ្តនៃការកសាងផែនការទូទៅ

ជាទូទៅការកសាងផែនការតែងត្រូវបានធ្វើឡើងតាមវដ្តមួយទៀងទាត់ដូចរូបទី៣ខាងក្រោម ៖




រូបទី៣ វដ្តនៃការកសាងផែនការអភិវឌ្ឍន៍

ប្រភព: Suranart Khemanarong, 1991

ជំហានទី១: អាស្រ័យលើប្រភេទនៃផែនការ ការកសាងផែនការគប្បីចាប់ផ្តើមពីការសិក្សាអំពីស្ថានភាពចំពោះមុខ ។ ការងារសំខាន់នៃជំហាននេះគឺការវិភាគបញ្ហា វិភាគប្រភពធនធាន និងឧបសគ្គនានា ហើយនិងកំនត់បាននូវទិសដៅ ។ ទំហំនៃប្រការទាំងនេះអាចនឹងរកឃើញបាន តាមរយៈការធ្វើអង្កេតសេដ្ឋកិច្ច_សង្គមកិច្ច ការវិភាគពីប្រភពពត៌មាននានា ការសិក្សាពីសង្គមបរិយាកាស និងរបាយការណ៍នានា ... ។ល។

ជំហានទី២: ជំហានទីមួយ បញ្ចប់ដោយសន្មតបាននូវបញ្ជីបញ្ហាផ្សេងៗ ដែលរកឃើញ ។ ផ្អែកលើបញ្ហាទាំងនេះ ក្នុងជំហានទី២ យើងអាចកំនត់នូវគោលដៅ និងទិសដៅនៃការអភិវឌ្ឍន៍ ។ ករណីបញ្ហាមានច្រើន យើងចាំបាច់ត្រូវកំណត់នូវអាទិភាព ថាតើបញ្ហាណាគួរត្រូវបានដោះស្រាយមុន។

ជំហានទី៣: ផ្អែកលើការលំបាកនិងលក្ខខ័ណ្ឌអនុគ្រោះ ដែលសំគាល់ឃើញនៅជំហានទីមួយ យើងអាចកំណត់ចេញនូវយុទ្ធសាស្រ្តផ្សេងៗ ដើម្បីឈានអោយដល់គោលដៅដែលបានកំណត់ ។ ការជ្រើសរើសយុទ្ធសាស្រ្តគួរផ្អែកតាមលក្ខខ័ណ្ឌសមស្រប ភាពអាចទទួលបាននៃអ្នកទទួលផល ... ។ល។

ជំហានទី៤: ផ្អែកលើយុទ្ធសាស្រ្តកំនត់រួច យើងអាចកំនត់នូវកម្មវិធី ឬគំរោងអភិវឌ្ឍន៍នានា ។ បើមានគំរោងច្រើនត្រូវបានលើកឡើង ការចាត់ថ្នាក់អាទិភាពត្រូវធ្វើឡើងដើម្បីជ្រើសរើសគំរោង ដែលត្រូវអនុវត្តមុន ។

ជំហានទី៥: ក្នុងជំហាននេះ ប្រភពហិរញ្ញវត្ថុ និងប្រភពដ៏ទៃទៀតគួរត្រូវបានកំណត់ ។ វិធីសាស្រ្តក្នុងការស្វែងរក ឬប្រមូលប្រភពធនធាន និងការអនុវត្តន៍គំរោង ក៏គួរត្រូវបានរៀបរៀងអោយស្រេចផងដែរ ។

ជំហានទី៦: ការអនុវត្តន៍គំរោងរួមមាន ការដំណើរការកម្មវិធី ការកំណត់ប្រតិទិនអនុវត្តន៍គំរោង(ផែនការ-ការងារ) ការសំរបសំរួល ឬសមាហរណកម្មគំរោង ដែលមានការពាក់ព័ន្ធគ្នា និងការកំនត់ពីតួនាទីនិងការទទួលខុសត្រូវលើសកម្មភាពផ្សេងៗ ។

ជំហានទី៧: ជំហានចុងក្រោយគឺ ការត្រួតពិនិត្យ និងវាយតំលៃលើការអនុវត្តន៍គំរោងកន្លងមក ។

ក្នុងជំហាននិមួយៗ គេអាចសង្កេតឃើញ ការលេចចេញនូវចំនុចខ្វះខាតរបស់ការរៀបចំ កសាងផែនការ ឬការបង្ហាញអោយឃើញថា គោលដៅដែលឆ្ពោះទៅរកនោះ មិនអាចធ្វើទៅបានទេ ហេតុនេះវាតំរូវអោយមានការកែសំរួលផែនការនោះឡើងវិញ ។

## ២.២ បទពិសោធន៍នៃការកសាងផែនការអភិវឌ្ឍន៍ខេត្ត

តាមបទពិសោធន៍នៃការធ្វើផែនការអភិវឌ្ឍន៍ខេត្តកន្លងមក នៅខេត្តសីលាទាំងប្រាំ ការងារកសាងផែនការ ត្រូវបានចាប់ផ្តើមពីការដែលបានទទួលសារាចរ ឬសេចក្តីណែនាំផ្សេងៗពីក្រសួងផែនការ ។ យោងលើការណែនាំនោះ អភិបាលខេត្តបានចេញសេចក្តីណែនាំលំអិតបន្ថែមទៀត ដើម្បីអោយដំណើរការរៀបចំកសាងផែនការនោះមានលក្ខណៈល្អប្រសើរ ។ ផ្អែកលើការណែនាំទាំងនោះ មន្ទីរជំនាញជុំវិញខេត្ត ចាប់ផ្តើមរៀបចំពង្រាងផែនការវិស័យរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងផែនការខេត្ត ។ ក្នុងករណីមានសំនូមពរ មន្ទីរផែនការខេត្តដែលជាអ្នកសំរបសំរួល អាចជួយមន្ទីរជំនាញទាំងនោះអោយរៀបចំផែនការរបស់គេបានចំទិសដៅល្អ ។ ការកសាងផែនការវិស័យត្រូវបានយកទៅផ្ទៀងផ្ទាត់ជាមួយ ផែនការឃុំនៅថ្នាក់ស្រុក ដែលគេហៅថា សមាហរណកម្មផែនការឃុំជាមួយនិងផែនការវិស័យ ។ ក្រោយពីកែ

សំរួលផែនការវិស័យអោយស៊ីសង្វាក់និងផែនការឃុំរួចហើយ ទើបយកផែនការទាំងនោះទៅបញ្ចូលក្នុងពង្រាងដំបូងនៃផែនការអភិវឌ្ឍន៍ខេត្ត ។ ពង្រាងផែនការអភិវឌ្ឍន៍ខេត្តនេះ ត្រូវបានដាក់ជូនគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត (គ.អ.ជ.ខ.) ដែលមានប្រធានមន្ទីរមកពីគ្រប់មន្ទីរចូលរួម និងមានអភិបាលខេត្តជាប្រធាន (សូមមើលរចនាសម្ព័ន្ធគ្រប់គ្រងសីលា) ដើម្បីពិនិត្យនិងផ្តល់យោបល់កែសំរួល ។ ក្រោយពីបានកែសំរួលជាចុងក្រោយ នូវផែនការអភិវឌ្ឍន៍ខេត្តតាមការផ្តល់យោបល់មក ទើបគ.អ.ជ.ខ អនុម័តនិងផ្សព្វផ្សាយអោយប្រើជាផ្លូវការ ។ ក្រោយពីអនុវត្តផែនការ ការតាមដាននិងវាយតំលៃក៏ត្រូវបានធ្វើឡើងដែរ ដើម្បីជាទុនសំរាប់ការកសាងផែនការវដ្តថ្មីក្រោយទៀត ។ ការអធិប្បាយលំអិតនឹងមានបន្ថែមទៀតនៅក្នុងផ្នែកទី៣ ។

វដ្តនៃការរៀបចំផែនការអភិវឌ្ឍន៍ខេត្តនេះអាចបំព្រួញតាមរូបទី៤ខាងក្រោម៖




រូបទី៤ វដ្តនៃការកសាងផែនការអភិវឌ្ឍន៍ខេត្ត

ដូចដែលបានដឹងនៅក្នុងសេចក្តីណែនាំរបស់ក្រសួងផែនការ របស់អភិបាលខេត្ត-ក្រុង ក៏ដូចជាខ្លឹមសារអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ រួចហើយថាមន្ទីរផែនការខេត្ត-ក្រុង

មិនមែនជាអ្នករៀបចំផ្ទាល់នូវផែនការរបស់វិស័យនានានោះទេ ។ តែជាអ្នកនាំមុខ ក្នុងការសំរបសំរួល អោយដំណើរការនៃការរៀបចំកសាងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុងបានសំរេចល្អ ។ ហេតុនេះផែនការអភិ-វឌ្ឍន៍ខេត្ត-ក្រុង ដែលរួមមានផែនការអភិវឌ្ឍន៍របស់ឃុំ និងមន្ទីរជំនាញនានាក្នុងខេត្ត-ក្រុង គប្បីត្រូវបាន ព្រាងឡើងដោយក្រុម ឬគណ:កម្មការដែលមានតំណាងមកពីគ្រប់មន្ទីរទាំងអស់ ។ តាមការរៀបចំកន្លង មកមន្ទីរផែនការខេត្ត-ក្រុង ដែលជាអ្នកសំរបសំរួលក្នុងការសរសេរផែនការ មាននាទីព្រាងសេចក្តីសំរេច តែងតាំងគណ:កម្មការរៀបចំផែនការ ដាក់ជូនអភិបាលខេត្ត និងដែលជាប្រធានគណ:កម្មាធិការអភិវឌ្ឍន៍ ជនបទខេត្ត(PRDC) ដើម្បីអនុម័ត ។ គណ:កម្មការនេះ នឹងត្រូវចែកជាក្រុមតូចៗ ឬអនុគណ:កម្មការ ទទួលបន្ទុកពិភាក្សាព្រាងផ្នែកផ្សេងៗគ្នានៃផែនការខេត្ត-ក្រុង ។ តំណាងនៃមន្ទីរឬវិសយ័ដែលមានទំនាក់ ទំនងគ្នា គប្បីត្រូវបានដាក់ក្នុងក្រុម ឬអនុគណ:កម្មការជាមួយគ្នា ។

ការងារនៃគណ:កម្មការនេះអាចសង្ខេបជាជំហ៊ានៗ ដូចតទៅ ៖

១- ប្រជុំរួមគណ:កម្មការកសាងផែនការ

- ពន្យល់សារជាថ្មី អំពីផ្នែកនានារបស់ផែនការខេត្ត-ក្រុង
- ប្រកាសពីសមាសភាព និងភារកិច្ចរបស់អនុគណ:កម្មការនិមួយៗ
- ពិភាក្សាកំនត់ពីកាលវិភាគសកម្មភាពរបស់អនុគណ:កម្មការនិមួយៗ
- កំនត់កាលបរិច្ឆេទប្រមូលលទ្ធផលការងារ និងការប្រជុំលើកក្រោយ
- ផែនការវិស័យនិមួយៗកសាងឡើងដោយផ្អែកលើវិធីសាស្រ្តLogframe ដោយមាន ការជួយសំរបសំរួលបច្ចេកទេសពីមន្ទីរផែនការខេត្ត-ក្រុង ក្នុងករណីមានសំណូមពរ
- កំណត់កាលវិភាគធ្វើសមាហរណកម្មផែនការវិស័យជាមួយផែនការមូលដ្ឋាន ។

២- ប្រជុំគណ:កម្មការកសាងផែនការនៅពេលដែលអនុគណ:កម្មការនិមួយៗបានបញ្ចប់ ឬឈាន ទៅបញ្ចប់ការសរសេររបស់ខ្លួន ដើម្បីពិនិត្យផ្លាស់ប្តូរយោបល់លើចំនុចមិនច្បាស់លាស់ ឬដោះ ស្រាយបញ្ហាដែលជួបប្រទះ ព្រមទាំងបញ្ចូលនូវលទ្ធផលសមាហរណកម្មផែនការនៅថ្នាក់ស្រុកទៅ ក្នុងផែនការវិស័យនិមួយៗ ។

៣- ប្រជុំគណ:កម្មការម្តងទៀតនៅពេល ពង្រាងគ្រប់ផ្នែកត្រូវកែសំរួលបញ្ចប់

- ធ្វើការវាយតំលៃលើដំណើរការកសាងផែនការខេត្ត-ក្រុង ដើម្បីកែសំរួលជំហាន និមួយៗ ក្នុងវដ្តនៃការកសាងផែនការនាឆ្នាំបន្ទាប់អោយកាន់តែល្អប្រសើរ ។
- មន្ទីរផែនការប្រមូលលទ្ធផលពីក្រុមនិមួយៗមកចងក្រងជាផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង

# III. បែបផែននៃផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង

ការចងក្រងជាបន្តបន្ទាប់ទៅនេះ គឺជាការដកស្រង់នូវបទពិសោធន៍ដែលបានអនុវត្តន៍រួចមកហើយនៅខេត្តសិលាទាំងប្រាំ (ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងរតនៈគីរី) នៅក្នុងការចាប់ផ្តើមកសាងផែនការអភិវឌ្ឍន៍ខេត្តនាឆ្នាំ១៩៩៧ ក្រោមជំនួយគាំទ្ររបស់ UNDP/UNOPS/CARERE ហើយក៏ជាផ្នែកមួយនៃកម្មវិធីសិលារបស់រាជរដ្ឋាភិបាលផងដែរ ។ ដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង នេះអាចប្រែប្រួលទៅតាមបច្ចេកទេសរបស់ខេត្ត-ក្រុងនិមួយៗ ដែលធ្វើយ៉ាងណាអាចជំរុញអោយសំរេចដំណើរការតាមជំហាននិមួយៗ ។ ប៉ុន្តែទំរង់បែបផែនរួមត្រូវបានធ្វើអោយមានលក្ខណៈជាបទដ្ឋាន សំរាប់ប្រើប្រាស់នៅទូទាំងប្រទេសចាប់តាំងពីឆ្នាំ១៩៩៩នេះតទៅ ហើយដែលនឹងលើកយកមកអធិប្បាយខាងក្រោមនេះ ។

## ៣.១ ប្រតិទិននៃការកសាងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង

នៅក្នុងការកសាងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង តាមបទពិសោធន៍របស់ខេត្តសិលាទាំង៥ (ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងរតនៈគីរី) មន្ទីរផែនការខេត្ត-ក្រុងគឺជាអ្នកសំរបសំរួលដោយផ្អែកទៅលើការណែនាំរបស់ក្រសួងផែនការ និងការណែនាំរបស់អភិបាលខេត្ត-ក្រុង ដោយបានព្រមព្រៀងធ្វើការងារឯកភាពតាមប្រតិទិនរួមមួយ ដែលមានជាសង្ខេបដូចខាងក្រោម ៖

១ ការបើកវគ្គបំពាក់បំប៉ននៅតាមខេត្តនិមួយៗ (មករា_វិច្ឆិកា)

២ ការបង្កើតនូវប្រព័ន្ធតាមដាននិងវាយតំលៃផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង (ឧសភា_កក្កដា)

៣ សិក្ខាសាលាស្តីពីផែនការយុទ្ធសាស្ត្រតាមវិស័យ (ឧសភា_កក្កដា)

៤ ការរៀបចំពង្រាងផែនការតាមមន្ទីរនានាសំរាប់ឆ្នាំបន្ទាប់ (កក្កដា_សីហា)

៥ ការពិនិត្យឡើងវិញនិងធ្វើសមាហរណកម្មរវាងផែនការឃុំ និងពង្រាងផែនការវិស័យនៅតាមបណ្តាស្រុក (សីហា_កញ្ញា)

៦ រៀបចំកែសំរួលផែនការវិស័យអោយស្របទៅតាមលទ្ធផលសមាហរណកម្ម (កញ្ញា_តុលា)

៧ ពង្រាងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុងសំរាប់ឆ្នាំបន្ទាប់ (កញ្ញា_តុលា)

៨ គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្តអនុម័តផែនការអភិវឌ្ឍន៍ខេត្ត-ក្រុងឆ្នាំបន្ទាប់ (តុលា)

៩ ការដាក់ផែនការអភិវឌ្ឍន៍ខេត្ត-ក្រុងជូនទៅថ្នាក់ជាតិ (វិច្ឆិកា)

១០ ការបង្ហាញផែនការអភិវឌ្ឍន៍ខេត្ត-ក្រុងទៅក្រុមដឹកនាំការងារសិលា (វិច្ឆិកា)

១១ ការជួយរៀបចំផែនការការងារស្រុកសំរាប់ឆ្នាំបន្ទាប់ (វិច្ឆិកា_ធ្នូ)

១២ ការរៀបចំកម្មវិធីវិនិយោគសំរាប់ការអភិវឌ្ឍន៍ខេត្ត-ក្រុង ដើម្បីបញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈរបស់ជាតិ (ធ្នូ_មិនា)

១៣ ការវាយតំលៃផែនការអភិវឌ្ឍន៍ខេត្តឆ្នាំចរមាន (ធ្នូ)

## ៣.២ ឯកសារជាមូលដ្ឋាន

នៅក្នុងការកសាងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង ចាំបាច់ត្រូវមានឯកសារជាបង្អែកសំរាប់អោយការរៀបចំនោះមានលក្ខណៈត្រឹមត្រូវពេញលេញ និងស៊ីសង្វាក់គ្នា ។ ឯកសារដែលគួរយកមកប្រើជាមូលដ្ឋាននោះមាន ៖

☞ **ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំលើកទី១ ១៩៩៦-២០០០**

គឺជាឯកសារដែលចាំបាច់បំផុតដែលត្រូវតែសម្របតាម ព្រោះជាគោលនយោបាយរួមរបស់ជាតិទាំងមូលដែលដាក់ចេញសំរាប់គ្រប់ខេត្ត-ក្រុងប្រតិបត្តិ ។

☞ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល**

គឺជាឯកសារដែលរៀបចំឡើងដោយរាជរដ្ឋាភិបាល ដើម្បីដាក់ចេញជាមាគ៌ានយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច របស់ប្រទេសជាតិ នៅក្នុងកំឡុងពេលមួយអាណត្តិនៃការកាន់អំណាចរបស់ខ្លួន ។

☞ **ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំរបស់ខេត្ត១៩៩៦-២០០០**

គឺជាឯកសារដែលខេត្ត-ក្រុងនិមួយៗកសាងឡើងសំរាប់ការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ដោយផ្អែកលើផែនការជាតិ ។ តែមានលក្ខណៈពិសេសតាមតំបន់-ខេត្ត-ក្រុងនិមួយៗ(ប្រសិនបើមាន) ព្រោះខេត្ត-ក្រុងមួយចំនួន ពុំបានចាប់អារម្មណ៍ក្នុងការរៀបចំអោយមានឡើងនោះទេ ។

☞ **កម្មវិធីវិនិយោគសាធារណៈជាតិ និងខេត្ត-ក្រុង**

គឺជាឯកសារដែលបានរៀបចំឡើងដោយរួមបញ្ចូលនូវគំរោង ឬកម្មវិធីអភិវឌ្ឍន៍នានា ដែលបានស្នើឡើងសំរាប់អនុវត្តក្នុងរយៈពេលមួយកំនត់ ។ ជាផែនការរំកិលបីឆ្នាំ ដែលបានរៀបចំជារៀងរាល់ឆ្នាំ ។ តាមបណ្តាខេត្ត-ក្រុងមួយចំនួនក៏ធ្លាប់បានរៀបចំផែនការប្រភេទបែបនេះដែរ។ ហេតុនេះអ្នករៀបចំផែនការគួរមានឯកសារប្រភេទនេះជាបង្អែកផងដែរ ។

☞ **ផែនការអភិវឌ្ឍន៍ខេត្ត-ក្រុងឆ្នាំមុនៗ**

ផែនការអភិវឌ្ឍន៍ដែលបានរៀបចំឡើងនៅឆ្នាំមុនៗ នឹងក្លាយជាឯកសារយោងសំរាប់ការរៀបចំផែនការអភិវឌ្ឍន៍នាឆ្នាំបន្ទាប់ ដូចជាផែនការអភិវឌ្ឍន៍ឆ្នាំ១៩៩៧ ត្រូវបានយកមកប្រើសំរាប់ជាឯកសារយោងក្នុងការរៀបចំផែនការឆ្នាំ១៩៩៨ ។ វាជាប្រការមួយដ៏ល្អ ព្រោះអាចអោយយើងរំលឹកឡើងវិញនូវអ្វីដែលយើងបានប៉ុនប៉ងអនុវត្តជាបន្តជាប់គ្នាពីមួយឆ្នាំទៅមួយឆ្នាំ មកផ្សារភ្ជាប់គ្នាប្រៀបដូចជាខ្សែច្រវាក់ដើម្បីអោយការប្រើប្រាស់ធនធានទាំងអស់មានប្រសិទ្ធភាពខ្ពស់បំផុត ។

☞ **ការវាយតម្លៃពាក់កណ្តាលទួបនៃផែនការអភិវឌ្ឍន៍ខេត្ត_ស្រុក**

ការរៀបចំផែនការគឺត្រូវធ្វើឡើងអោយមុនដំណាច់ឆ្នាំ ហេតុនេះគួរយកការវាយតំលៃពាក់កណ្តាលឆ្នាំនៃផែនការចាស់មកធ្វើជាឯកសារបង្អែក ជំនួសអោយការវាយតំលៃចុងឆ្នាំ ។ ឯកសារវាយតំលៃនេះនឹងផ្តល់អោយយើងនូវការពិចារណាជាថ្មីសមរម្យ សំរាប់ការរៀបចំយុទ្ធសាស្ត្រអនុវត្តន៍គំរោងផែនការនានាដែលគ្រោងនឹងស្នើឡើងនៅឆ្នាំខាងមុខ បានជាក់លាក់សមហេតុផល ។

☞ **យុទ្ធសាស្ត្រនិងគោលនយោបាយជាតិតាមវិស័យ**

ចំពោះវិស័យមួយចំនួន ក្រសួងសាមីបានរៀបចំរួចជាស្រេចនូវគោលនយោបាយជាយុទ្ធសាស្ត្រសំរាប់បណ្តាមន្ទីរខេត្ត_ក្រុងខ្លួនប្រតិបត្តិតាម ។ វាគឺជាឯកសារចាំបាច់សំរាប់ជាបង្អែកផងដែរ ។

☞ **បណ្ណារបាយការណ៍អង្កេតសេដ្ឋកិច្ច_សង្គមកិច្ចប្រទេសកម្ពុជា**

វិទ្យាស្ថានស្ថិតិជាតិបានរៀបចំការអង្កេតសេដ្ឋកិច្ច_សង្គមកិច្ចតាមបច្ចេកទេសត្រឹមត្រូវ មានភាពជាក់លាក់បំផុត ហើយត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ជាពត៌មានផ្លូវការរួចទៅហើយ សំរាប់ជាមូលដ្ឋានទិន្នន័យប្រើប្រាស់នៅក្នុងគោលដៅផ្សេងៗ ។ សំរាប់ការកសាងផែនការអភិវឌ្ឍន៍ខេត្ត_ក្រុង ទិន្នន័យបានមកពីប្រភពខាងលើ ត្រូវបានយកមកជាបង្អែកក្នុងការវិភាគអំពីស្ថានភាពសេដ្ឋកិច្ច_សង្គមកិច្ចនៅខេត្តនិមួយៗ ដោយដកស្រង់តែអ្វីដែលទាក់ទង ឬក៏ទិន្នន័យសំរាប់ប្រៀបធៀបខេត្ត_ក្រុងមួយទៅខេត្ត_ក្រុងមួយទៀត ។

## ៣.៣ ការចូលរួមក្នុងការកសាងផែនការអភិវឌ្ឍន៍ខេត្ត_ក្រុង

នៅក្នុងសារាចរណែនាំរបស់ក្រសួងផែនការ នោះប្រាកដជាមានបញ្ជាក់ច្បាស់ថា ការកសាងផែនការអភិវឌ្ឍន៍ខេត្ត_ក្រុង តំរូវអោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន មូលដ្ឋានភូមិ_ឃុំ មន្ទីរនានា អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជនផងដែរ ។ នៅក្នុងការកសាងផែនការអភិវឌ្ឍន៍ខេត្ត_ក្រុង កន្លងមកគេសង្កេតឃើញថាពុំមានជំពូកដោយឡែក ដែលអធិប្បាយអំពីផែនការរបស់អង្គការក្រៅរដ្ឋាភិបាល ឬផ្នែកឯកជននោះឡើយ ពីព្រោះ សកម្មភាពរឺគំរោងអភិវឌ្ឍន៍របស់អង្គការក្រៅរដ្ឋាភិបាល ឬផ្នែកឯកជនទាំងនោះបានស្ថិតនៅជាស្រេចរួចហើយ នៅក្នុងវិស័យនានាដែលមាន ។ ហេតុនេះ មន្ទីរនៃវិស័យនិមួយៗគប្បីយកចិត្តទុកដាក់ស្រង់យកគំរោងឬសកម្មភាពអភិវឌ្ឍន៍ទាំងនោះ មកបញ្ចូលទៅក្នុងផែនការវិស័យ ឬ មន្ទីររបស់ខ្លួន ។ ម្យ៉ាងទៀតវាក៏ជាចំនែកមួយនៃការអភិវឌ្ឍន៍វិស័យផងដែរ ។ ក្នុងករណីដែលម្ចាស់គំរោងពុំឯកភាពអោយបញ្ចូលទៅជាផ្នែកមួយនៃផែនការវិស័យនោះ ស្នើលើកយកគំរោង ឬកម្មវិធីនោះទៅដាក់ក្នុងផ្នែកឧបសម្ព័ន្ធ។ សូមកុំព្យាយាមបង្កើតឬបន្ថែមជំពូកថ្មីទៀតនៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត_ក្រុង ដែលនាំអោយមានភាពខុសប្លែកពីទំរង់ដែលក្រសួងផែនការស្នើឡើង សំរាប់ជាបទដ្ឋានប្រើប្រាស់ទូទាំងប្រទេស។

## ៣.៤ ទំនាក់ទំនងអន្តរវិស័យក្នុងការកសាងផែនការ

ដើម្បីរួមបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង ក្នុងការកសាងផែនការវិស័យនិមួយៗ តែងតែមាននូវបញ្ហាចំរុះជាច្រើនផ្នែក ឬក៏ជាការជះឥទ្ធិពលពីវិស័យមួយទៅវិស័យមួយទៀត ។ ហេតុនេះវិស័យនិមួយៗ គប្បីពិនិត្យនូវបញ្ហាទាំងនោះហើយរួមគ្នារកដំណោះស្រាយដែលមានផលវិបាកតិចបំផុត វីក៏វិធីដែលផ្តល់នូវប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីសំរេចគោលដៅទូទៅជាចំបង ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួន ដែលបង្ហាញពីទំនាក់ទំនងពីវិស័យមួយទៅវិស័យមួយទៀត ៖

ក) <u>បញ្ហាដែលទាក់ទងទៅនឹងបរិស្ថាន</u>

សំរាប់កម្មវិធីអភិវឌ្ឍន៍កសិកម្ម ការនាំមកប្រើនៅក្នុងស្រុកនូវពូជបរទេសដែលគ្មានក្នុងស្រុក ដូចជា "រុក្ខជាតិ សត្វ ត្រី ... ។ល។" នោះអាចធ្វើអោយបាត់បង់នូវពូជក្នុងស្រុក ដែលធ្លាប់មានពីមុនមក ហើយនិងមានតំលៃជាលក្ខណៈជាតិចាំបាច់បំផុត ។

ការសាងសង់ទំនប់ទឹក ប្រព័ន្ធធារាសាស្ត្រ និងផ្លូវថ្នល់ជាដើម របស់ធារាសាស្ត្រ ឬសាធារណការ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន នោះអាចធ្វើអោយផ្លាស់ប្តូរនូវជីវិតសត្វ រុក្ខជាតិក្នុងតំបន់នោះ ។

ការអភិវឌ្ឍន៍ឧស្សាហកម្ម និងទេសចរណ៍អាចជះឥទ្ធិពលដល់បរិស្ថានរូបវន្ត បរិស្ថានជីវសាស្ត្រ បរិស្ថានសេដ្ឋកិច្ចសង្គម ... ។ល។

ហេតុនេះគំរោងអភិវឌ្ឍន៍នានាដែលយល់ថាអាចបះពាល់ដល់បរិស្ថាន ត្រូវមានសេចក្តីបញ្ជាក់បន្ថែមអោយច្បាស់លាស់ ដោយមានការពិភាក្សាត្រឹមត្រូវពីជំនាញការផ្នែកបរិស្ថាន ជៀសវាងវិបត្តិផ្សេងៗដែលកើតមានឡើងទៅអនាគត ហើយដែលតំរូវអោយចំណាយថវិកាជាច្រើនដើម្បីស្តារស្ថានភាពនោះឡើងវិញ ។

ខ) <u>បញ្ហាដែលទាក់ទងនិង**GENDER** (Cross cutting issues)</u>

សំរាប់កម្មវិធីទឹកស្អាតនិងអនាម័យ ការរៀបចំគំរោងទាំងនោះវាទាក់ទងនឹងបញ្ហាមួយចំនួនដូចជា ៖

តើអ្នកណាជាអ្នកទៅដងទឹកនោះយកមកប្រើ ? អាយុប៉ុន្មាន ? ពេលណា ? ទីកន្លែងណា ? ញឹកញាប់ប៉ុណ្ណា ? ហេតុអ្វី ? ដើម្បីអ្វី ? ផលវិបាកអ្វីដែលស្ត្រីត្រូវដោះស្រាយ ?

សំរាប់កម្មវិធីថែទាំសុខភាពបឋម ត្រូវនឹកគិតទៅដល់សំនួរមួយចំនួនដូចជា ៖

តើអ្នកណាជាអ្នកមានតួនាទីលើសលុបជាងគេ? អាយុប៉ុន្មាន? តើកិច្ចការអ្វីដែលធ្វើជាក់លាក់ ? តើវាមានការងារទំនាក់ទំនងជាមួយអ្វីខ្លះ? ញឹកញាប់ឬទេ? ព្រោះអ្វី? ផលវិបាកដែលស្ត្រីត្រូវដោះស្រាយ?

កម្មវិធីដែលទាក់ទងនិងការអនុវត្តន៍នូវបច្ចេកទេសកសិកម្មបែបថ្មី គេគួរដឹងអំពី ៖

តើអ្នកណាដើរតួនាទីអ្វី ? អាយុប៉ុន្មាន ? តើកិច្ចការអ្វីដែលធ្វើជាក់លាក់ ? តើវាមានទំនាក់ទំនងជាមួយអ្វីខ្លះ ? ញឹកញាប់ឬទេ ? ព្រោះអ្វី ? ផលវិបាកដែលស្ត្រីត្រូវដោះស្រាយ ? ដូចជា ជំនាញ ធនធាន ឧបករណ៍ ឥណទាន ពេលវេលា ការសំរេចចិត្ត ... ។ល។

ចំពោះគំរោងកម្មវិធីទេសចរណ៍ វាមានបញ្ហាទាក់ទងនិង ៖

ឥទ្ធិពលវិជ្ជមានចំពោះបុរស/ស្ត្រី ? ឥទ្ធិពលអវិជ្ជមានចំពោះបុរស/ស្ត្រី ? វិបាករយៈពេលខ្លី ? វិបាករយៈពេលវែង ? តើត្រូវធានាអោយបាននូវឥទ្ធិពលវិជ្ជមានតាមរបៀបណា ?

នៅពេលដែលមានការរិះគិតដោយផ្អែកលើចំនោទបញ្ហាខាងលើ គំរោងដែលបានរៀបចំឡើងមុខជាអាចបញ្ចូលជាស្វ័យប្រវត្តិនូវបញ្ហា GENDER ដែលម្ចាស់ជំនួយជាច្រើនកំពុងតំរូវអោយមាន ។

គ) <u>ការផ្សារភ្ជាប់អន្តរវិស័យ</u>

សំរាប់គំរោងមួយចំនួន ការអនុវត្តន៍បានធ្វើឡើងដោយចំរុះវិស័យដូចជា ៖

កម្មវិធីទឹកស្អាតនិងអនាម័យ អាចអនុវត្តដោយ មន្ទីរសុខាភិបាល មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរកិច្ចការនារី ។

ការសាងសង់ផ្លូវជនបទ ផ្លូវខេត្ត និងផ្លូវជាតិ ដោយមន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរសាធារណការនិងដឹកជញ្ជូន ។

កម្មវិធីអប់រំក្រៅប្រព័ន្ធ ដែលរៀបចំឡើងដោយមន្ទីរអប់រំយុវជននិងកីឡា មន្ទីរកិច្ចការនារី និងមន្ទីរសង្គមកិច្ចជាដើម ។

ហេតុនេះ ដើម្បីអោយផែនការដែលរៀបចំឡើងមានភាពស៊ីសង្វាក់គ្នា នោះត្រូវមានការផ្សារភ្ជាប់គ្នារវាងវិស័យ(មន្ទីរ)និមួយៗយ៉ាងជិតស្និត ទើបការអនុវត្តន៍អាចមានប្រសិទ្ធភាពខ្ពស់ ។ មន្ទីរនិមួយៗដែលមានការពាក់ព័ន្ធអាចមានឱកាសជជែក ឬរៀបចំគំរោងផែនការរបស់ខ្លួនអោយមានលក្ខណៈជាក់ស្តែង និងផ្សារភ្ជាប់រវាងគ្នានិងគ្នា នៅពេលដែលបានចូលរួមក្នុងគណៈកម្មការរៀបចំផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង ជារៀងរាល់ឆ្នាំ ។ ការផ្សារភ្ជាប់នេះលំបាកនិងកើតមានបំផុតចំពោះគំរោងតូចៗ សំរាប់អនុវត្តន៍នៅមូលដ្ឋាន ប្រសិនបើ ការរៀបចំផែនការ ត្រូវបានធ្វើឡើងតែតាមរយៈខ្សែបណ្តោយក្រសួងរបស់ខ្លួននោះ ។

សរុបមក សំរាប់ការកសាងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង មន្ទីរនិមួយៗ ត្រូវយកចិត្តទុកដាក់លើចំនុចទាំងប៉ុន្មានខាងលើ ដើម្បីអោយការអនុវត្តផែនការដែលបានកសាងឡើង អាចសំរេចបាននូវគោលដៅអភិវឌ្ឍន៍ខ្ពស់បំផុតនៅពេលអនាគត និងដោយធានាបាននូវនិរន្តរភាព ។

## ៣.៥ ទំរង់នៃផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង

ជាទូទៅផែនការអភិវឌ្ឍន៍ខេត្ត-ក្រុងត្រូវបានចែកជា៥ជំពូក ដូចតទៅៈ

**ជំពូក១** **ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចខេត្ត-ក្រុង**

- ♦ ប្រជាសាស្ត្រ
- ♦ កំលាំងពលកម្ម និង ការប្រកបមុខរបរ (ទិន្នន័យសេដ្ឋកិច្ច)
- ♦ ភាពក្រីក្រ និង ប្រាក់ចំណូល (សន្ទស្សន៍នៃភាពក្រីក្រ)

**ជំពូក២** **ក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត-ក្រុង**

- ♦ ទស្សនៈ
- ♦ សក្តានុពលភាព និង ឧបសគ្គក្នុងកិច្ចអភិវឌ្ឍន៍
- ♦ គោលដៅអភិវឌ្ឍន៍ និងទិសដៅបន្ទាន់
- ♦ យុទ្ធសាស្ត្រនៃកិច្ចអភិវឌ្ឍន៍

**ជំពូក៣** **ផែនការអភិវឌ្ឍន៍មូលដ្ឋាន**

- ♦ ដំណើរការកសាងផែនការមូលដ្ឋាន(សង្ខេប)
- ♦ ផែនការអភិវឌ្ឍន៍ឃុំ

**ជំពូក៤** **កម្មវិធីអភិវឌ្ឍន៍តាមវិស័យ**

- ♦ សេចក្តីផ្តើម
- ♦ បេសកកម្ម
- ♦ ទស្សនៈ
- ♦ ស្ថានភាពរបស់វិស័យ
    - ○ បញ្ហា
    - ○ ឱកាស
    - ○ លទ្ធផលឆ្នាំកន្លង
- ♦ LOGFRAME (សូមមើលតារាងភ្ជាប់)
- ♦ យុទ្ធសាស្ត្រ
- ♦ សន្និដ្ឋាន

**ជំពូក៥** **កម្មវិធីវិនិយោគសំរាប់ការអភិវឌ្ឍន៍ខេត្ត-ក្រុង**

(សូមមើលតារាងគំរូដែលមានភ្ជាប់មកជាមួយ)

### ៣.៥.១) ជំពូក១ " ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចរបស់ខេត្ត-ក្រុង "

ការអធិប្បាយនៅក្នុងជំពូក១នេះ

មានទាក់ទងទាំងស្រុងទៅនិងការវិភាគទិន្នន័យដែលបានមកពីប្រភព ផ្សេងៗ ដូចជា ៖

-ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ប្រទេសកម្ពុជា របស់វិជ្ជាស្ថានជាតិស្ថិតិ

-ទិន្នន័យពីមន្ទីរនានានៅក្នុងខេត្ត

-ទិន្នន័យពីភូមិ-ឃុំដែលមាន

-និងពីប្រភពដ៏ទៃទៀតដែលពាក់ព័ន្ធ ... ។

នេះជាជំពូកមួយដែលប្រើប្រាស់ទិន្នន័យនិងធ្វើការវិភាគទិន្នន័យ ដើម្បីគាំទ្រអោយការលើកឡើងនៅក្នុងជំពូកទី២ មានលក្ខណៈត្រឹមត្រូវ ។ អាចនិយាយម្យ៉ាងទៀតថា នេះជាជំពូកដែលជាអំណះអំណាងអោយជំពូកទី២ក៏បាន ។ លើសពីនេះទៅទៀត ជំពូកនេះគឺជាការបកស្រាយបង្ហាញពីស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗរបស់ខេត្ត-ក្រុងនិមួយៗ ។ ជាជំពូកដែលបង្ហាញអោយឃើញនូវលក្ខណៈពិសេសរបស់ខេត្ត-ក្រុង និងដែលអាចទាញចេញនូវគំរោងផែនការ ដោយឡែកពីផែនការរួមថ្នាក់ជាតិ ។ ក្នុងនោះការវិភាគទិន្នន័យ ច្រើនផ្តោតទៅលើចំនុចបីជាសំខាន់គឺ ៖

ក) ប្រជាសាស្ត្រ (Demography)

រួមមានការវិភាគទៅលើ ប្រជាជនសរុប ទំហំមធ្យមនៃគ្រួសារ អត្រាអ្នកនៅក្នុងបន្ទុកបែងចែកតាមអាយុ អត្រាអក្ខរកម្មមនុស្សចាស់ ភាគរយស្ត្រីជាមេគ្រួសារ ... ។ល។

ខ) ទិន្នន័យសេដ្ឋកិច្ចស្តីពីកំលាំងពលកម្មនិងមុខរបរ

រួមមានការវិភាគទៅលើ ការប្រកបការងារបែងចែកតាមវិស័យសំខាន់ៗដូចជា កសិកម្ម រុក្ខកម្ម នេសាទ កម្មន្តសាល មុខជំនួញខ្នាតតូច រដ្ឋបាលសាធារណៈនិងការពារជាតិ ...។ល។ ក៏នៅមានការវិភាគទៅលើ អត្រាចូលរួមធ្វើពលកម្ម (បុរស ស្ត្រី) ប្រជារាស្ត្រស្ថិតក្នុងកំលាំងពលកម្ម អត្រាគ្មានការងារធ្វើ ពលកម្មរបស់កុមារ ... ។ល។

គ) សន្ទស្សន៍នៃភាពក្រីក្រដែលបញ្ជាក់ទៅលើស្ថានភាពប្រាក់ចំណូលក្នុងតំបន់

តាមស្ថានភាពជាក់ស្តែងនៅព្រះរាជាណាចក្រកម្ពុជា ការស្រង់ពត៌មានពីប្រាក់ចំណូលរបស់គ្រួសារនិមួយៗ ច្រើនតែពុំអាចធ្វើទៅបានជាក់លាក់ ។ ហេតុនេះ ការប្រើប្រាស់សន្ទស្សន៍មួយចំនួន ដូចជា ៖ លទ្ធភាពប្រើប្រាស់សំភារៈសាធារណៈ (សាលារៀន មណ្ឌលសុខភាព ផ្លូវឆ្លងកាត់ ...) ធៀបនិងចំនួនគ្រួសារ ការកាន់កាប់ដីធ្លី និងប្រភេទដី ស្ថានភាពកម្មសិទ្ធិផ្ទះសម្បែង ភាគរយក្រុមគ្រួសារដែល

គ្មានបង្គន់អនាម័យ ភាគរយក្រុមគ្រួសារដែលប្រើប្រាស់ស្រះ ស្ទឹង អូរ ជាប្រភពទឹកសំរាប់ហូបចុក ភាគរយប្រជាជនពិការ ... ។ល។ ត្រូវបានយកមកធ្វើការវិភាគ ជំនួសអោយទិន្នន័យស្ថិតិស្ថានភាពប្រាក់ចំណូល ។

ការវិភាគដែលមានភ្ជាប់ជាមួយនូវក្រាហ្វិច តារាង ឬគំនូសតាងផ្សេងៗ(Chart)នោះអាចនាំមកនូវភាពងាយស្រួលយល់ ជាងការដែលមានតែអត្ថបទបកស្រាយសុទ្ធសាទតែប៉ុណ្ណោះ ។

នៅខេត្តសិលាទាំងប្រាំ មន្ទីរផែនការខេត្តបានរៀបចំអោយមានទិន្នន័យមូលដ្ឋានភូមិ ជាលំអិតនៅតាមគ្រប់ភូមិបន្ថែមទៀត សំរាប់សិក្សានិងបង្ហាញពីភាពក្រីក្ររបស់ភូមិនិមួយៗដោយឡែកពីគ្នា ។

### ៣.៥.២) ជំពូក២ " ក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត-ក្រុង "

ជំពូកនេះអធិប្បាយអំពីគោលការណ៍រួម សំរាប់ការអភិវឌ្ឍន៍ខេត្ត-ក្រុង ហើយក៏ជាគោលនយោបាយរួម ដែលបានដាក់ចេញសំរាប់អោយមានការរីកចំរើនក្នុងកិច្ចអភិវឌ្ឍន៍ ។ ក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត-ក្រុង មានទំរង់ជាគ្រោងឆ្អឹងរបស់ផែនការអភិវឌ្ឍន៍ខេត្ត-ក្រុងទាំងមូល ។ នៅពេលដែលផែនការនេះត្រូវបានយកទៅពិចារណា ជំពូក២នេះនឹងជួយអោយមានភាពងាយស្រួលយល់ អំពីអ្វីជាទស្សនៈទានរួមនៃការអភិវឌ្ឍន៍ខេត្ត ហើយដែលការរៀបរាប់លំអិតនឹងមានបន្ថែមនៅជំពូកបន្តបន្ទាប់។ ក្នុងនេះមានចែកជាបួនចំនុចបន្តទៀតគឺ ៖

ក) ទស្សនៈ (Vision)

គឺជាអ្វីដែលជាការយល់ឃើញអំពីការអភិវឌ្ឍន៍រយៈពេលយូរអង្វែងទៅអនាគត សំរាប់១០ឬ២០ឆ្នាំខាងមុខ ។ អាចនិយាយបានម្យ៉ាងទៀតថា ជាគោលដៅអភិវឌ្ឍន៍រយៈពេលវែង ឬជា បំណងប្រាថ្នារបស់ខេត្ត-ក្រុងទាំងមូល ដែលចង់អោយមានការផ្លាស់ប្តូរជឿនលឿនក្នុងរយៈពេល១០ឬ២០ឆ្នាំខាងមុខ ។

ឧ. ខេត្តបាត់ដំបងអាចនឹងផលិតស្រូវយ៉ាងច្រើន ប្រកបដោយគុណភាពខ្ពស់សំរាប់នាំយកទៅលក់នៅលើទីផ្សារអន្តរៈជាតិ ជាខេត្តជង្រុកស្រូវដ៏ល្បីល្បាញប្រចាំប្រទេសកម្ពុជា ។

ខ) សក្តានុពលភាពនិងឧបសគ្គក្នុងកិច្ចអភិវឌ្ឍន៍ (Potential and constrain in development)

គឺជាការលើកឡើងនូវអ្វីដែលយើងរំពឹងថា នឹងអាចនាំមកនូវភាពរីកចំរើន ជាសក្តានុពលភាពខាងសម្បត្តិធម្មជាតិ រ៉ែ ថាមពល ដីមានជីជាតិ សង្គមសេដ្ឋកិច្ច កសិកម្ម កសិ-ឧស្សាហកម្ម ... ។ល។ តែទន្ទឹមនិងនេះក៏ត្រូវសិក្សានិងលើកឡើងពីកត្តាមួយចំនួន ដែលធ្វើអោយរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ផងដែរ ។ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង ត្រូវរំពឹងមើលឧបសគ្គទាំងនោះ និងរិះរកមធ្យោបាយសំរាប់ដោះស្រាយ ដោយបង្កើតចេញជាគោលដៅអភិវឌ្ឍន៍និងទិសដៅបន្ទាន់ ។

ខ. ខេត្តបាត់ដំបងមានដីជាច្រើនសំរាប់ពង្រីកលទ្ធភាពដំណាំស្រូវ(សក្តានុពលភាព) ប៉ុន្តែដីទាំងនោះនៅមានមីន(ឧបសគ្គ) ។

គ) <u>គោលដៅអភិវឌ្ឍន៏និងទិសដៅបន្ទាន់</u> (Goal and Immediate Objective)

គឺជាការប៉ងប្រាថ្នារបស់ខេត្ត_ក្រុងទាំងមូល ដែលចង់សំដៅទៅអោយដល់ស្ថានភាពមួយ ក្នុងរយៈពេលមួយកំណត់ ។ សំរាប់គោលដៅអភិវឌ្ឍន៍ នោះគេត្រូវការរយៈពេលមួយវែង ។ ដើម្បីអោយអាចសំរេចបានជាទូទៅ គេច្រើនកំណត់ក្នុងរយៈពេលប្រាំឆ្នាំ ។ តែដើម្បីអោយបានទៅដល់ស្ថានភាពមួយនៅឆ្ងាយនោះ លុះត្រាតែយើងបានទៅដល់ស្ថានភាពមួយនៅជិតសិន នោះគេហៅថាទិសដៅបន្ទាន់ ដែលជាទូទៅគេច្រើន កំណត់ក្នុងរយៈពេលមួយឆ្នាំ ។ បើពិនិត្យអោយស៊ីជំរៅទៀត <u>*ទស្សនៈ*</u> <u>*គោលដៅ*</u> <u>*ទិសដៅ*</u> សុទ្ធតែជា <u>*បំណងប្រាថ្នា*</u> ដែលមាននៅក្នុងគំរោង ឬផែនការទាំងអស់ ហើយត្រូវដាក់ចេញមក ឬក៏សំដែងចេញមកអោយឃើញ ដើម្បីបង្ហាញអោយដឹងថា អ្វីដែលគេកំពុងតែឆ្ពោះទៅរក ឬត្រូវពុះពារធ្វើអោយបានសំរេចនៅថ្ងៃអនាគត ។ ប្រសិនបើគ្មាន <u>*បំណងប្រាថ្នា*</u> ឬ <u>*គោលបំណង*</u> នោះគំរោងនិងផែនការក៏ពុំត្រូវបានរៀបចំឡើងដែរ ។ ប៉ុន្តែដោយសារថា <u>*បំណងប្រាថ្នា*</u> ទាំងនោះស្ថិតនៅក្នុងឋានានុក្រមខុសគ្នា ទើបគេកំណត់ហៅខុសៗគ្នា ដើម្បីងាយស្រួលសំគាល់ ដូចជា *ទស្សនៈ*_សំរាប់រយៈពេល១០_២០ឆ្នាំ ស្ថិតនៅក្នុងលំដាប់ខ្ពស់ជាងគេ *គោលដៅ*(អភិវឌ្ឍន៍)_សំរាប់រយៈពេលប្រហែល៥ឆ្នាំ ស្ថិតនៅ លំដាប់មធ្យម *ទិសដៅ*(បន្ទាន់)_សំរាប់រយៈពេល១ឆ្នាំ ស្ថិតនៅលំដាប់ទាបជាងគេ ។

ឃ) <u>យុទ្ធសាស្ត្រក្នុងកិច្ចអភិវឌ្ឍន៍</u>

គឺជាការគិតទុកជាមុនថាតើត្រូវធ្វើដូចម្តេចដើម្បីសំរេចអោយបាននូវ ទិសដៅនិងគោលដៅ ដែលបានដាក់ចេញមកនោះ ។ បើនិយាយអោយស្រួលយល់ នោះហាក់ដូចជាផ្លូវដែលត្រូវជ្រើសរើស ដើម្បីអោយបានទៅដល់ស្ថានភាព ឬទីតាំងមួយដែលយើងបានប៉ងប្រាថ្នា ។

ខ. ការកសាងផែនការវិមជ្ឈការ និងការផ្តល់ហិរញ្ញប្បទានវិមជ្ឈការ គួបផ្សំនិងការរៀបចំប្រព័ន្ធតាមដាននិងវាយតំលៃត្រឹមត្រូវ(យុទ្ធសាស្ត្រ)នោះ អាចធ្វើអោយមានការប្រើប្រាស់ធនធានដែលស្តួចស្តើងបានចំទិសដៅ និងមានប្រសិទ្ធភាពខ្ពស់ ។

បើនិយាយពីការប្រើប្រាស់ធនធាន នោះអាចមានវិធីជាច្រើនសំរាប់ធ្វើ។ ប៉ុន្តែ ការកសាងផែនការវិមជ្ឈការ និងការផ្តល់ហិរញ្ញប្បទានវិមជ្ឈការ គឺជាជំរើសមួយក្នុងចំនោមវិធីដ៏ទៃទៀត ។

ការអភិវឌ្ឍន៍ជនបទដោយមានការចូលរួមពីសហគមន៍ជនបទ ក៏ជាជំរើស(វិធី) មួយដែលអាចនាំមកនូវជោគជ័យនិងមានលក្ខណៈនិរន្តរភាពផងដែរ ។

### ៣.៥.៣) ជំពូក៣ " ផែនការអភិវឌ្ឍន៍មូលដ្ឋាន "

ពាក្យមូលដ្ឋានដែលប្រើក្នុងជំពូក៣នេះ គឺសំដៅដល់ភូមិនិងឃុំ ។ ផែនការអភិវឌ្ឍន៍មូលដ្ឋាន គឺជាគំរោងផែនការ ដែលបានកសាងឡើងនៅថ្នាក់ភូមិដោយអ្នកភូមិផ្ទាល់ តាមការជួយណែនាំសំរបសំរួលពីក្រុមការងារណាមួយ ដែលគេហៅថាក្រុមសំរបសំរួលស្រុក (សំរាប់អ្នកដែលចុះពីថ្នាក់ស្រុកទៅ) និងក្រុមសំរបសំរួលខេត្ត (សំរាប់អ្នកដែលចុះពីថ្នាក់ខេត្តទៅ) ។ ផែនការអភិវឌ្ឍន៍ភូមិ គឺជាការសំដែងចេញនូវអ្វីដែលប្រជារាស្ត្រនៅក្នុងភូមិនោះត្រូវការ ។ ជាផែនការថ្នាក់ក្រោមបំផុត ហើយត្រូវបានគេយកមកចងក្រងបញ្ចូលគ្នានៅថ្នាក់ឃុំអោយទៅជាផែនការអភិវឌ្ឍន៍ឃុំ ។ ចំនែកផែនការស្រុកគឺជាការរួមបញ្ចូលផែនការឃុំបន្តមកទៀត ។ សំរាប់ខេត្តទាំងប្រាំ ដែលបានអនុវត្តន៍កម្មវិធីសិលា ផែនការស្រុកពុំត្រូវបានគេកសាងឡើងទេ ដោយចាត់ទុកថ្នាក់ស្រុកជាកន្លែងសំរាប់ធ្វើសមាហរណកម្មរវាងផែនការឃុំ និងផែនការវិស័យទេវិញ ។ ស្រុកជាទីតាំងត្រូវជួបគ្នារវាងផែនការមូលដ្ឋាន(ថ្នាក់ឃុំពីក្រោម) និងផែនការវិស័យនានា (ថ្នាក់ខេត្តពីលើចុះទៅ) ហើយដែលចាំបាច់វិស័យនិមួយៗត្រូវតែស្រង់យក តំរូវការដែលមូលដ្ឋានបានស្នើឡើង ។ តែក្នុងពេលប្រជុំធ្វើសមាហរណកម្ម វិស័យក៏មានសិទ្ធិជ្រើសរើសយកឬជំទាស់ នូវសំណើទាំងឡាយដែលមិនសមរម្យ ឬមិនអាចអនុវត្តកើតដោយផលវិបាកផ្សេងៗ ។ល។ ការពន្យល់បន្ថែមអំពីការរៀបចំសំរបសំរួលសមាហរណកម្មផែនការឃុំ ដែលបានអនុវត្តកន្លងមកចាប់តាំងពីឆ្នាំ១៩៩៧ នៅតាមបណ្តាខេត្តសិលាទាំងប្រាំមានបញ្ចូលនៅចំនុច៣.៧នៃសៀវភៅនេះ ។

មាតិកាលំអិតនៅក្នុងជំពូកនេះ ពុំទាន់មានលក្ខណៈជាបទដ្ឋាន។ ប៉ុន្តែការអធិប្បាយត្រូវផ្តោតទៅលើចំនុចសំខាន់ពីរគឺ ៖

-ការពន្យល់អំពីជំហាននៃដំណើការកសាងផែនការមូលដ្ឋាន (បើមាន)

-ការពន្យល់ផែនការអភិវឌ្ឍន៍ឃុំនៅតាមស្រុកនិមួយៗ

ការអធិប្បាយអំពីដំណើរការសំរបសំរួលកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន(LPP) នៅក្នុងកម្មវិធីសិលា ត្រូវបានលើកយកទៅដាក់បញ្ចូលនៅក្នុងផ្នែកឧបសម្ព័ន្ធនៃសៀវភៅនេះផងដែរ ។

### ៣.៥.៤) ជំពូក៤ " កម្មវិធីអភិវឌ្ឍន៍តាមវិស័យ "

ផែនការអភិវឌ្ឍន៍តាមបណ្តាវិស័យនិមួយៗ ត្រូវយកទៅបញ្ចូលទៅក្នុងជំពូកទី៤ និង ជំពូកទី៥ នៃផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង ។ ផែនការវិស័យ ត្រូវមានបីផ្នែកជាសំខាន់គឺ ៖

☞ ការពិពណ៌នា (សំរាប់ជំពូក៤)

☞ ឡូក់ហ្វ្រេម (សំរាប់ជំពូក៤)

☞ តារាងគំរោងវិនិយោគសំរាប់ការអភិវឌ្ឍន៍ខេត្ត-ក្រុង (សំរាប់ជំពូក៥)

៣.៥.៤.១. សេចក្ដីផ្ដើម:

គឺជាការពិពណ៌នាអំពីភាពចាំបាច់និងសារៈសំខាន់របស់វិស័យ ដោយផ្អែកទៅលើ ច្បាប់ ឬក្រឹត្យស្ដីពីការបង្កើតអោយមានវិស័យ ។ កម្មវិធីអភិវឌ្ឍន៍របស់វិស័យជាទំហំនៃការទទួលខុសត្រូវ ដែលច្បាប់កំណត់អោយសំរាប់វិស័យនិមួយៗ ។

៣.៥.៤.២ បេសកកម្ម:

គឺជាការពិពណ៌នាអំពីបេសកកម្មចំពោះមុខដែលវិស័យត្រូវបំពេញ ។ ជាភារៈកិច្ចត្រូវធ្វើក្នុងរយៈពេលមួយកំណត់ ក្នុងរង្វង់នៃការទទួលខុសត្រូវដែលច្បាប់បានកំណត់ ។

៣.៥.៤.៣ ទស្សនៈ

ជាគំនិតយល់ឃើញរបស់វិស័យនិមួយៗ សំរាប់រយៈពេលយូរអង្វែង (ឧ. ១០ឬ២០ឆ្នាំទៅខាងមុខទៀត)។ អាចថាជាគោលដៅអភិវឌ្ឍន៍យូរអង្វែង ១០_២០ឆ្នាំ សំរាប់ការងារអភិវឌ្ឍន៍វិស័យនិមួយៗ។ អាចយល់បានម្យ៉ាងទៀតថា តើអ្នកនឹងឃើញអ្វីកើតមានឡើង ឬមានអ្វីផ្លាស់ប្ដូរខ្លះ ចំពោះវិស័យរបស់អ្នកក្នុងរយៈពេល ១០_២០ឆ្នាំខាងមុខទៀត ។

ឧ. ១០_២០ឆ្នាំខាងមុខ ផលនេសាទពុំអាចបំពេញសេចក្ដីត្រូវការខាងហូបចុកបានទេ ដូច្នេះប្រជារាស្ត្រត្រូវការចិញ្ចឹមត្រី ដើម្បីបំពេញបន្ថែមនូវតំរូវការដែលកំពុងកើនឡើង ។

៣.៥.៤.៤ ស្ថានភាពរបស់វិស័យ (គួរផ្អែកលើពត៌មាន_ស្ថិតិរបស់វិស័យផង)

គឺជាស្ថានភាពជាក់ស្ដែងរបស់វិស័យនិមួយៗដូចជា ៖

_បញ្ហាៈ ទិន្នផលស្រូវទាប(កសិកម្ម), ប្រជារាស្ត្រមានប្រាក់ចំនូលទាប(អភិវឌ្ឍន៍ជនបទ), ការធ្លាក់ចុះនៃវប្បធម៌ខ្មែរ(វប្បធម៌), ភ្ញៀវទេសចរណ៍តិច(ទេសចរណ៍) ...។ល។ ក្នុងនេះអាចលើកឡើងតែបញ្ហាដែលនៅក្នុងរង្វង់នៃការទទួលខុសត្រូវ ឬបើចាំបាច់ណាស់ បញ្ហាដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ការអភិវឌ្ឍន៍វិស័យខ្លួន ដែលមន្ទីរត្រូវដោះស្រាយ និងបញ្ហាដែលនាំអោយបាត់ឱកាស ។

_ឱកាសៈ គឺជាលក្ខណៈអំណោយផល ដែលអាចអោយធ្វើការអភិវឌ្ឍន៍វិស័យបាន ។

ឧ. មានដីច្រើនសំរាប់ពង្រីកដំណាំស្រូវ ប្រាសាទបុរាណសំរាប់ទេសចរណ៍ ជំនួយផ្សេងៗ មានឧបករណ៍សំភារៈ ធនធានមនុស្សគ្រប់គ្រាន់ ... ។ល។

_លទ្ធផលឆ្នាំកន្លងមកៈ គឺជាការរៀបរាប់អំពីលទ្ធផលដែលវិស័យសំរេចបាននាឆ្នាំកន្លងមក ឬជាការអនុវត្តន៍ផែនការអភិវឌ្ឍន៍នាឆ្នាំកន្លងមក ដោយសង្ខេបបំផុត ។

### ៣.៥.៤.៥ ឡុកហ្វ្រេម Logframe

ជាគំរូតារាងមាន១៥ប្រអប់ដែលមានដាក់បញ្ចូលនូវខ្លឹមសារសង្ខេបពេញលេញ នូវផែនការរបស់មន្ទីរនិមួយៗ ។

| ឋានានុក្រមនៃទិសដៅ | និទស្សន៍ ឬ កត្តាចង្អុលបង្ហាញ | មធ្យោបាយផ្ទៀងផ្ទាត់ | ការសន្មត់ ឬ កត្តាខាងក្រៅ |
|---|---|---|---|
| គោលដៅអភិវឌ្ឍន៍ ១ | | | |
| ទិសដៅបន្ទាន់ ២ | | | |
| លទ្ធផល ឬអៅតុត ៣ | | | |
| សកម្មភាព ៤ | ទុន ឬអ៊ីនភុត ៥ | | |

សំគាល់: ➞ លក្ខខ័ណ្ឌបំពេញអោយដើម្បីឈានទៅសំរេចប្រអប់បន្ទាប់

←······· សំរាប់បញ្ជាក់អោយប្រអប់បន្ទាប់

ការជះឥទ្ធិពលនៃកត្តាខាងក្រៅទៅលើប្រអប់ទិសដៅ

នៅក្នុងប្រអប់ទី១ មានអធិប្បាយអំពីគោលដៅអភិវឌ្ឍន៍ ដែលវិស័យនិមួយៗប៉ុនប៉ងសំរេចអោយបានក្នុងរយៈពេលយូរអង្វែង (ជាទូទៅ៥ឆ្នាំ) ។

ជាមួយនិងការដែលត្រូវធ្វើអោយសំរេច នូវជំនាក់កាលខាងលើ នោះក៏ត្រូវបំពេញអោយបាននូវប្រអប់ទី២សិនដែរ ដែលជាទិសដៅបន្ទាន់ ។

ដូចគ្នានេះដែរ ដើម្បីអោយទិសដៅបន្ទាន់អាចសំរេចបាន លុះត្រាតែមន្ទីរ ឬវិស័យធ្វើអ្វីអោយចេញជាលទ្ធផលសិនដែរ ដែលត្រូវបានដាក់នៅក្នុងប្រអប់ទី៣ ហើយដែលពាក្យអង់គ្លេសថា អៅភុត ។

តែដើម្បីអោយអៅភុតនោះអាចសំរេចបាន លុះត្រាតែមានធ្វើសកម្មភាពផ្សេងៗ(ប្រអប់ទី៤) និងទុន ឬអ៊ីនភុត ដែលសរសេរនៅក្នុងប្រអប់ទី៥ ។

ការគិតគូរតាមរបៀបនេះ ហៅថាភាពឡូស៊ីកតាមខ្សែឈរ ។ អាចបកស្រាយពីក្រោមឡើងលើក៏បានដែរ ដូចជា ៖ បើអ៊ីនភុត នៅក្នុងប្រអប់ទី៥ មានគ្រប់គ្រាន់ នោះអាចធ្វើសកម្មភាពនានា នៅក្នុងប្រអប់ទី៤បាន ពេលនោះគេប្រាកដជានឹងទទួលបាននូវអៅភុតក្នុងប្រអប់ទី៣ ហើយមុខជាអាចសំរេចនូវទិសដៅបន្ទាន់ក្នុងប្រអប់ទី២ជាមិនខាន រួចយូរឬឆាប់ មុខជាអាចទៅដល់គោលដៅអភិវឌ្ឍន៍ នៅក្នុងប្រអប់ទី១។

ចំនែកប្រអប់៣ទៀត ដែលនៅជាប់ជួរឈរហៅថានុក្រមទិសដៅ គឺជានិទស្សន៍ (ជួនកាលគេហៅកត្តាសំគាល់ កត្តាចង្អុលបង្ហាញ ឬតួលេខផែនការ) ដែលបញ្ជាក់ន័យអោយប្រអប់ទី១ ទី២ ទី៣ ថាតើគោលដៅជាបរិមាណត្រឹមកំរិតណាដែលមានបំណងទៅអោយដល់នោះ ឬក៏អាចនិយាយថាតើមានអ្វីជាសំគាល់ដើម្បី អោយដឹងថា គោលដៅ ទិសដៅ អៅភុត អាចសំរេចបាន ។ ចំពោះសកម្មភាព និង ទុនគ្មានកត្តាសំគាល់នោះទេ ។

ជួរឈរទី៣ សរសេរចេញជាមធ្យោបាយសំរាប់ផ្ទៀងផ្ទាត់ ថាតើមានមធ្យោបាយណាមួយដែលអាចប្រើសំរាប់ការវាយតំលៃពីទំហំតួលេខដែលទទួលបាននៅពេលអនុវត្តផែនការ ។

ចំពោះជួរឈរទី៤ ចុងក្រោយគេ គឺជាការគិតទុកមុននូវអ្វីដែលអាចនិងកើតមានឡើង ហើយមានឥទ្ធិពលទៅលើការអនុវត្តន៍គំរោងផែនការមិនបានទទួលជោគជ័យ ។ ឧ. ទឹកជំនន់ ខ្យល់ព្យុះ អសន្តិសុខអតិផរណា ការខ្វះការសហការពីស្ថាប័នមានសមត្ថកិច្ច ... ។ល។ គឺជាលក្ខខ័ណ្ឌដែលស្ថិតនៅក្រៅការគ្រប់គ្រងរបស់ម្ចាស់ផែនការ តែមានឥទ្ធិពលជាសំខាន់ទៅលើផែនការ ដែលមិនអោយឈានទៅសំរេចអ្វីៗនៅថ្នាក់បន្ទាប់ (ប្រអប់ទី៥ ទៅ ប្រអប់ទី៤ ទៅ ប្រអប់ទី៣ ទៅ ប្រអប់ទី២ ទៅ ប្រអប់ទី១) ។

បុគ្គលិកផែនការទាំងឡាយ ដែលធ្លាប់បានចូលរួមក្នុងការងារកសាងផែនការអភិវឌ្ឍន៍ខេត្ត នៅក្នុងខេត្តទាំងប្រាំដែលមានកម្មវិធីសិលា សុទ្ធតែបានយល់ និងមានសមត្ថភាពកសាងផែនការវិស័យរបស់ខ្លួនតាមវិធីសាស្ត្រនេះយ៉ាងពិតប្រាកដ ។

### ៣.៥.៤.៦ យុទ្ធសាស្ត្រ

គឺជាផ្លូវដែលវិស័យត្រូវជ្រើសរើស ដើម្បីអោយគោលដៅនិងទិសដៅវិស័យខ្លួនអាចសំរេចបាន ។ វាហាក់ដូចជាសំនួរដែលយើងសួរថា៖ តើត្រូវធ្វើដូចម្តេចដើម្បីទៅដល់បាន ?

ឧ. កសិកម្ម: *ទិសដៅ* បង្កើនផលិតផលឈើហូបផ្លែ ត្រីសាច់ តាមបច្ចេកទេសកសិកម្មថ្មី។

*យុទ្ធសាស្ត្រ* បង្រៀនកសិករគំរូទាំងប្តីទាំងប្រពន្ធ នៅស្ថានីយកសិកម្មផ្ទាល់ ។

បើនិយាយពីការបង្រៀនកសិករ គេអាចបង្រៀនតាមផ្ទះ ដល់ប្តីឬប្រពន្ធកសិករទាំងអស់ ក្នុងភូមិមួយចំនួន ឬ កសិករមួយចំនួនក្នុងភូមិទាំងអស់ ...។ល។ អំពីបច្ចេកទេសកសិកម្ម ដែលមន្ទីរកសិកម្មខេត្ត-ក្រុងអាចជ្រើសយកជំរើសមួយដូចបានជំរាបជូនខាងលើ ។

៣.៥.៤.៧ សេចក្តីសន្និដ្ឋានៈ

ការសន្និដ្ឋានលើផែនការអភិវឌ្ឍន៍វិស័យរបស់ខ្លួន ។

**៣.៥.៥ ជំពូក ៥ "កម្មវិធីវិនិយោគសំរាប់ការអភិវឌ្ឍន៍របស់ខេត្ត" (PDIP)**

គឺជាបញ្ជីសកម្មភាព/គំរោង បែងចែកតាមវិស័យ/អង្គភាពអនុវត្ត ដែលមានបញ្ជាក់តំលៃប៉ាន់ស្មានគំរោង ប្រភពថវិកា ទីកន្លែងអនុវត្តន៍ រយៈពេលអនុវត្តន៍ ...។ល។ (សូមមើលគំរូតារាងភ្ជាប់មកជាមួយនៅក្នុងផ្នែកឧបសម្ព័ន្ធ) ។

## ៣.៦ ផែនទីមូលដ្ឋានសំរាប់ប្រើនៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង

ដើម្បីអោយផែនការមួយ មានលក្ខណៈល្អប្រសើរ ងាយស្រួលប្រើប្រាស់ និងដឹងពីទីតាំងនានារបស់ខេត្តនោះ ការរៀបចំផែនការគួរមានភ្ជាប់ផែនទីមួយចំនួនដូចជា ៖

-ផែនទីមូលដ្ឋាន ដែលមានបង្ហាញពីបណ្តាញផ្លូវ អូរ ស្ទឹង ផ្លូវទឹក និងព្រំដែនរដ្ឋបាលទាំងអស់ដោយមានបញ្ជាក់បង្ហាញពីទីតាំង ការិយាល័យភូមិ ឃុំ ស្រុក ផង ។

-ផែនទីប្រើប្រាស់ដី សំរាប់ទូទាំងខេត្ត ឬញែកចេញដោយឡែកតាមស្រុកនិមួយៗ ។

-ផែនទីបង្ហាញពីទីតាំងសាលារៀន ។

-ផែនទីបង្ហាញទីតាំងមណ្ឌលសុខភាពឃុំ និងមន្ទីរពេទ្យ ។

-ផែនទីបង្ហាញទីតាំងរបស់គំរោង ឬសកម្មភាពអភិវឌ្ឍន៍របស់មន្ទីរ ភូមិ ឃុំ អង្គការក្រៅរដ្ឋាភិបាល... ។ល។ ដែលបានអនុវត្តហើយ និងកំពុងបន្តអនុវត្ត ។

## ៣.៧ ការធ្វើសមាហរណកម្មផែនការឃុំជាមួយនិងវិស័យ

### ក. ការកំណត់តួនាទីផ្សេងៗនិងការត្រៀមរៀបចំជាមុន

ឆ្លងតាមបទពិសោធន៍ដែលបានធ្វើជាក់ស្តែងនៅក្នុងខេត្តសិលាទាំងប្រាំកន្លងមក ការធ្វើសមាហរណកម្មផែនការថ្នាក់ឃុំជាមួយនឹងផែនការរបស់វិស័យនានា ត្រូវបានរៀបចំឡើងតាមរយៈសិក្ខាសាលា ដែលចាំបាច់ត្រូវមានការទទួលខុសត្រូវរៀងខ្លួនតាមលំដាប់ថ្នាក់ ដូចជា គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត មន្ទីរផែនការខេត្ត បណ្តាមន្ទីរជំនាញ គណៈកម្មការអភិវឌ្ឍន៍ស្រុក គណៈកម្មការអភិវឌ្ឍន៍ឃុំ(គ.អ.ឃ) IOs/NGOs ។

តួនាទីទាំងនោះមានដូចជា ៖

### ៣.៧.១ តួរនាទីនិងការទទួលខុសត្រូវរបស់គណៈកម្មាធិការប្រតិបត្តិ

១. រៀបចំការប្រជុំថ្នាក់ខេត្តដើម្បីកសាងពង្រាងផែនការវិនិយោគ
២. បញ្ជាអោយមន្ទីរជំនាញនានា និងគ.អ.ឃ រៀបចំផែនការវិនិយោគរបស់ឃុំនិងមន្ទីរជំនាញខ្លួន
៣. ជួយក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យរបស់មន្ទីរនានា
៤. ចូលរួមក្នុងការប្រជុំធ្វើសមាហរណកម្មនៅថ្នាក់ស្រុក
៥. ធ្វើសេចក្តីបញ្ជាក់លើផែនការវិនិយោគ ដើម្បីដាក់ជូនគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត
៦. ប្រកាសប្រាប់ទៅវិស័យ និងមូលដ្ឋានអំពីថវិកាវិនិយោគ

### ៣.៧.២ តួនាទីនិងការទទួលខុសត្រូវរបស់មន្ទីរផែនការខេត្ត-ក្រុង

១. សហការជាមួយលេខាធិការដ្ឋាន ដើម្បីរៀបចំនិងដាក់ជូននូវលក្ខណៈវិនិច្ឆ័យនៃការងារសមាហរណកម្មទៅគណៈកម្មាធិការប្រតិបត្តិ ដើម្បីអាចទទួលបាននូវការអនុម័តពីគ.ប្រ ។
២. សហការជាមួយបណ្តាមន្ទីរជំនាញនានា ដើម្បីធ្វើការត្រួតពិនិត្យនិងវាយតំលៃពីលទ្ធផលសមាហរណកម្មផែនការវិនិយោគ ។
៣. ទទួលផែនការអភិវឌ្ឍន៍មូលដ្ឋានពីលេខាធិការដ្ឋាន និងផ្ញើរទិន្នន័យទៅកាន់មន្ទីរជំនាញនានា មុនពេលមន្ទីរជំនាញរៀបចំបានជាផែនការវិនិយោគវិស័យរបស់ខ្លួន ។
៤. ជាសេនាធិការរបស់គ.អ.ជ.ខ ក្នុងកិច្ចទំនាក់ទំនងអន្តរវិស័យនៅថ្នាក់ខេត្ត-ក្រុង និងសំរបសំរួលការងារសមាហរណកម្មរវាងមន្ទីរផ្សេងៗ ជាមួយនិងមូលដ្ឋាននៅថ្នាក់ស្រុក ។
៥. ធ្វើសេចក្តីបញ្ជាក់និងធានាថា ផែនការវិនិយោគ ពិតជាបានធ្វើសមាហរណកម្មរួចជាស្រេច ។
៦. ទំនាក់ទំនងផ្តល់ពត៌មាន ស្តីពីលទ្ធភាពនៃហិរញ្ញប្បទាននានា ដល់បណ្តាមន្ទីរ មូលដ្ឋាន NGOs និងIOs ដ៏ទៃទៀត ។
៧. រៀបចំប្រមូលផ្តុំនិងចងក្រងឯកសារ ស្តីពីដំណើរការសមាហរណកម្ម ។

### ១.៣ តួនាទីនិងការទទួលខុសត្រូវរបស់បណ្តាមន្ទីរជំនាញនៅខេត្ត-ក្រុង

១. ទទួលនិន្នន័យពីមន្ទីរផែនការដើម្បីរៀបចំផែនការវិនិយោគរបស់មន្ទីរខ្លួន ។
២. ពិភាក្សាអំពីបញ្ជីសកម្មភាពនានាជាមួយឃុំសំរាប់ធ្វើសមាហរណកម្ម ។

៣. ជ្រើសរើសយកឃុំអាទិភាព ដែលសមស្របទៅនិងសមត្ថភាពថវិកាដែលវិស័យខ្លួនមាន ។

៤. រៀបចំការឧទ្ទេសនាមបង្ហាញរបស់វិស័យខ្លួនចំពោះឃុំ ។

៥. កំណត់ទីតាំងអនុវត្តន៍គំរោងរបស់វិស័យនៅក្នុងឃុំ ។

៦. រៀបចំត្រៀមធ្វើកិច្ចព្រមព្រៀងជាមួយគណៈកម្មការអភិវឌ្ឍន៍ស្រុក ទៅលើក្របខ័ណ្ឌការងារជាជំនួយដល់ឃុំ ។

៧. ជូនផែនការវិនិយោគរបស់វិស័យ ទៅគណៈកម្មាធិការប្រតិបត្តិតាមរយៈមន្ទីរផែនការខេត្ត-ក្រុង។

៨. ផ្តល់បុគ្គលិកបច្ចេកទេស សំរាប់បំរើសេវានានានៅក្នុងឃុំ ។

១.៤ តួនាទីនិងការទទួលខុសត្រូវរបស់គណៈកម្មការអភិវឌ្ឍន៍ស្រុក

១. ចូលរួមប្រជុំនៅថ្នាក់ខេត្ត-ក្រុង ជាមួយបណ្តាវិស័យ និងតំណាងគណៈកម្មការមូលដ្ឋាននានា ។

២. ចុះហត្ថលេខាលើអនុស្សារណៈជាមួយបណ្តាវិស័យ លើសមាហរណកម្មរបស់គ.អ.ឃ ។

៣. ទទួលខុសត្រូវចំពោះការផ្តើមបើកសិក្ខាសាលាស្តីពីសមាហរណកម្មផែនការ រវាងបណ្តាវិស័យជាមួយនិងឃុំ ។

៤. ចូលរួមអនុវត្តការតាមដាននិងវាយតម្លៃជាមួយបណ្តាវិស័យ IOs, NGOs ទៅលើលទ្ធផលទទួលបានរបស់គ.អ.ឃ ។

៥. ផ្សព្វផ្សាយគោលការណ៍រួមនៃការធ្វើសមាហរណកម្មផែនការ ដល់គ.អ.ឃទាំងអស់ ។

៦. ប្រមូលនិងធ្វើការផ្សព្វផ្សាយពត៌មានផ្សេងៗ ។

១.៥ តួនាទីនិងការទទួលខុសត្រូវរបស់ឃុំ

១. ផ្តល់ទិន្នន័យសេដ្ឋកិច្ច-សង្គមកិច្ច ទៅដល់បណ្តាវិស័យ ។

២. ចូលរួមក្នុងការងារធ្វើសមាហរណកម្មផែនការ ។

៣. ធ្វើកិច្ចព្រមព្រៀងការងារជាមួយនិងបណ្តាវិស័យដែលពាក់ព័ន្ធ ។

៤. ពិនិត្យមើលដោយប្រយោល ទៅលើការគ្រប់គ្រងហិរញ្ញវត្ថុនៃគំរោងនានារបស់វិស័យ ដែលបានធ្វើសមាហរណកម្មជាមួយផែនការរបស់ខ្លួន ។

៥. ផ្តល់ហិរញ្ញប្បទានគាំទ្រទៅដល់ភូមិនានា សំរាប់អនុវត្តន៍គំរោង ។

៦. តាមដានការអនុវត្តន៍ និងការងារហិរញ្ញកិច្ចរបស់ភូមិ ។

៧. ដាក់ជូនផែនការការងាររបស់ឃុំ ដល់គណៈកម្មការអភិវឌ្ឍន៍ស្រុក ។

៨. ផ្តល់ពត៌មានអំពីលទ្ធផលអនុវត្តន៍បានជាក់ស្តែង សំរាប់ការតាមដាននិងវាយតំលៃ ។

១.៦ តួនាទីនិងការទទួលខុសត្រូវរបស់ IOs និង NGOs

១. ចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ខេត្ត-ក្រុង និងស្រុក ។

២. សិក្សាទិន្នន័យសេដ្ឋកិច្ច-សង្គមដែលមាន ។

៣. គាំទ្រគំរោងនានា ក្នុងករណីដែលវិស័យនិងគណកម្មការអភិវឌ្ឍន៍ឃុំនានាមានការខ្វះខាតថវិកា ។

ការអធិប្បាយទាំងប៉ុន្មានមកខាងលើនេះ គ្រាន់តែជាការព្រមព្រៀងរួមមួយដែលបានកំនត់ និងបានយកទៅអនុវត្តតាមខេត្តទាំងប្រាំក្នុងកម្មវិធីសិលា ។ នេះក៏មិនមែនជាបទបញ្ញត្តិដែលដាក់កំហិតដោយក្រសួងផែនការនោះទេ ។ ម៉្យាងទៀតដោយយល់ឃើញថា បទពិសោធន៍ស្តីពីការកសាងផែនការវិមជ្ឈការ ដែលបានរៀបចំឡើងដោយបុគ្គលិក-មន្ត្រីរាជការជាប់ពាក់ព័ន្ធនិងកម្មវិធីសិលា មានលក្ខណៈល្អប្រសើរអាចទទួលយកបាននោះ ទើបអគ្គនាយកដ្ឋានផែនការដកស្រង់យកមកបញ្ចូលគ្រាន់ទុកជាគតិបណ្ឌិត ។

ការសំរបសំរួលការងារធ្វើសមាហរណកម្មផែនការនេះ ទាមទារអោយមានការត្រៀមរៀបចំអោយបានល្អប្រសើរជាមុន ដូចជា ៖

I) ការប្រជុំរួមនៅមន្ទីរផែនការខេត្ត-ក្រុង

១- ការប្រជុំនេះរៀបចំឡើង និងសំរបសំរួលដោយ មន្ទីរផែនការខេត្ត-ក្រុងតែម្តង

២- អ្នកចូលរួមគឺ : មន្ត្រីផែនការថ្នាក់ស្រុក មកពីគ្រប់ស្រុកក្នុងខេត្ត-ក្រុង និងមន្ត្រីផែនការ មកពីគ្រប់មន្ទីរជំនាញក្នុងខេត្ត-ក្រុង ។

៣- របៀបវារៈសំខាន់ៗក្នុងការប្រជុំនេះរួមមាន :

ក- ការផ្សព្វផ្សាយនិងពិភាក្សាលើរូបភាព នៃការធ្វើសមាហរណកម្មផែនការថ្នាក់ឃុំ ដោយមានការបញ្ជាក់ច្បាស់ពីតួនាទីដែលមន្ត្រីផែនការស្រុក និងមន្ត្រីផែនការតាមមន្ទីរជំនាញនានាត្រូវចូលរួមសហការអនុវត្ត ដូចបានអធិប្បាយជូនស្រាប់នៅផ្នែកខាងលើ ។

ខ- ណែនាំនិងពិភាក្សាលើទំរង់នៃតារាងគំរូនានា ដែលឃុំនិមួយៗត្រូវបំពេញសំរាប់សកម្មភាពដែលបាននិងកំពុងធ្វើក្នុងឆ្នាំនេះ និងគំរោងស្នើឡើងសំរាប់ឆ្នាំក្រោយ។

គ- កំណត់កាលវិភាគសំរាប់ចុះធ្វើសមាហរណកម្ម ដោយលៃទុកចន្លោះពេលសំរាប់មន្ត្រីខ្សែបណ្តោយជំនាញថ្នាក់ស្រុក និងមេឃុំនានារៀបចំខ្លួន ។

**II)** ការប្រជុំរបស់មន្ទីរជំនាញនិមួយៗជាមួយខ្សែបណ្តោយជាសេនាធិការខ្លួនថ្នាក់ស្រុក :

១_ការប្រជុំនេះរៀបចំនៅតាមមន្ទីរជំនាញនានា និងដឹកនាំសំរបសំរួលដោយមន្ត្រីផែនការរបស់មន្ទីរជំនាញនិមួយៗផ្ទាល់ ។

២_អ្នកចូលរួមមាន មន្ត្រីដែលជាខ្សែបណ្តោយរបស់មន្ទីរ ប្រចាំនៅតាមស្រុកនានា គ្រប់ស្រុកក្នុងខេត្ត_ក្រុង ។

៣_ របៀបវារៈសំខាន់ៗមាន :

ក_ ណែនាំពីដំណើរការសមាហរណកម្មផែនការឃុំនិងវិស័យ ។

ខ_ កំនត់ពីតួនាទីរបស់មន្ត្រីខ្សែបណ្តោយដែលជាសេនាធិការមន្ទីរ ក្នុងដំណើរការនេះ។

គ_ ផ្សព្វផ្សាយពីគំរោងនានារបស់មន្ទីរដែលបាននិងកំពុងធ្វើ និងគំរោងសំរាប់ឆ្នាំក្រោយនៅថ្នាក់ស្រុក_ឃុំ ដើម្បីមន្ត្រីខ្សែបណ្តោយមានមូលដ្ឋានគ្រប់គ្រាន់ សំរាប់ចូលរួមក្នុងសមាហរណកម្មផែនការឃុំ ។

ឃ_ផ្សព្វផ្សាយពីកាលវិភាគនៃការចុះធ្វើសមារណកម្មរបស់មន្ត្រីផែនការ នៅតាមស្រុកនិមួយៗ ។

**III)** ការប្រជុំត្រៀមលក្ខណៈនៅមូលដ្ឋាន

ដើម្បីអោយសិក្ខាសាលាសមាហរណកម្មផែនការ អាចប្រព្រឹត្តទៅបានលឿនប្រកបដោយប្រសិទ្ធភាពខ្ពស់នោះ ចាំបាច់ត្រូវមានការរៀបចំខ្លួនជាមុនអោយហើយស្រេចនៅមូលដ្ឋាន ។ ការប្រជុំត្រៀមរៀបចំនេះត្រូវធ្វើអោយបានមុនយ៉ាងហោចណាស់ក៏២ថ្ងៃ មុនពេលសិក្ខាសាលាសមាហរណកម្មបានចាប់ផ្តើម ។ នៅក្នុងពេលប្រជុំត្រៀមនេះ ចាំបាច់ត្រូវ ៖

- សំរបសំរួលដោយ: ប្រធានគ.អ.ឃ និងក្រុមសំរបសំរួលស្រុក
- ចូលរួមដោយ : គ្រប់សមាជិកគ.អ.ឃ និងតំនាងគ.អ.ភ ព្រមទាំង NGOs
- ធ្វើឡើងរយៈពេល : ១_២ ថ្ងៃ
- ពិភាក្សាអំពី : បញ្ហាជ្រើសរើសតំណាង សំរាប់ចូលរួមសិក្ខាសាលាសមាហរណកម្មផែនការនៅស្រុក ចំនួន៣នាក់ (បុរស២នាក់ និងនារីម្នាក់) ។
- ក្តាប់ពត៌មានរបស់ភូមិទាំងឡាយ សំរាប់យកទៅជជែកជាមួយបណ្តាវិស័យ មានដូចជា ៖
    * សកម្មភាពនានាកន្លងមក និងការជះឥទ្ធិពល (ផលប៉ះពាល់)
    * គោលដៅអភិវឌ្ឍន៍របស់ភូមិ_ឃុំ និងស្ថានភាពបច្ចុប្បន្ន
    * សកម្មភាពអភិវឌ្ឍន៍ជាអាទិភាពនាពេលអនាគត (១ឆ្នាំ)

រាល់សំណើផ្សេងៗ ដែលបំរុងនិងលើកយកទៅស្នើឡើង នៅក្នុងសិក្ខាសាលាសមាហរណកម្មនៅស្រុក គប្បីសរសេរក្នុងផ្ទាំងក្រដាសធំៗអោយបានរួចជាស្រេច ដើម្បីងាយស្រួលក្នុងការឡើងបង្ហាញ ។

**ខ) សិក្ខាសាលាសមាហរណកម្មនៅស្រុក**

ក្រោយពីបានត្រៀមរៀបចំរួចរាល់ និងបានផ្សព្វផ្សាយពីកាលវិភាគនៃសកម្មភាពការងារ ក៏ដូចជាចែកជូនលិខិតអញ្ជើញចូលរួមទៅតាមមុខសញ្ញានោះ សិក្ខាសាលានៅក្នុងបរិវេណសាលាស្រុក ត្រូវបានរៀបចំឡើង រយៈពេលចំនួន២ទៅ៣ថ្ងៃ ទៅតាមវិសាលភាពនៃស្រុកនិមួយៗ នៅក្នុងកំឡុងខែសីហា_កញ្ញា ជារៀងរាល់ឆ្នាំ ។ មានខេត្តខ្លះបានសាកល្បងរួចទៅហើយ ក្នុងការរៀបចំធ្វើសិក្ខាសាលាសមាហរណកម្មផែនការនេះនៅថ្នាក់ឃុំ។ ប៉ុន្តែ បានជួបប្រទះនិងការលំបាកជាច្រើន ដូចជា មធ្យោបាយធ្វើដំណើរ ពេលវេលា ការចូលរួមមិនពេញលេញ និងត្រូវចំណាយថវិកាច្រើនទៀតផង ...។ល។ អាស្រ័យហេតុនេះទើបមានការព្រមព្រៀងគ្នាមួយថា សិក្ខាសាលាសមាហរណកម្មផែនការមូលដ្ឋាននិងផែនការវិស័យ ត្រូវតែរៀបចំធ្វើឡើងនៅថ្នាក់ស្រុក ។ ព្រោះថា ៖

- ងាយស្រួលក្នុងការធ្វើដំណើរមកជួបជុំ សំរាប់ទាំងពីរទិសគឺ ឃុំនិងខេត្ត ។
- ផ្តល់ឱកាសអោយថ្នាក់ស្រុកចូលរួមធ្វើសមាហរណកម្ម ។
- នៅថ្នាក់ស្រុកមានមន្រ្តីគ្រប់គ្រងតាមខ្សែបណ្តោយរបស់មន្ទីរជំនាញស្ទើរគ្រប់វិស័យ ។
- វត្តមានជាប្រចាំនៃបុគ្គលិកស្រុកនិងការចំណាយថវិកាតិច អាចធានាអោយមាននិរន្តរភាព ។

ដើម្បីមានភាពងាយស្រួលក្នុងការចាត់ចែងរៀបចំ ការពិពណ៌នាលំអិតខាងក្រោមនេះ នឹងអាចជួយជាលំនាំសំរាប់អ្នកសំរបសំរួលទាំងឡាយ ។

ខ១) អ្នកចូលរួម:

| **អ្នកចូលរួម** | **ភារកិច្ចទទួលខុសត្រូវ** |
|---|---|
| _ ថ្នាក់ដឹកនាំមន្ទីរពាក់ព័ន្ធ | _ ចរចារនិងព្រមព្រៀងលើលទ្ធផលពិភាក្សា |
| _ ជនបង្គោលផែនការវិស័យ | _ ជួយចូលរួមយោបល់និងកត់ត្រា |
| _ មន្ត្រីជំនាញពីមន្ទីរនានា | _ ផ្តល់យោបល់បច្ចេកទេសសំរាប់គាំទ្រការចរចារ |
| _ មន្ទីរផែនការ | _ ដឹកនាំនិងសំរបសំរួលសិក្ខាសាលានិងកត់ត្រារាល់កិច្ចព្រមព្រៀង |
| _ ក្រុមសំរបសំរួលខេត្ត_ក្រុង | _ ជួយ គ.អ.ភ ក្នុងការការពារគំរោង |

| | |
|---|---|
| - ជំនួយការគំរោងនានា/ ជំនួយការផែនការ(បើមាន) | - ដើរតួនាទីផ្តល់យោបល់ប្រឹក្សាក្នុងសិក្ខាសាលា |
| - អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ និងភ្នាក់ងារនានារបស់សហប្រជាជាតិ (បើមាន) | - ចរចារនិងព្រមព្រៀង |
| - អភិបាលស្រុក | - ជាគណៈអធិបតី ចរចារដើម្បីជួយគាំទ្រឃុំខ្លួន ផ្តល់សំភារៈប្រើប្រាស់ផ្សេងៗ កោះអញ្ជើញការិយាល័យស្រុកពាក់ព័ន្ធនានា ឃុំ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ។ |
| - មន្ត្រីជំនាញស្រុក | - ផ្តល់ព័ត៌មាន និងជួយគាំទ្រការជជែកពិភាក្សា ។ |
| - ក្រុមសំរបសំរួលស្រុក | - ជួយគាំទ្រ គអយ ក្នុងការការពារសំណើគំរោង ។ |
| - គ.អ.ឃ(មាន៤នាក់) ដែលជាប្រធានម្នាក់ លេខាម្នាក់ ហិរញ្ញិកម្នាក់ និងតំណាងជិនឌ័រម្នាក់ (បើមាន) | - ការពារគំរោង ចរចារ និងទទួលយកនូវការព្រមព្រៀង ។ |

១៦) របៀបវារៈនៃសិក្ខាសាលា :

សិក្ខាសាលាដែលរៀបចំឡើងនេះ មានរបៀបវារៈជាសំខាន់ដូចតទៅ ៖

| | |
|---|---|
| ១. អភិបាលស្រុក | បើកកម្មវិធីសិក្ខាសាលា ។ |
| ២. ប្រធានការិយាល័យផែនការស្រុក | ប្រកាសហេតុ របៀបវារៈនៃសិក្ខាសាលា គោលបំណងនៃសិក្ខាសាលា និងវិធីសាស្ត្រធ្វើសិក្ខាសាលា ។ |
| ៣. គអឃ | ឡើងរាយការណ៍អំពីលទ្ធផល និងសកម្មភាពដែលបានអនុវត្តកន្លងមក ហើយនិងគំរោងផែនការឆ្នាំថ្មីរបស់ខ្លួន ។ |
| ៤. មន្ត្រីការិយាល័យជំនាញថ្នាក់ស្រុក | ឡើងរាយការណ៍អំពីលទ្ធផលការងារកន្លងមក ។ |
| ៥. បណ្តាមន្ទីរជំនាញ | ឡើងបង្ហាញ ពីពង្រាងផែនការវិស័យ ដែលទាក់ទងទៅនឹងផែនការវិនិយោគ ព្រមទាំងរំលឹកឡើងវិញនូវគោលការណ៍និងលក្ខណៈវិនិច្ឆ័យនានា ។ |
| ៦. វិស័យនានា IOs, NGOs | ចាប់ពិភាក្សា ចរចារ ព្រមព្រៀង ជាមួយឃុំ(១ឃុំម្តងៗ) ។ |
| ៧. ការិយាល័យផែនការស្រុក | ធ្វើការបូកសរុបពីលទ្ធផលនៃការព្រមព្រៀងជាបណ្តោះអាសន្នរវាង វិស័យ អង្គការជាតិនិងអន្តរជាតិ និងឃុំនានា ។ |
| ៨. អភិបាលស្រុក | បិទកម្មវិធី ។ |

១៣) ឯកសារចាំបាច់នានាសំរាប់ប្រើក្នុងសិក្ខាសាលាមាន៖

- តារាងចំណាត់ថ្នាក់ភាពក្រីក្រ (បើមាន)
- ផែនការអភិវឌ្ឍន៍ឃុំ (តារាងអាទិភាព)
- ផែនទីផែនការ (បង្ហាញពីទីតាំងបំរុងអនុវត្តសកម្មភាព)
- របាយការណ៍អនុវត្តន៍កន្លងមក
- លក្ខណៈវិនិច្ឆ័យ/គោលនយោបាយរបស់វិស័យ
- ពង្រាងផែនការវិស័យ
- ទិន្នន័យបច្ចេកទេស
- ផែនទីបង្ហាញទីតាំងអនុវត្តន៍គំរោង(ស្រុក)

១៤) អ្នកសំរបសំរួលនិងប្រធានអង្គសិក្ខាសាលា:

១) អ្នកសំរបសំរួល : ប្រធានមន្ទីរផែនការខេត្ត-ក្រុង

២) ប្រធានអង្គប្រជុំ : អភិបាលស្រុក ឬប្រធានគណៈកម្មការអភិវឌ្ឍន៍ស្រុក

១៥) ការឡើងបង្ហាញនៅក្នុងសិក្ខាសាលា:

- *ការឡើងបង្ហាញរបស់ គ.អ.ស (បើមាន)*
    * ក្របខ័ណ្ឌនៃកិច្ចអភិវឌ្ឍន៍ស្រុក
    * បទពិសោធន៍កន្លងមក
- *ការឡើងបង្ហាញរបស់ គ.អ.ឃ*
    * សកម្មភាពកន្លងមក និងការជះឥទ្ធិពល
    * គោលដៅ និងស្ថានភាពបច្ចុប្បន្នរបស់ភូមិ-ឃុំ
    * សកម្មភាពអនាគត (ដោយមានបញ្ជាក់ទីតាំងនៃសកម្មភាព) សំរាប់មួយឆ្នាំ
- *ការបង្ហាញរបស់ NGOs*
    * សកម្មភាពកន្លងមក និងការជះឥទ្ធិពល
    * សកម្មភាពអនាគត និងគោលនយោបាយ
    * ទីតាំងធ្វើសកម្មភាពផ្សេងៗ និងថវិកា

- *ការបង្ហាញរបស់បណ្ដាវិស័យ*

  * គោលនយោបាយជាតិ និងគោលនយោបាយខេត្ត-ក្រុង ដើម្បីឆ្លើយតបទៅនឹងតំបន់គោលដៅ ។
  * លក្ខណៈវិនិច្ឆ័យរបស់វិស័យ ។
  * សកម្មភាពអនាគត និងអាទិភាពផ្សេងៗ ។
  * ធនធានផ្សេងៗ ។
  * ភាពជាម្ចាស់នៃសកម្មភាព និងការអនុវត្តន៍ ។

ការអធិប្បាយលំអិតទាំងប៉ុន្មានខាងលើនេះ គ្រាន់តែចង់បង្ហាញពីរបៀបរៀបចំ ដ៏ល្អិតល្អន់របស់ខេត្តទាំងប្រាំដែលកំពុងអនុវត្តកម្មវិធីសិលា ដើម្បីទទួលបានផែនការវិនិយោគខេត្តមួយ ដែលមានការចូលរួមពិតប្រាកដពីមូលដ្ឋាន និងមានចរិតវិមជ្ឈការទៀតផង ។ បច្ចុប្បន្ន លទ្ធផលនៃការរៀបចំផែនការវិនិយោគខេត្តសិលាទាំងប្រាំ កំពុងបានទទួលការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកផ្ដល់ជំនួយអន្តរជាតិនានា ក្នុងនោះមានទាំងកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិផង ។

# IV ឧបសម្ព័ន្ធ

## ៤.១ តារាងគំរូៈ កម្មវិធីវិនិយោគសំរាប់កិច្ចអភិវឌ្ឍន៍ខេត្ត (PDIP)

| លំដាប់ អាទិភាព | មន្ទីរ-ការិយាល័យ ទទួលខុសត្រូវ | ទីតាំងគំរោង ឃុំ-ស្រុក | ឈ្មោះគំរោង-ការពិពណ៌នា សង្ខេបអំពីគំរោង | ពេលចាប់ផ្ដើមនិង រយៈពេលអនុវត្តន៍ | សមត្ថភាពក្នុងប្លង់ ឬ ទំហំគំរោង | ថវិកាប៉ាន់ស្មាន សំរាប់១ឆ្នាំ | ថវិកាសរុបសំរាប់ កម្មវិធីទាំងមូល | ប្រភពជំនួយ ឬប្រភពថវិកា | អ្នកទទួលផល |
|---|---|---|---|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

## ៤.២ តារាងគំរូៈ ឡូក់ហ្វ្រេមតាមបណ្តាវិស័យ

| ឋានានុក្រមនៃទិសដៅ | និទស្សន៍ឬកត្តាសំគាល់ | មធ្យោបាយផ្ទៀងផ្ទាត់ | ការសន្មត កត្តាខាងក្រៅ |
|---|---|---|---|
| គោលដៅនៃកិច្ចអភិវឌ្ឍន៍ | | | |
| ទិសដៅបន្ទាន់ | | | |
| លទ្ធផល | | | |
| សកម្មភាព | ធនធាន | | លក្ខខណ្ឌដំបូង |

## ៤.៣ តារាងគំរូ : បញ្ជីគំរោងដែលបាននិងកំពុងដំណើរការក្នុងឆ្នាំ ...........

ស្រុក : ................................................

ឃុំ : ................................................

| ល.រ | ឈ្មោះគំរោងឬសកម្មភាពអភិវឌ្ឍន៍នានា | ទីកន្លែងអនុវត្តន៍និងលេខកូដភូមិសាស្ត្រ | ប្រភពជំនួយ | លទ្ធផលសំរេច |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ៤.៤ តារាងគំរូ : បញ្ជីសំណើគំរោងអភិវឌ្ឍន៍ជាអាទិភាពរបស់ឃុំ សំរាប់ឆ្នាំ ..........

ស្រុក : ............................................

ឃុំ : ............................................

| ល.រ | ឈ្មោះគំរោងឬសកម្មភាពអភិវឌ្ឍន៍ស្នើឡើង | អាទិភាព | ទីកន្លែងអនុវត្តន៍និងលេខកូដភូមិសាស្ត្រ | ចំនួនអ្នកទទួលផល |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ៤.៥ តារាងគំរូ: ផែនការការងារស្រុកប្រចាំត្រីមាសទី .....ឆ្នាំ ........... របស់ស្រុក ...........

| ល.រ | ឈ្មោះគំរោង | សកម្មភាព | ទីកន្លែងអនុវត្តន៍និងលេខកូដភូមិសាស្រ្ត | រយៈពេលគំរោង | | កាលវិភាគអនុវត្តន៍ | | | ថវិកា | ប្រភពថវិកា | ការិ/បុគ្គលិក អ្នកអនុវត្តន៍ | អ្នកទទួលផល |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ផ្តើម | បញ្ចប់ | មករា | កុម្ភៈ | មិនា | | | | |
| ១ | ២ | ៣ | ៤ | ៥ | | ៦ | | | ៧ | ៨ | ៩ | ១០ |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |




# SEILA 1999 Target Area

SEILA: A Royal Government of Cambodia Programme in Decentralized Planning, Financing and Management of Provincial Development supported by the UNDP/CARERE Project

- Provincial centre
- District centre
- Provincial border
- District border

Target Areas

- Reconciliation
- Other



CARERE GIS Unit, 12 February 1999




## SEILA Target Area 1999

| Provinces | Districts | Communes | Villages | Population |
|---|---|---|---|---|
| 1- Siem Reap | 11 | 29 | 265 | 182,480 |
| 2- Banteay Meanchey | 9 | 39 | 380 | 285,000 |
| 3- Battambang | 9 | 28 | 218 | 262,624 |
| 4- Pursat | 5 | 13 | 139 | 100,523 |
| 5- Rattanakiri | 6 | 13 | 61 | 22,377 |
| **Total** | **40** | **122** | **1063** | **853,004** |

## ៤.៧ ដំណើរការកសាងផែនការមូលដ្ឋាន
## (LPP Process)

### ១. សេចក្តីផ្តើម

ឯកសារនេះសង្ខេបអំពីកិច្ចព្រមព្រៀងនានា ដែលបានធ្វើឡើង ចំពោះដំណើរការកសាងផែនការមូលដ្ឋាន ដោយផ្អែកលើលទ្ធផលនៃការពិនិត្យឡើងវិញនូវដំណើរការកសាងផែនការមូលដ្ឋាន ដែលបានធ្វើឡើងចាប់ពីខែមេសា ដល់ ខែកញ្ញា ឆ្នាំ១៩៩៨ ។ ការពិនិត្យឡើងវិញនេះរួមបញ្ចូលទាំងការត្រួតពិនិត្យប្រកបដោយលក្ខណៈស៊ីជំរៅ ធ្វើឡើងដោយក្រុមស្រាវជ្រាវពីខាងក្រៅ ការវាយតំលៃរបស់ខេត្តនៅថ្នាក់ភូមិឃុំ និងនៅថ្នាក់ខេត្ត ដែលរៀបចំឡើងដោយបុគ្គលិកយៃរេវ និងបុគ្គលិកកម្មវិធីសិលាតាមខេត្តនិមួយៗ និងរួមបញ្ចូលទាំងលទ្ធផលនៃការធ្វើសិក្ខាសាលានៅខេត្តពោធិសាត់ ក្នុងខែសីហា ហើយនិងរបាយការណ៍របស់បេសកកម្មវាយតំលៃUNCDF/AIT នៅចុងខែសីហាផងដែរ ។

អគ្គនាយកដ្ឋាយផែនការលើកយកសេចក្តីដកស្រង់សង្ខេបនេះ មកកែសំរួលនិងចងក្រងបញ្ចូលក្នុងសៀវភៅនេះ ដើម្បីបានជាមូលដ្ឋានសំរាប់អ្នករៀបចំសំរបសំរួលកសាងផែនការមូលដ្ឋាននានា ពិនិត្យពិចារណានិងអនុវត្ត ក្នុងករណីចាំបាច់ផ្សេងៗ ។ ដោយសារចំណេះដឹងនៅមូលដ្ឋានភូមិ_ឃុំ មិនដូចមន្ត្រីរាជការនៅថ្នាក់ស្រុក ខេត្ត នោះដំណើរការដែលបានរៀបចំឡើងសំរាប់កសាងផែនការមូលដ្ឋាន ក៏មានលក្ខណៈខុសគ្នាពីការកសាងផែនការអភិវឌ្ឍន៍ខេត្តផងដែរ ។

### ២. ដំណើរការកសាងផែនការមូលដ្ឋាន

ការសង្ខេបពីជំហាននានាក្នុងដំណើរការកសាងផែនការមូលដ្ឋាន

| ភូមិ_ឃុំគោលដៅថ្មី (ដំណើរការពេញលេញ) | ភូមិ_ឃុំកំពុងដំណើរការ(ការពិនិត្យឡើងវិញ) |
|---|---|
| ១.១ ការប្រជុំរបស់គ.អ.ជ.ខ ដើម្បីធ្វើការវិភាជន៍នូវមូលនិធិអភិវឌ្ឍន៍មូលដ្ឋាន(LDF) ចំពោះឃុំ ។ | .១ ការប្រជុំរបស់គ.អ.ជ.ខ ដើម្បីធ្វើការវិភាជន៍នូវមូលនិធិអភិវឌ្ឍន៍មូលដ្ឋាន(LDF)ចំពោះឃុំ។ |
| ១.២ ការប្រជុំគ.អ.ឃ/គ.អ.ភ ដើម្បីឧទ្ទេសនាមដំបូងនូវដំណើរការកសាងផែនការមូលដ្ឋាន ។ | .២ ការប្រជុំគ.អ.ឃ/គ.អ.ភ : ការបំពាក់បំប៉ន និង ការប្រជុំសើរើជាថ្មីសារឡើងវិញ ។ |
| ១.៣ ការប្រជុំគ.អ.ភ/ភូមិ: គោលដៅអនាគតរបស់ភូមិ និងការប្រមូលទិន្នន័យភូមិ ។ | .៣ មិនចាំបាច់ ។ |
| ១.៤ ផែនការសកម្មភាពរបស់ភូមិសំរាប់ពេលអនាគត (ពីមុនហៅថា ទំរង់បែបបទទី១ – Form I ) ។ | .៤ ការប្រជុំគ.អ.ភ/ភូមិ ដើម្បីពិនិត្យឡើងវិញនូវផែនការសកម្មភាពរបស់ភូមិសំរាប់ពេលអនាគត |

| | |
|---|---|
| ១.៥ ផ្តល់សុពលភាពចំពោះផែនការសកម្មភាពរបស់ភូមិសំរាប់ពេលអនាគត ។ | .៥ មិនចាំបាច់ |
| ១.៦ សិក្ខាសាលាគ.អ.ឃ ដើម្បីរៀបចំបង្កើតជាផែនការអភិវឌ្ឍន៍ឃុំ ។ | .៦ សិក្ខាសាលាគ.អ.ឃ ដើម្បីពិនិត្យមើលឡើងវិញចំពោះផែនការអភិវឌ្ឍន៍ឃុំ ។ |
| .៧ ការប្រជុំគ.អ.ភ/ភូមិ ដើម្បីផ្តល់ពត៌មានស្តីអំពីផែនការអភិវឌ្ឍន៍ឃុំ ។ | .៧ ការប្រជុំគ.អ.ភ/ភូមិ ដើម្បីផ្តល់ពត៌មានស្តីអំពីផែនការអភិវឌ្ឍន៍ឃុំ ។ |
| .៨ ការប្រជុំរបស់គ.អ.ឃ ដើម្បីត្រៀមរៀបចំសំរាប់សិក្ខាសាលាសមាហរណកម្មជាមួយវិស័យ ។ | .៨ ការប្រជុំរបស់គ.អ.ឃ ដើម្បីត្រៀមរៀបចំសំរាប់សិក្ខាសាលាសមាហរណកម្មជាមួយវិស័យ ។ |
| .៩ ការប្រជុំរបស់គ.អ.ជ.ខ ដើម្បីត្រៀមរៀបចំសិក្ខាសាលាសមាហរណកម្មវិស័យ ។ | .៩ ការប្រជុំរបស់គ.អ.ជ.ខ ដើម្បីត្រៀមរៀបចំសិក្ខាសាលាសមាហរណកម្មវិស័យ ។ |
| .១០ សិក្ខាសាលាសមាហរណកម្មផែនការវិស័យ ជាមួយនិងផែនការឃុំនៅថ្នាក់ស្រុក ។ | .១០ សិក្ខាសាលាសមាហរណកម្មផែនការវិស័យ ជាមួយនិងផែនការឃុំនៅថ្នាក់ស្រុក ។ |
| ១.១១ ការប្រជុំរបស់គ.អ.ឃ ដើម្បីធ្វើការពិនិត្យឡើងវិញលើលទ្ធផលនៃសិក្ខាសាលាសមាហរណកម្មជាមួយវិស័យ ។ | .១១ ការប្រជុំរបស់គ.អ.ឃ ដើម្បីធ្វើការពិនិត្យឡើងវិញលើលទ្ធផលនៃសិក្ខាសាលាសមាហរណកម្មជាមួយវិស័យ ។ |
| .១២ ការរៀបចំសំណើគំរោង: (ពីមុនជាផ្នែករបស់ទំរង់បែបបទទី២ –FormII ) ការសិក្សាលទ្ធភាព ការប៉ាន់ស្មានតំលៃ គិតរួមបញ្ចូលទាំងការចូលរួមវិភាគទានរបស់មូលដ្ឋាន ។ | .១២ ការរៀបចំសំណើគំរោង: ការសិក្សាលទ្ធភាព ការប៉ាន់ស្មានតំលៃ គិតរួមបញ្ចូលទាំងការចូលរួមវិភាគទានរបស់មូលដ្ឋាន ។ |
| .១៣ ការប្រជុំរបស់ គ.អ.ជ.ខនិងគ.ប្រ ដើម្បីធ្វើការវាយតំលៃគំរោងមុនការចេញប្រកាស សំរាប់ការចាប់ផ្តើមដំណើរការដេញថ្លៃគំរោង ។ | .១៣ ការប្រជុំរបស់ គ.អ.ជ.ខនិងគ.ប្រ ដើម្បីធ្វើការវាយតំលៃគំរោងមុនការចេញប្រកាស សំរាប់ការចាប់ផ្តើមដំណើរការដេញថ្លៃគំរោង ។ |
| ១.១៤ ការប្រជុំរបស់គ.អ.ភ/ភូមិ ដើម្បីផ្តល់សុពលភាពចំពោះសំណើគំរោង និងរៀបចំបង្កើតជាផែនការការងារសំរាប់គំរោង ។ | .១៤ ការប្រជុំរបស់គ.អ.ភ/ភូមិ ដើម្បីផ្តល់សុពលភាចំពោះសំណើគំរោង និងរៀបចំបង្កើតជាផែនការការងារសំរាប់គំរោង ។ |

## ២. វិធីសាស្ត្រវាយតំលៃជនបទដោយមានការចូលរួម (ភីអាអេ_PRA)

វិធីសាស្ត្រទាំងប៉ុន្មានខាងក្រោមនេះ នឹងត្រូវយកទៅប្រើប្រាស់នៅក្នុង ដំណើរការកសាងផែនការមូលដ្ឋាន(អិលភីភី_LPP) :

១. ផែនទីភូមិ

២. ផែនទីស្ត្រី

៣. ចំណាត់ថ្នាក់ទ្រព្យធន

៤. ស្ថិតិជំរឿនសង្គម

តាមដែលអាចធ្វើទៅបាន គួរតែមានអ្នកភូមិច្រើនបំផុត ចូលរួមនៅក្នុងចំណាត់ថ្នាក់ទ្រព្យធននិងស្ថិតិជំរឿនសង្គម ។ ផែនទីស្ត្រី គួរតែ ជាដ្យាក្រាម មិនមែនជាផែនទីពិតប្រាកដរបស់ភូមិឡើយ ។ ចំណាត់ថ្នាក់ទ្រព្យធន គួរអោយមានការបែងចែកគ្រួសារជាបីប្រភេទ ។ ចំណាត់ថ្នាក់ទ្រព្យធន ប្រវត្តិដើម និងស្ថានភាពសេដ្ឋកិច្ច_សង្គមកិច្ច នឹងត្រូវបញ្ចូលទៅក្នុងបញ្ជីអាទិភាពនានា ដែលរក្សាទុកនៅឯភូមិ និងក្នុងផែនការអភិវឌ្ឍន៍ឃុំ ។

| វិធីសាស្ត្រ PRA | ការពិពណ៌នា | ដំណើរការ/ វិធីសាស្ត្រ | អ្នកចូលរួម | អ្នកណារៀបចំ ? | សំគាល់ |
|---|---|---|---|---|---|
| ផែនទីភូមិ | ពត៌មានមូលដ្ឋានទិន្នន័យពន្យល់ (ផ្ទៃដីសរុប អណ្តូងទឹក ផ្ទះ) | | ក្រុមការងារ ប្រធានក្រុម គ.អ.ភ និង បុគ្គលសំខាន់ៗ | គ.អ.ភ និងក្រុមសំរបសំរួលស្រុក | ប្រហែលជាមានការលំបាកខ្លះនៅរតនៈគីរី |
| ផែនទីស្ត្រី | សកម្មភាព ចំងាយទៅដល់ធនធាន ដ្យាក្រាម | សួរយោបល់ទីប្រឹក្សាយែនឌ័រ និងជំនួយការយែនឌ័រ | អ្នកភូមិជាស្ត្រីទាំងឡាយ | គ.អ.ភ(ស្ត្រី) ដែលជួយដោយក្រុមសំរបសំរួលស្រុក | |
| ចំណាត់ថ្នាក់ទ្រព្យធន | | ជាពីរក្រុម និង សរុបលទ្ធផល | ប្រជារាស្ត្រក្នុងភូមិ | .អ.ភជំនួយដោកុមសំរបសំរួលសុក ។ | |
| ស្ថិតិជំរឿនសង្គម | សៀវភៅទិន្នន័យភូមិ | មានវិធីសាស្ត្រ៥ផ្សេងៗគ្នានិងតំរូវអោយមានការវាយតំលៃ | ប្រជារាស្ត្រក្នុងភូមិ | .អ.ភជំនួយដោកុមសំរបសំរួលសុក ។ | |

## ៣. ពត៌មានភូមិ

ពត៌មានភូមិគឺ មានគោលបំណងសំរាប់កិច្ចអភិវឌ្ឍន៍(កម្មវិធីសិលានិងកម្មវិធីផ្សេងទៀត) មិនមែនសំរាប់បំរើជាផលប្រយោជន៍នយោបាយឬមុខជំនួញណាមួយឡើយ ។

ប.ព.ភ = បញ្ជរពត៌មានភូមិ (ជាក្តារពត៌មានដែលមានរៀបចំនៅតាមភូមិគោលដៅនិមួយៗ)

ក.ព.គ = ក្តារពត៌មានគំរោង (ជាបន្ទះក្តារតូចៗដែលបង្ហាញពីពត៌មានគំរោងអភិវឌ្ឍន៍នានា)

| ទីកន្លែងរបៀបផ្សព្វផ្សាយ | ពត៌មានប្រភេទណា | នៅពេលណា |
|---|---|---|
| ប.ព.ភ | ១. ឈ្មោះនិងរូបភាព គ.អ.ភ | មុនពេលធ្វើ ផ.អ.ភ |
| ប.ព.ភ | ២ តំណាង គ.អ.ឃ នៅក្នុង គ.អ.ឃ | មុនពេលធ្វើ ផ.អ.ភ |
| ប.ព.ភ | ៣. អាទិភាពរបស់ភូមិ | បន្ទាប់ពីធ្វើ ផ.អ.ភ |
| ប.ព.ភ/ប្រជុំភូមិ | ៤. ថវិកាបំរុង | បន្ទាប់ពីធ្វើ ផ.អ.ឃ |
| ឧឃោសនៈស័ព្ទ បើមាន | ៥. គំរោងសំណើភូមិ | បន្ទាប់ពីធ្វើ ផ.អ.ឃ |
| ប.ព.ភ/ប្រជុំភូមិ | ៦. ទីតាំងគំរោងភូមិនៅលើផែនទី | បន្ទាប់ពីប្រជុំភូមិ |
| ប.ព.ភ/ប្រជុំភូមិ | ៧. វិភាគទានចូលរួមចំណែករបស់មូលដ្ឋាន (ចំនួនប៉ុន្មាន ការប្រើប្រាស់វា អ្នកណាជាអ្នកប្រមូល) | បន្ទាប់ពីប្រជុំភូមិ |
| ប.ព.ភ | ៨. ការទិញសំភារៈ និងតម្លៃ | បន្ទាប់ពីប្រជុំភូមិ |
| ប្រជុំភូមិ | ៩. ធ្វើគំរោង ដោយអ្នកម៉ៅការ ឬដោយអ្នកភូមិ | បន្ទាប់ពីប្រជុំភូមិ |
| ប្រជុំភូមិ | ១០. កិច្ចព្រមព្រៀង ការថែរក្សា នាពេលអនាគត | បន្ទាប់ពីប្រជុំភូមិ |
| ប.ព.ភ | ១១. កត់ត្រាការចាយវាយថវិកា និងថវិកានៅសល់ | បន្ទាប់ពីប្រជុំភូមិ |
| ប.ព.ភ | ១២. ការទទួលខុសត្រូវថែរក្សា | បន្ទាប់ពីប្រជុំភូមិ |
| ប.ព.ភ | ១៣. រូបភាពនានានៃគំរោង | បន្ទាប់ពីប្រជុំភូមិ |

### *ក្តារពត៌មានគំរោងភូមិ (ក.ព.គ)*

នៅក្នុងកម្មវិធីសិលាគេបានឯកភាពថា នៅគ្រប់ទីកន្លែងអនុវត្តគំរោងបន្ទះក្តារបង្ហាញពីពត៌មានសង្ខេបនៃគំរោងអភិវឌ្ឍន៍និងសញ្ញាសំគាល់កម្មវិធី ត្រូវបិទផ្សាយតាមមាតិកាដូចខាងក្រោមនេះ :

១. និមិត្តសញ្ញានៃកម្មវិធីសិលា

២. ថវិកាបំរុងរបស់គំរោង (IPF)

៣. ថវិកាវិភាគទានចូលរួមចំណែករបស់អ្នកភូមិ

៤. ឈ្មោះអ្នកអនុវត្តន៍គំរោង

៥. ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់គំរោង

៦. គណៈកម្មការថែរក្សា

ការរៀបចំបែបនេះ គឺសំដៅអោយមានតំលាភាពនៅក្នុងកម្មវិធី និងការទទួលខុសត្រូវរបស់មូលដ្ឋាន ក្នុងការថែរក្សាសមិទ្ធិផលទាំងឡាយដែលបានកសាងឡើង ។

## ៤. មាតិកានិងទំរង់បែបផែននៃផែនការអភិវឌ្ឍន៍ភូមិ_ឃុំ

ក្នុងកម្មវិធីសិលា គេបានព្រមព្រៀងគ្នាថា ផែនការអភិវឌ្ឍន៍ភូមិនានា នឹងមិនបន្តរៀបចំយូរអង្វែងតទៅទៀតទេ ហើយនិងសំរេចទៀតថា ឯកសារសំខាន់នៅកំរិតភូមិ នឹងមានតែបញ្ជីអាទិភាពរយៈពេលមួយឆ្នាំ ប៉ុណ្ណោះ ។ ពត៌មានមួយចំនួនដូចតទៅនេះ គួរតែមានរក្សាទុកនៅថ្នាក់ភូមិផងដែរ :

- ទិន្នន័យ (ស្ថិតិជំរឿនសង្គម ចំណាត់ថ្នាក់ទ្រព្យធន) ។
- ផែនទីផែនការូបនីយកម្ម (គំរោងផែនការសកម្មភាពអនាគតរបស់ភូមិ តាមការចូលចិត្ត)
- សកម្មភាពនានានៃឆ្នាំកន្លងមក (តាមការចូលចិត្ត) ។
- សេចក្តីបញ្ជាក់អះអាងពីកិច្ចព្រមព្រៀងលើផែនការអភិវឌ្ឍន៍ភូមិ (មួយប្រយោគ) ។
- បញ្ជីឈ្មោះអ្នកចូលរួម ។

***មាតិការបស់ផែនការអភិវឌ្ឍន៍ឃុំ:***

១. ប្រវត្តិឃុំ/ស្ថានភាព (ធ្វើក៏បាន មិនបាច់ក៏បាន) (១ ទំព័រ)

២. ផែនទីឃុំ ដោយរួមបញ្ចូលទិន្នន័យ និងសកម្មភាពនានាដែលបានគ្រោងទុក

៣. គោលដៅនានា និងសកម្មភាពអនាគតសំរាប់រយៈពេល ៣ ឆ្នាំ

៤. គោលដៅនានា និងសកម្មភាពអនាគតសំរាប់រយៈពេល១ឆ្នាំ

***ឧបសម្ព័ន្ធ:***

- សង្ខេបតាមវិស័យ (តារាងអាទិភាព)
- សកម្មភាពឆ្នាំមុន
- សង្ខេបទិន្នន័យស្ថិតិជំរឿនសង្គមរបស់ភូមិ
- តាមភូមិនីមួយៗ : តារាងគោលដៅនានា ឬក៏សកម្មភាពទៅអនាគត ឬក៏ជាអាទិភាព
- តារាងចំណាត់ថ្នាក់ទ្រព្យធនរបស់ភូមិ

## ៤.៨ និតិវិធីក្នុងការអនុវត្តន៍ផែនការមូលដ្ឋាន

### ១. វិភាគទានចូលរួមចំណែករបស់មូលដ្ឋាន

១. គោលការណ៍: វិភាគទានចូលរួមចំណែករបស់មូលដ្ឋាន ត្រូវតែមានផ្តល់ជាសរុប យ៉ាងហោចណាស់ក៏១០%នៃថវិកាបំរុង(IPF)ដែរ ។ វិភាគទានចូលរួមចំណែកនេះ អាចចូលរួមជា សាច់ប្រាក់ សំភារ: និងកំលាំងពលកម្ម ។

២. វិភាគទានចូលរួមចំណែកជាសាច់ប្រាក់យ៉ាងហោចណាស់ ក៏ត្រូវអោយបាន៣%នៃថវិកាបំរុង ចំនួននេះអាចនឹងអោយគេបង្កើនបាន ហើយការកំណត់ភាគរយ គឺត្រូវផ្អែកទៅលើចំណាត់ថ្នាក់ភាពក្រីក្ររបស់ឃុំ ។

៣. សាច់ប្រាក់ទាំងនេះ នឹងត្រូវប្រមូលដោយព្រះសង្ឃ គ.អ.ភ ឬអនុគណ:កម្មការរបស់ គ.អ.ភ ។

៤. សាច់ប្រាក់ចូលរួមវិភាគទានទាំងនេះ ត្រូវតែប្រមូលអោយបានមុនពេលដែលគណ:កម្មាធិការប្រតិបត្តិនៃគ.អ.ជ.ខ ផ្តល់សិទ្ធសំរេចប្រគល់ហិរញ្ញប្បទានទៅអោយគ.អ.ឃនានា ។

### ២. ការទូទាត់ប្រាក់សំរាប់កំលាំងពលកម្មគ្មានជំនាញ

គ្មានការទូទាត់ប្រាក់ណាមួយ សំរាប់កំលាំងពលកម្មគ្មានជំនាញនោះទេ ។

### ៣. ការដេញថ្លៃនិងម៉ៅការ

*ដំណើរការនៃការដេញថ្លៃ*

១. ធ្វើសេចក្តីប្រកាស (ពត៌មានជាសាធារណ:) :

- វិស័យការងារសំរាប់អ្នកម៉ៅការ ឧបករណ៍_សំភារ: និងបទពិសោធន៍បច្ចេកទេស ។
- ទំរង់បែបបទដាក់ពាក្យសុំដេញថ្លៃ និងប្រភេទគំរោងសំរាប់អ្នកម៉ៅការ ។
- ការបង់ប្រាក់កក់សំរាប់ការដេញថ្លៃគំរោង: ២០ឬក៏៣០ដុល្លាអាមេរិក ។

២. កាលបរិច្ឆេទ :

- កំណត់កាលបរិច្ឆេទសំរាប់ការដេញថ្លៃ រយ:ពេលមួយថ្ងៃបន្ទាប់ពីបានធ្វើជំរើសស្រង់ចុះក្នុងបញ្ជីនូវឈ្មោះអ្នកដែលមានសមត្ថភាពគ្រប់គ្រាន់អាចចូលដេញថ្លៃបាន ។

៣. ការប្រជុំជាផ្លូវការ:

- អ្នកចូលរួមមាន: គ.អ.ស DFT, PFT, TSS, គ.អ.ឃ(អ្នកសំរបសំរួល) គ.អ.ភ និង អ្នកម៉ៅការ ។

៤. ការដេញថ្លៃ:

- បែងចែកអ្នកម៉ៅការជាក្រុម ទៅតាមប្រភេទនៃកិច្ចសន្យា
- ការបើកសំបុត្រដេញថ្លៃ
- ធ្វើការជ្រើសរើស អាស្រ័យទៅតាមលក្ខណ:វិនិច្ឆ័យ

៥. លក្ខណ:វិនិច្ឆ័យសំរាប់ការជ្រើសរើសអ្នកម៉ៅការ :

- តម្លៃគំរោង
- ឧបករណ៍_សំភារ:
- សមត្ថភាពនិងបទពិសោធន៍ការងាររបស់អ្នកម៉ៅការ
- ភាពអនុគ្រោះនឹងត្រូវផ្តល់ទៅអោយអ្នកម៉ៅការណា ដែលមានវិញ្ញាបនបត្រឬលិខិតគតិយុត្តិពិតប្រាកដ

<u>សំគាល់</u>: - មន្រ្តីរាជការ បុគ្គលិករដ្ឋដែលបំរើការក្នុងកម្មវិធីសិលា មិនអាចធ្វើកិច្ចសន្យាសំរាប់អនុវត្តគំរោងណាមួយបានទេ ។

- គ.អ.ស_គ.អ.ឃ_គ.អ.ភ = គណ:កម្មការអភិវឌ្ឍន៍ជនបទស្រុក_ឃុំ_ភូមិ
- PFT = ក្រុមសំរបបសំរួលខេត្ត DFT = ក្រុមសំរបសំរួលស្រុក
- TSS = ក្រុមគាំទ្របច្ចេកទេស នៅក្នុងលេខាធិការដ្ឋាននៃគណ:កម្មាធិការប្រតិបត្តិនៃគ.អ.ជ.ខ

## ៤. ការអនុវត្តន៍គំរោង

១. របាយការណ៍រីកចំរើននៃការអនុវត្តន៍គំរោង

- នៅពេលអនុវត្តគំរោងនិមួយៗ ភ្នាក់ងារអនុវត្តន៍ត្រូវរៀបចំរបាយការណ៍ស្តីពីការរីកចំរើនមួយ ដើម្បីបញ្ជាក់អំពីការងារដែលបានបំពេញរួចរាល់ និងដើម្បីអាចទូទាត់ថវិកាចំណាយជំហានបន្ទាប់

២. របាយការណ៍បញ្ចប់គំរោង

- ក្រោយពីបានបញ្ចប់ការងាររួចជាស្ថាពរ ភ្នាក់ងារអនុវត្តន៍ត្រូវផ្តល់របាយការណ៍បញ្ចប់គំរោង ដែលបូកសរុបសកម្មភាពទាំងអស់ ដើម្បីធ្វើការទូទាត់ថវិកានៅសល់ជំហានចុងក្រោយ ។

៣. ការវាយតម្លៃ ប្រចាំខែ ត្រីមាស ១ឆ្នាំ/៣ឆ្នាំ

- ក្រៅពីរបាយការណ៍នានាខាងលើ ការវាយតំលៃផ្ទៃក្នុងនិងពីខាងក្រៅ ក៏ត្រូវបានរៀបចំចាត់ចែងអោយមានឡើងតាមកាលវេលាកំណត់ ដើម្បីធានាប្រសិទ្ធភាពនៃគំរោង ។

## ៥. និតិវិធីហិរញ្ញវត្ថុនៃដំណើរការកសាងផែនការមូលដ្ឋាន

៥.១. គ.អ.ជ.ខ នឹងផ្តល់ថវិកាទៅអោយគ.អ.ឃ បន្ទាប់ពីអនុម័តលើកិច្ចព្រមព្រៀងគំរោងរួច។

៥.២. ការផ្ទេរថវិកាជំហានដំបូងពី គ.អ.ជ.ខ ទៅគ.អ.ឃ ត្រូវចាត់ចែងអនុវត្តមិនអោយលើសពី២ថ្ងៃ បន្ទាប់ពីមានការដាក់ពាក្យស្នើសុំ ។

៥.៣. ការផ្តល់ថវិកាជំហានបន្តបន្ទាប់ពីគ.អ.ជ.ខ ទៅគ.អ.ឃ ត្រូវធ្វើឡើងមិនអោយហួសពីរយៈពេល៣ថ្ងៃ បន្ទាប់ពីសំណើត្រូវបានដាក់ជូនរួចហើយ ។

៥.៤. ក្រោយពេលទទួលបានថវិកាពីគ.អ.ជ.ខរួចហើយ គ.អ.ឃត្រូវផ្តល់ថវិកាទៅអោយ គ.អ.ភ ទៅតាមកិច្ចសន្យា ដោយមិនអោយហួសពីរយៈពេល១ថ្ងៃ បន្ទាប់ពីបានទទួលសំណើពី គ.អ.ភ ។

៥.៥. ចរន្តថវិការវាង គ.អ.ជ.ខ_គ.អ.ឃ_គ.អ.ភ ត្រូវបានព្រមព្រៀងទៅតាមគំនូសបំព្រួញ ដូចមានភ្ជាប់មកជាមួយខាងក្រោមនេះ ។

៥.៦. នៅពេលដែល ទំរង់បែបបទសំណើរគំរោងត្រូវបានរៀបចំរួច ពេលនោះទំរង់បែបបទនៃកិច្ចព្រមព្រៀងគំរោងគួរតែត្រូវបានគេរៀបចំរួចរាល់ មិនយឺតជាងពីរសប្តាហ៍ បន្ទាប់ពីថ្ងៃដែលបានដាក់ជូនពិនិត្យ ។

## ៦. កិច្ចសន្យា/កិច្ចព្រមព្រៀងនានា

*៦.១. កិច្ចសន្យា/កិច្ចព្រមព្រៀងរវាង គ.អ.ជ.ខនិងគ.អ.ឃ*

- ត្រូវតែមានកិច្ចសន្យា/កិច្ចព្រមព្រៀងរវាង គ.អ.ជ.ខ និង គ.អ.ឃ ។
- កិច្ចសន្យា/កិច្ចព្រមព្រៀង គួរមានទំរង់និងលក្ខខណ្ឌមួយចំនួនដូចតទៅ :

១. កាលបរិច្ឆេទ

២. ការកំណត់គូរភាគី

៣. ចំនួនថវិកាសរុប(សរសេរជាលេខនិងជាអក្សរ) ។ កាលវិភាគទូទាត់ថវិកាជូន ដែលត្រូវរៀបចំឡើង មិនគួរដាក់អោយមានលើសពី៣ដង ហើយនិងមិនគួរយោងទៅតាមប្រភេទគំរោងនោះទេ ។

៤. លក្ខខ័ណ្ឌនៃកិច្ចសន្យា/កិច្ចព្រមព្រៀង

៤.១) លក្ខខ័ណ្ឌនៃការផ្ទេរប្រាក់ (អាស្រ័យទៅតាមខេត្ត_ក្រុងនិមួយៗ) ។

៤.២) គ.អ.ឃ ត្រូវផ្ទេរថវិកាបន្តទៅអោយ គ.អ.ភដោយសមរម្យ ។

៤.៣) គ.អ.ឃត្រូវរក្សាទុកការកត់ត្រានិងរបាយការណ៍ ស្តីអំពីចំណូលចំណាយនានា។

៤.៤) គ.អ.ជ.ខ មានសិទ្ធិចុះត្រួតពិនិត្យបញ្ជីគណនេយ្យ និងកំណត់ត្រានានារបស់ គ.អ.ឃ ។

៤.៥) គ.អ.ឃ ត្រូវតែរាយការណ៍អំពីសកម្មភាពអនុវត្តន៍គំរោងនានា ។

៤.៦) សិទ្ធិសំរេចក្នុងការដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានឡើងនៅក្នុងកំឡុងពេលអនុវត្តន៏កិច្ចសន្យា ត្រូវកំណត់អោយបានច្បាស់លាស់(អាស្រ័យទៅតាមខេត្តនីមួយៗ) ។

៤.៧) ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់ របស់កិច្ចសន្យា ។

៤.៨) ទីកន្លែងទទួលនិងរក្សាទុក ច្បាប់ចំលងនានានៃកិច្ចសន្យា ។

៤.៩) ភាគីទាំងសងខាង ត្រូវតែគោរពអនុវត្តន៏តាមកិច្ចព្រមព្រៀង ។

៤.១០) ការកែតំរូវផ្សេងៗអាចធ្វើទៅបាន លុះត្រាតែមានការព្រមព្រៀងពីភាគីទាំងពីរ ។

៤.១១) ការចុះហត្ថលេខារបស់ភាគីទាំងពីរ ។

### *៦.២. កិច្ចសន្យា/កិច្ចព្រមព្រៀងរវាង គ.អ.ឃនិងគ.អ.ភ*

- ត្រូវតែមានកិច្ចសន្យា/កិច្ចព្រមព្រៀងរវាង គ.អ.ឃ និង គ.អ.ភ ។
- កិច្ចសន្យា/កិច្ចព្រមព្រៀង គួរតែមានទិដ្ឋភាពនិងលក្ខខណ្ឌមួយចំនួនដូចតទៅ :

១. កាលបរិច្ឆេទ

២. ការកំណត់គូរភាគី

៣. គ.អ.ឃ បញ្ជាក់ចំនួនថវិកាសរុប(សរសេរជាលេខនិងជាអក្សរ) អាស្រ័យទៅតាមការអនុម័ត ទំរង់បែបបទសំណើគំរោង ។

៤. លក្ខខ័ណ្ឌនានានៃកិច្ចសន្យា/កិច្ចព្រមព្រៀង :

៤.១) - ចំនួនទឹកប្រាក់ដែលត្រូវផ្តល់លើកទីមួយ បន្ទាប់ពីចុះហត្ថលេខាលើកិច្ចសន្យា
- ចំនួនទឹកប្រាក់ត្រូវផ្តល់លើកទីពីរបន្ទាប់ពីបានទទួលយល់ព្រមលើរបាយការណ៍
- ចំនួនទឹកប្រាក់ផ្តល់លើកចុងក្រោយ(បន្ទាប់ពីយល់ព្រមលើរបាយការណ៍បញ្ចប់)

៤.២) ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់នៃកិច្ចសន្យា ។

៤.៣) គ.អ.ភ ត្រូវខិតខំអនុវត្តគំរោងអោយមានប្រសិទ្ធភាព ។

៤.៤) គ.អ.ភ ត្រូវតែរក្សាទុកកំណត់ត្រា និងធ្វើរបាយការណ៍អោយបានទាន់ពេលវេលា ទៅតាមកាលវិភាគទូទាត់ ។

៤.៥) គ.អ.ឃ មានសិទ្ធិចុះពិនិត្យបញ្ជីស្លាម(ធ្វើសវនកម្ម) និងរបាយការណ៍នានារបស់ គ.អ.ភ ។

៤.៦) គ.អ.ភ ត្រូវតែបញ្ជាក់ពីចំនួនថវិកាចូលរួមវិភាគទានរបស់មូលដ្ឋាន (ដូចធ្លាប់បាន បញ្ជាក់នៅក្នុងទំរង់បែបបទទី២) ។

៤.៧) គ.អ.ជ.ខ ជាអ្នកមានសមត្ថកិច្ចដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានឡើង នៅក្នុងកំឡុងពេលអនុវត្តន៍កិច្ចសន្យា ។

៤.៨) ទីកន្លែងទទួលនិងរក្សាទុកកិច្ចសន្យា ។

៤.៩) ភាគីទាំងពីរ ត្រូវតែយល់ព្រមអនុវត្តតាមកិច្ចសន្យា ។

៤.១០) ហត្ថលេខារបស់ភាគីទាំងពីរ ។

*៦.៣. កិច្ចសន្យារវាងគ.អ.ភ និងអ្នកម៉ៅការ*

- ត្រូវតែមានកិច្ចសន្យារវាង គ.អ.ភ និង អ្នកម៉ៅការ ។
- កិច្ចសន្យា/កិច្ចព្រមព្រៀង គួរតែមានល័ក្ខខ័ណ្ឌមួយចំនួនដូចតទៅ :

១. កាលបរិច្ឆេទនៃកិច្ចសន្យា ។

២. ការកំណត់ភាគីនៃកិច្ចសន្យា ។

៣. ល័ក្ខខ័ណ្ឌនៃកិច្ចសន្យា ។

៣.១) អ្នកម៉ៅការ ត្រូវតែបំពេញការងារ ទៅតាមកិច្ចសន្យា ។

៣.២) ការទូទាត់ប្រាក់ នឹងមិនអាចធ្វើទៅបានមុនពេលគំរោងបានចាប់ផ្តើមអនុវត្ត។

៣.៣) គ.អ.ភ ត្រូវតែទូទាត់ប្រាក់អោយអ្នកម៉ៅការទៅតាមកិច្ចសន្យា ។

៤. រយៈពេលនៃកិច្ចសន្យា ។

៥. អ្នកម៉ៅការ ត្រូវតែធានាលើគុណភាពនៃសេវាកម្ម/ផលិតផល ។

៦. អ្នកម៉ៅការ ត្រូវតែទទួលខុសត្រូវលើសុវត្ថិភាព(បរិស្ថាន តំបន់ជុំវិញ សង្គម) ។

៧. គ.អ.ភនឹងមិនទទួលខុសត្រូវចំពោះបញ្ហានានា ឬគ្រោះថ្នាក់ផ្សេងៗ ដែលកើតមាន ឡើងក្នុងកំឡុងពេលកំពុងអនុវត្តគំរោងឡើយ ។

៨. អ្នកម៉ៅការ ត្រូវទទួលខុសត្រូវចំពោះការសំអាតទីតាំងគំរោង ក្រោយពីកិច្ចការបាន បញ្ចប់រួចសព្វគ្រប់ ។

៩. គ.អ.ភ ត្រូវផ្តល់ប្រាក់ទៅអោយអ្នកម៉ៅការអោយបានមុនចំនួនថ្ងៃ (ដែលនឹងត្រូវ កំនត់ដោយខេត្ត) បន្ទាប់ពីគុណភាពនៃសេវាកម្ម/ផលិតផល ត្រូវបានទទួលយល់ ព្រមដោយគណៈកម្មការវាយតំលៃមួយ និងក្រុមបច្ចេកទេស ដូចបានបញ្ជាក់ក្នុង របាយការណ៍ ។

១០.អ្នកម៉ៅការ មិនអាចកែប្រែចំនុចណាមួយនៃកិច្ចសន្យានេះ ដោយគ្មានការយល់ព្រម ពីគ.អ.ភនោះទេ ។

១១. ហត្ថលេខារបស់ភាគីទាំងពីរ ។

## ៦.៨. *បែបបទនិតិវិធីនៃការដេញថ្លៃ*

- រាល់គំរោងនានា ដែលមិនអនុវត្តផ្ទាល់ដោយគ.អ.ភ ត្រូវតែដាក់អោយដេញថ្លៃ ។
- គណៈកម្មការដេញថ្លៃមួយ ត្រូវតែបង្កើតអោយមានឡើងដោយម្ចាស់គំរោង (គ.អ.ភឬ គ.អ.ឃ)។
- ការរៀបចំដេញថ្លៃ នឹងត្រូវធ្វើឡើងបន្ទាប់ពីទំរង់បែបបទសំណើរគំរោងត្រូវបានអនុម័ត ។

## ចរន្តថវិកាសំរាប់គំរោងនានា នៃដំណើរការកសាងផែនការ មូលដ្ឋាន



## ៤.៩ នីតិវិធីក្នុងការគ្រប់គ្រងកិច្ចការអភិវឌ្ឍន៍មូលដ្ឋាន

### ១. ការរៀបចំបង្កើតគណៈកម្មការអភិវឌ្ឍន៍ភូមិ

ការរៀបចំបង្កើតគណៈកម្មការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) គឺជាតួនាទីចំបងរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត អាចស្នើសុំកិច្ចសហការនិងជំនួយពីលេខាធិការដ្ឋាននៃគ.ប្រ/គ.អ.ជ.ខ **NGOs/IOs** និងស្ថាប័នដ៏ទៃទៀត ។

គណៈកម្មការអភិវឌ្ឍន៍ភូមិ អាចមានសមាសភាពពីប្រាំទៅប្រាំពីរនាក់ ដែលត្រូវមានស្ត្រីយ៉ាងតិច ៤០% ។ ចំពោះភូមិដែលមានប្រជាជនតិចជាង ១០០គ្រួសារ គ.អ.ភ ត្រូវមានសមាជិក៥រូប ។

*ក) បែបបទនិតិវិធីនៃការបោះឆ្នោត*

- ការផ្សព្វផ្សាយជូនប្រជាជនក្នុងភូមិ អំពីការបោះឆ្នោតជ្រើសរើសគ.អ.ភ ។
- កំណត់លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសបេក្ខជន ។
- បេក្ខជនឈរឈ្មោះត្រូវចង្អុលបង្ហាញដោយអ្នកភូមិ ។
- ប្រជាពលរដ្ឋដែលមានអាយុពី១៨ឆ្នាំឡើងទៅ ទើបអាចមានសិទ្ធិឈរឈ្មោះជាបេក្ខជន និងអាចចូលរួមបោះឆ្នោតបាន ។

*ខ) តួនាទីនិងការទទួលខុសត្រូវរបស់គណៈកម្មការអភិវឌ្ឍន៍ភូមិ :*

- ប្រសិនបើប្រធានគណៈកម្មការអភិវឌ្ឍន៍ភូមិ ជាបុរស នោះអនុប្រធានជាស្ត្រី ហើយអ្នកទាំងពីរត្រូវទៅចូលរួមជាសមាជិកតំណាងនៅក្នុងគណៈកម្មការអភិវឌ្ឍន៍ឃុំ ដើម្បីជួយជំរុញអោយមានតុល្យភាពបុរសនិងស្ត្រី។
- ប្រគល់ភារៈកិច្ចសមាជិកម្នាក់ទទួលបន្ទុកយេនឌ័រ (**Gender**) ។
- ប្រគល់ភារៈកិច្ចសមាជិកម្នាក់ទទួលបន្ទុកប្រមូលវិភាគទានចូលរួម ។
- ប្រគល់ភារៈកិច្ចសមាជិកម្នាក់ទទួលបន្ទុកផ្នែកពត៌មានភូមិ ។
- ប្រធានគណៈកម្មការអភិវឌ្ឍន៍ភូមិ ជាអ្នកមានសិទ្ធិអនុម័តយល់ព្រម អោយប្រើប្រាស់ថវិកា ហើយអនុប្រធានជាអ្នកស្តីទី ។ សមាជិក ២នាក់ ទៀតក្នុងចំណោមគណៈកម្មការអភិវឌ្ឍន៍ភូមិ គឺជាអ្នកពិនិត្យបញ្ជាក់ការប្រើប្រាស់ថវិកា ផ្លាស់ប្តូរវេនទៅវិញទៅមក ។

*គ) អាណត្តិរបស់គណៈកម្មការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) :*

- នឹងមានការបោះឆ្នោត ជ្រើសរើសគណៈកម្មការអភិវឌ្ឍន៍ភូមិ(គ.អ.ភ)រយៈពេល៣ឆ្នាំម្តង។
- គ.អ.ឃ នឹងធ្វើការតាមដានត្រួតពិនិត្យការអនុវត្តន៍ការងាររបស់គ.អ.ភ តាមរយៈអ្នកភូមិ ។
- ក្នុងករណី មានសមាជិកណាម្នាក់របស់គណៈកម្មការអភិវឌ្ឍន៍ភូមិអសកម្ម មិនបានបំពេញតួនាទីរបស់ខ្លួន នោះនឹងមានការជ្រើសរើសមនុស្សផ្សេង មកបំពេញជំនួសមុនចប់អាណត្តិ ។
- សមាជិកថ្មីរបស់គ.អ.ភ អាចនឹងត្រូវបានស្នើឡើងដោយអ្នកភូមិ ហើយដាក់ឈ្មោះផ្ញើទៅកាន់ គ.អ.ភ សំរាប់ជាការស្នើសុំ ពេលនោះអ្នកដែលមានសំឡេងគាំទ្រភាគច្រើន នឹងត្រូវសំរេច។

## ២. លក្ខណៈវិនិច្ឆ័យសំរាប់បែងចែកថវិកាបំរុង :

*ក. ពីខេត្ត ទៅឃុំ:*

ផ្អែកតាមរូបមន្តជាមូលដ្ឋាន :

$$\text{ថវិកាបំរុង (IPF) ឃុំ} = \frac{\text{ថវិកាបំរុង (IPF) ខេត្ត} \times \text{ចំនួនភូមិក្នុងឃុំគោលដៅ}}{\text{ចំនួនភូមិគោលដៅសរុប}}$$

រូបមន្តម្យ៉ាងទៀតដែលអាចជំនួសបាន

សំរាប់ពីខេត្តទៅឃុំ ដោយបានតាង :

១ = ប្រជាជនសរុបនៅក្នុងឃុំ

២ = ចំនួនគ្រួសារដែលមានស្ត្រីជាមេគ្រួសារ

៣ = ចំនួនកុមារដែលមិនបានចូលរៀន

៤ = ចំនួនគ្រួសារគ្មានដីធ្លីនៅក្នុងឃុំ

៥ = ចំនួនគ្រួសារដែលក្របំផុត ក្នុងចំនោមអ្នកក្រនានា ដែលបានកំណត់ក្នុងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឃុំ ។

រូបមន្ត :

$$\text{ចំនួនថវិកាបំរុងសំរាប់ឃុំមួយ} = \frac{\text{ចំនួនថវិកាបំរុងសរុប} \times \text{ចំនួនN របស់ឃុំមួយ (១+២+៣+៤+៥)}}{\text{ចំនួន N (ចំនួនសរុបN របស់គ្រប់ឃុំទាំងអស់នៅក្នុងជំហាន៣)}}$$

*ខ. ពីឃុំទៅភូមិ*

លក្ខណៈវិនិច្ឆ័យចាំបាច់សំរាប់ការបែងចែកថវិកាបំរុង(IPF) ពីឃុំទៅភូមិមាន ដូចទៅ :

១. សំណើគំរោង ត្រូវតែធ្វើឡើងតាមរយៈ LPP គិតបញ្ចូលទាំងសេវាកម្មសង្គមផងដែរ ។

២. ទាក់ទងទៅលើលទ្ធផលនៃការសិក្សាលទ្ធភាពបច្ចេកទេស ។

៣. ចំនួនអ្នកទទួលផលសរុប ។

៤. ផ្តោតជាសំខាន់ទៅលើ**Gender** ។

៥. មានការចូលរួមវិភាគទានសមហេតុផលរបស់មូលដ្ឋាន (សូមអានការកំណត់ខាងលើ) ។

៦. ការប្រើប្រាស់ថវិកាបំរុងពីមុនមក ។

លក្ខណៈវិនិច្ឆ័យដែលអាចប្រើបានជាបន្ថែមមាន ៖

១. ផ្អែកតាមឯកសារជួយគាំទ្ររបស់គណៈកម្មការអភិវឌ្ឍន៍ឃុំ ។

២. ផ្អែកតាមពេលវេលានៃគំរោង ។

៣. មាននិរន្តរភាពដែលទាក់ទងទៅនិងការតាមដាននិងថែទាំការពារសមិទ្ធផល ។

## ៣. សមាសភាពគណៈកម្មការអភិវឌ្ឍន៍ឃុំ(គ.អ.ឃ)

គណៈកម្មការអភិវឌ្ឍន៍ឃុំត្រូវបានបង្កើតឡើងដោយការតែងតាំង និងមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១. | ប្រធានឃុំ | ជាប្រធានគ.អ.ឃ |
| ២. | ជំទប់ឃុំ | ជាអនុប្រធានគ.អ.ឃ |
| ៣. | លេខាធិការឃុំ | ជាហិរញ្ញឹក |
| ៤. | ព្រះសង្ឃ និងអាចារ្យវត្ត | ជាទីប្រឹក្សា |
| ៥. | នាយកសាលាប្រចាំឃុំ | ជាសមាជិក |
| ៦. | ប្រធានពេទ្យឃុំ | ជាសមាជិក |
| ៧. | ប៉ូលីសឃុំ | ជាសមាជិក |
| ៨. | ប្រធានគ.អ.ភគ្រប់ភូមិ | ជាសមាជិក |
| ៩. | តំណាងស្ត្រីយ៉ាងហោច៣០%មកពី គ.អ.ភ | ជាសមាជិក |

ក្នុងករណីចាំបាច់ គណៈកម្មការអភិវឌ្ឍន៍ឃុំមានសិទ្ធិអញ្ជើញអង្គការក្រៅរដ្ឋាភិបាល (NGOs) និង បុគ្គលឬអង្គភាពនានា ដែលពាក់ព័ន្ធចូលរួមប្រជុំ ។